ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយដីធ្លី

# "សៀវភៅសដីធ្លី"

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥

រៀបចំដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# អារម្ភកថា

ក្រោយពីមានការឯកភាពជាតិនាឆ្នាំ១៩៩៨ ជាងមួយទសវត្សមកនេះ ប្រទេសកម្ពុជាបានប្រែក្លាយពីស្ថានភាពបែកបាក់និងសង្គ្រាមផ្ទៃក្នុង មកជាប្រទេសមានសន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ចខ្ពស់ ហើយភាពក្រីក្រត្រូវបានកាត់បន្ថយក្នុងល្បឿនមួយគួរជាទីពេញចិត្ត។ អ្វីជាកង្វល់មួយក្នុងអារម្មណ៍របស់ខ្ញុំ គឺការងារគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិដែលជាសម្បត្តិរបស់ជាតិនៅត្រូវខិតខំពង្រឹងថែមទៀត ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពស្របតាមស្មារតីនៃសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ ស្តីពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពក្រោយឆ្នាំ២០១៥។

ខ្ញុំទទួលស្គាល់ថា ការគិតគូររបស់ខ្ញុំលើវិស័យដីធ្លីមានការយឺតយ៉ាវបន្តិចបើប្រៀបធៀបទៅនឹងវិស័យសេដ្ឋកិច្ចនិងសន្តិសុខសណ្តាប់ធ្នាប់សង្គម។ការសម្រេចបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្នុងនីតិកាលទី២នៃរដ្ឋសភា ដោយរួមបញ្ចូលផ្នែកការងារសុរិយោដីភូមិសាស្ត្រ និងផ្នែកសំណង់ ជាមួយនឹងការងាររៀបចំដែនដី នគរូបនីយកម្ម គឺជាការប្រមូលផ្តុំការងារដ៏ធំធេងមកនៅក្រោមក្រសួងថ្មីនេះ នៅពេលដែលអ្វីៗបានវិវត្តរួចទៅហើយ។ ផ្អែកលើចរិតអន្តរវិស័យ វិសាលភាពការងារ និងការប្រឈមនានា ការសម្រេចដាក់ចេញនូវកម្មវិធីកំណែទម្រង់ដីធ្លី គឺជាចក្ខុវិស័យប្រកបដោយវិចារណញ្ញាណក្នុងការសម្របសម្រួលនិងតាមដានត្រួតពិនិត្យការងារដីធ្លី។

ខ្ញុំសូមសរសើរដោយស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងនិងលទ្ធផលសម្រេចបានលើផ្នែកគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងលទ្ធផលការងារដែលក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានអនុវត្តនាពេលកន្លងមក។ ការធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការប្រើប្រាស់ដីធ្លីទៅតាមសក្តានុពលដីប្រកបដោយប្រសិទ្ធភាព គួបផ្សំនឹងការផ្តល់ដីធ្លីដល់អ្នកផលិតពិតប្រាកដ ជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង ដែលទាំងអស់នេះជាសំណាញ់សុវត្ថិភាពនៃប្រជាជាតិមួយ។

ខ្ញុំមានមោទនភាពនិងមានសោមនស្សដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំឯកសារ "**សៀវភៅសដីធ្លី**" ដែលជាត្រីវិស័យក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យសម្បូររុងរឿង ប្រកបដោយសមធម៌និងបរិយាបន្ន មានចិរភាព និងរក្សាបានលំនឹងបរិស្ថាន សម្រាប់សង្គមជាតិនាពេលបច្ចុប្បន្ននិងទៅអនាគត។

ដើម្បីជោគជ័យ ខ្ញុំសូមអំពាវនាវដល់គ្រប់ស្ថាប័នសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យចាប់អារម្មណ៍លើអ្វីដែល "**សៀវភៅសដីធ្លី**" បានលើកឡើង និងចូលរួមសហការអនុវត្តតាមជំនាញនិងភារកិច្ចរៀងៗខ្លួន ក្នុងការថែរក្សា ការពារ និងអភិវឌ្ឍដីធ្លីនិងធនធានធម្មជាតិឱ្យមានចិរភាព សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដល់មនុស្សជំនាន់នេះនិងជំនាន់ក្រោយៗទៀត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## មាតិកា


**១- សេចក្តីផ្តើម** .......... ១

**១.១- ប្រវត្តិនៃការកាន់កាប់និងការប្រើប្រាស់ដីធ្លីនៅកម្ពុជា** .......... ១

**១.២- បញ្ហាប្រឈមពាក់ព័ន្ធនឹងដីធ្លី** .......... ២

**១.៣- គោលនយោបាយដីធ្លី ឬ "សៀវភៅសដីធ្លី"** .......... ៣

**១.៤- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី** .......... ៥

១.៤.១- រដ្ឋធម្មនុញ្ញ .......... ៥

១.៤.២- ច្បាប់ភូមិបាល .......... ៦

១.៤.៣- ក្រមរដ្ឋប្បវេណី .......... ៧

**២- ចក្ខុវិស័យនៃគោលនយោបាយដីធ្លី** .......... ៨

**៣- គោលបំណងនិងគោលដៅនៃគោលនយោបាយដីធ្លី** .......... ៨

**៣.១- គោលបំណង** .......... ៩

**៣.២- គោលដៅ** .......... ៩

**៤- យុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី** .......... ១០

**៤.១- ការធ្វើសមាហរណកម្មគោលនយោបាយតាមវិស័យ** .......... ១០

៤.១.១- ការគ្រប់គ្រងដីកសិកម្ម .......... ១០

៤.១.២- ការគ្រប់គ្រងព្រៃឈើ .......... ១១

៤.១.៣- ការគ្រប់គ្រងធនធានទឹក .......... ១២

៤.១.៤- ការគ្រប់គ្រងដែននេសាទ .......... ១៣

៤.១.៥- បរិស្ថាននិងតំបន់ការពារធម្មជាតិ .......... ១៤

៤.១.៦- ទេសចរណ៍បេតិកភណ្ឌនិងធនធានធម្មជាតិ .......... ១៥

៤.១.៧- ការប្រើប្រាស់ដីធ្លីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន .......... ១៧

៤.១.៨- ការប្រើប្រាស់ដីធ្លីនិងការធ្វើអាជីវកម្មធនធានរ៉ែ .......... ១៨

**៤.២- ការសម្របសម្រួលជាមួយវិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ** .......... ១៩

**៥- ផែនការសកម្មភាពនៃគោលនយោបាយដីធ្លី** .......... ២០

**៥.១- អនុវិស័យរដ្ឋបាលដីធ្លី** .......... ២១

៥.១.១- ក្របខណ្ឌគតិយុត្តនៃការកាន់កាប់ដីធ្លី .......... ២១

៥.១.២- ការចុះបញ្ជីដីធ្លី .......... ២៣

៥.១.៣- ការចុះបញ្ជីបន្ត ការធ្វើលេខាចារឹក ការចុះបញ្ជីសិទ្ធិប្រត្យក្ស .......... ២៨

៥.១.៤- ការបង្កើតបញ្ជីសារពើភណ្ឌអចលនទ្រព្យរបស់រដ្ឋ .......... ៣០

៥.១.៥- ការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ....................................................៣១
៥.១.៦- ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ...............................................៣២
៥.១.៧- ប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដីនិងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ
ភូមិសាស្ត្រជាតិ ...................................................................................៣៣
៥.១.៨- ការធ្វើចំណាត់ថ្នាក់ប្រភេទដីតាមលក្ខណៈធម្មជាតិនៃដី..................................៣៤
**៥.២- អនុវិស័យរៀបចំដែនដី**.......................................................................................៣៥
៥.២.១- គោលការណ៍នៃការរៀបចំដែនដី..............................................................៣៧
៥.២.២- ឧបករណ៍នៃការរៀបចំដែនដី..................................................................៣៧
៥.២.៣- ឋានានុក្រមនៃផែនការរៀបចំដែនដី..........................................................៣៨
៥.២.៤- ការអភិវឌ្ឍបញ្ញត្តិនគរូបនីយកម្មនិងសំណង់នៅទីក្រុង.................................៣៨
៥.២.៥- ការអភិវឌ្ឍបញ្ញត្តិតំបន់ជនបទនិងការកែប្រែប្រភេទប្រើប្រាស់ដី......................៣៩
៥.២.៦- ការកែសម្រួលក្បាលដី ការបង្រួមក្បាលដី/បំបែកក្បាលដី..............................៤១
៥.២.៧- ការអភិវឌ្ឍតំបន់អាទិភាព.......................................................................៤៣
**៥.៣- អនុវិស័យបែងចែកដីធ្លី**......................................................................................៤៤
៥.៣.១- គោលនយោបាយសម្បទានដីសង្គមកិច្ច......................................................៤៤
៥.៣.២- គោលនយោបាយសម្បទានដីសេដ្ឋកិច្ច.......................................................៤៦
៥.៣.៣- ការអភិវឌ្ឍក្របខណ្ឌនៃភាពជាដៃគូរវាងកសិដ្ឋានខ្នាតតូច ខ្នាតមធ្យម
និងខ្នាតធំ និងការចូលរួមពីវិស័យឯកជន...................................................៤៩
៥.៣.៤- គោលនយោបាយចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមជនបទ
និងនៅតាមទីក្រុង ទីប្រជុំជន..................................................................៥១
**៥.៤-គោលនយោបាយដីធ្លីនិងបញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម**........៥៣
៥.៤.១-សភាពការណ៍បញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជា.......៥៣
៥.៤.២-គោលការណ៍ទូទៅនិងដំណោះស្រាយ.......................................................៥៤
៥.៤.៣-យន្តការនៃការអនុវត្តការប្រើប្រាស់ដីធ្លីប្រកបដោយសុវត្ថិភាពចំពោះដីធ្លី
រងផលប៉ះពាល់ដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម...........៥៥
**៥.៥- គោលនយោបាយជាតិស្តីពីលំនៅឋាននិងការតាំងទីលំនៅបណ្តោះអាសន្ន**...៥៦
៥.៥.១- ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការងារលំនៅឋាន....................................៥៦
៥.៥.២- ការរៀបចំយន្តការ...................................................................................៥៦
៥.៥.៣- ការរៀបចំផ្នែកហិរញ្ញវត្ថុសម្រាប់លំនៅឋាន...............................................៥៧
៥.៥.៤- ការរៀបចំកម្មវិធីលំនៅឋានសម្រាប់គ្រួសារមានចំណូលមធ្យមនិងទាប.....៥៨
**៥.៦- គោលនយោបាយដីធ្លីនិងជនជាតិដើមភាគតិច**...................................................៥៨

៥.៦.១- សិទ្ធិកាន់កាប់និងប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច..........៥៩
៥.៦.២- បទបញ្ញាផ្ទៃក្នុងសហគមន៍..........៦០
៥.៦.៣- ការកសាងផែនការប្រើប្រាស់ដីសហគមន៍..........៦០
**៥.៧- គោលនយោបាយដីធ្លីនិងយេនឌ័រ**..........៦១
**៥.៨- គោលនយោបាយដីធ្លីនិងការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ**..........៦៣
៥.៨.១- គោលការណ៍និងសកម្មភាពនៃការអភិវឌ្ឍតំបន់កងកម្លាំងប្រដាប់អាវុធ.....៦៣
៥.៨.២- ទិសដៅបន្ត..........៦៤
**៥.៩- ការរៀបចំប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ**..........៦៥
៥.៩.១- គោលនយោបាយនៃការវាយតម្លៃថ្លៃអចលនទ្រព្យ..........៦៥
៥.៩.២- វិធីសាស្ត្រអនុវត្តការវាយតម្លៃថ្លៃអចលនទ្រព្យ..........៦៥
៥.៩.៣- ភាពចាំបាច់និងប្រសិទ្ធភាពនៃការវាយតម្លៃថ្លៃអចលនទ្រព្យ..........៦៦
**៥.១០- គោលនយោបាយដីធ្លីនិងការប្រែប្រួលអាកាសធាតុ**..........៦៦
**៥.១១- គោលនយោបាយដីធ្លីក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ**..........៦៨
**៦- ការតាមដានត្រួតពិនិត្យ**..........៦៩
៦.១- ការកសាងសមត្ថភាពនិងការសម្របសម្រួលស្ថាប័ន..........៦៩
៦.២- ការពង្រឹងការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត..........៧០
**៧- សេចក្តីសន្និដ្ឋាន**..........៧១
**ឯកសារពិគ្រោះ**..........៧៣
**សន្ទានុក្រម**..........៧៤

# គោលនយោបាយដីធ្លី

## "សៀវភៅសដីធ្លី"

### ១- សេចក្តីផ្តើម

ដីនិងធនធានធម្មជាតិទាំងឡាយជាមូលដ្ឋានគ្រឹះក្នុងការទ្រទ្រង់សង្គម សេដ្ឋកិច្ច និងនយោបាយ។ ប្រទេសកម្ពុជាមានទីតាំងភូមិសាស្ត្រល្អប្រសើរ មានអំណោយផលពីធនធានធម្មជាតិ និងមានប្រជាជនភាគច្រើនប្រកបរបរកសិកម្ម។ ក្នុងន័យនេះ ការប្រើប្រាស់ដីនិងធនធានផ្សេងៗឱ្យមានតម្លាភាព ចីរភាព និងការគ្រប់គ្រងការប្រើប្រាស់ធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព ជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍ។ ធនធានទាំងនេះមិនគ្រាន់តែជាបេតិកភណ្ឌរបស់ប្រទេសជាតិនិងអាចបម្រើដល់ការផលិតប៉ុណ្ណោះទេ តែក៏អាចប្រើប្រាស់ជាមុខជំនួញក្នុងវិស័យពាណិជ្ជកម្មផងដែរ។

### ១.១- ប្រវត្តិនៃការកាន់កាប់និងការប្រើប្រាស់ដីធ្លីនៅកម្ពុជា

ប្រទេសកម្ពុជាបានទទួលរងនូវសង្គ្រាមជាបន្តបន្ទាប់ចាប់ពីចុងទសវត្សទី៧នៃសតវត្សទី២០មកដែលនាំឱ្យរបបនយោបាយជាតិមានការប្រែប្រួល និងធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងដីធ្លីមានការផ្លាស់ប្តូរ។ មុនទសវត្សទី៧នៃសតវត្សទី២០ ការគ្រប់គ្រងដីធ្លីផ្អែកទៅលើគោលការណ៍ដែលបុគ្គលម្នាក់ៗអាចរានឆ្ការព្រៃបាននិងប្រកាសកាន់កាប់ជាកម្មសិទ្ធិ ហើយបង់ពន្ធជូនរដ្ឋ។ ដោយនៅសម័យនោះ ប្រជាជនមានចំនួនតិច ហើយធនធានធម្មជាតិនៅសម្បូរនៅឡើយ គួបផ្សំនឹងឧបករណ៍/មធ្យោបាយសម្រាប់ទាញយកផលពីដីនៅមានលក្ខណៈសាមញ្ញ បាតុភាពកើតចេញពីបញ្ហាដីធ្លីមានតិចតួច ក្នុងទ្រង់ទ្រាយតូចៗ រវាងកសិករនិងកសិករតែប៉ុណ្ណោះ។ ក្រោយមក នៅចុងទសវត្សទី៧នៃសតវត្សទី២០ ស្ថានភាពនៃការកាន់កាប់ដីធ្លីចាប់ផ្តើមមានភាពស្មុគស្មាញបន្តិចបន្តួចនៅតាមតំបន់ខ្លះរហូតដល់ឆ្នាំ១៩៧៥។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ បានលុបបំបាត់ចោលទាំងស្រុងនូវរបបកម្មសិទ្ធិឯកជនលើចលនវត្ថុនិងអចលនវត្ថុ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាភាគច្រើនដែលរួចផុតពីរបបប្រល័យពូជសាសន៍ បានធ្វើដំណើរពពាក់ពពូនទៅគ្រប់ទិសទីក្នុងបំណងត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួន ក្រោយពីការបណ្តេញចេញពីទីក្រុង ទីប្រជុំជន ឬការបង្ខំឱ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួនកាលពីអំឡុងខែមេសា ឆ្នាំ១៩៧៥។ ប៉ុន្តែ មានគ្រួសារខ្លះ ដោយមូលហេតុផ្សេងៗឬដោយសុខភាពទ្រុឌទ្រោមខ្លាំងនិងពុំមានលទ្ធភាពធ្វើដំណើរបាន ក៏សម្រេចចិត្តស្នាក់នៅជាបណ្តោះអាសន្នជាមួយគេឯង។ ប្រជាជនមួយភាគធំបានបន្តស្នាក់នៅជាអចិន្ត្រៃយ៍លើទីតាំងថ្មី។

ប្រឈមនឹងស្ថានភាពច្របូកច្របល់ អស្ថិរភាពសង្គម អសន្តិសុខ និងគ្រោះទុរ្ភិក្ស ការរៀបចំកសាងរដ្ឋអំណាចមូលដ្ឋានដើម្បីចាត់ចែងការរក្សាសន្តិសុខនិងការរៀបចំផលិតកម្ម

កសិកម្មគឺជាការងារបន្ទាន់ចំពោះមុខ។ ដោយប្រជាជនមួយចំនួនស្ថិតក្នុងសភាពទ្រុឌទ្រោម រួមជាមួយការខ្វះខាតនូវមធ្យោបាយផលិតកម្ម ការរៀបចំចងក្រងជា***ក្រុមសាមគ្គីបង្កបង្កើនផល*** ជាវិធីតែមួយគត់ក្នុងការដោះស្រាយគ្រោះទុរភិក្សនិងការជួយសង្គ្រោះដល់ប្រជាជនរាប់លាននាក់ ដែលមានតែបាតដៃទទេ។ ដូច្នេះ ក្រៅពីទីតាំងដីលំនៅឋាន ដីស្រែចម្ការត្រូវបានបែងចែកដល់ក្រុមសាមគ្គីបង្កបង្កើនផល ដែលមានសមាជិកពី១០ទៅ២០គ្រួសារក្នុងមួយក្រុមៗ ហើយពីមួយឆ្នាំទៅមួយឆ្នាំ ការប្រើប្រាស់ដីធ្លីបានដូររូបភាពទៅជាក្រុមសាមគ្គីមានចរិតជាការវេរប្រវាស់ ដែលស្របតាមទំនៀមទម្លាប់របស់ប្រជាជនផង និងក្នុងស្មារតីធ្វើម្ចាស់លើការងារផលិតកម្មផង។ ទីបំផុត រដ្ឋាភិបាលនៃអតីត**រដ្ឋកម្ពុជា**បានសម្រេចប្រកបដោយភាពក្លាហាន ប្រគល់សិទ្ធិលើដីធ្លី និងផ្ទះសម្បែងដែលប្រជាជនបានកាន់កាប់ ជូនគ្រប់គ្រួសារទាំងអស់នៅឆ្នាំ១៩៨៩។ ឆ្លងតាមរបត់នៃការកាន់កាប់ដីធ្លីបែបនេះ ច្បាប់ភូមិបាលឆ្នាំ១៩៩២ បានផ្តល់ជាមូលដ្ឋានគតិយុត្តក្នុងការកើតឡើងវិញនៃរបបកម្មសិទ្ធិឯកជនលើដីធ្លី ហើយបន្ទាប់មកទៀតនៅឆ្នាំ២០០១ ច្បាប់ភូមិបាលត្រូវបានអភិវឌ្ឍបន្ថែមទៀត ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

ក្រោយពីរដ្ឋប្រគល់ដីធ្លីនិងផ្ទះសម្បែងឱ្យប្រជាជនកាន់កាប់ជាឯកជននៅឆ្នាំ១៩៨៩ ការចែករំលែកគ្នាឬការដោះដូរដីធ្លីផ្ទះសម្បែងដែលមិនសូវគិតពីតម្លៃ បានប្រែប្រួលនិងចាប់គិតជាតម្លៃទូទាត់តាមរបៀបទីផ្សារ។ តម្លៃនេះបានកើនឡើងជាលំដាប់នៅដើមទសវត្សទី១០ នៃសតវត្សទី២០ ដោយសារស្ថានភាពសន្តិសុខប្រទេសជាតិកាន់តែល្អប្រសើរ ការហូរចូលនៃជនជាតិខ្មែរដែលរស់នៅបរទេស ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនពីជាយដែនកម្ពុជាថៃ។ បន្ទាប់មក ការដាក់ចេញនូវគោលនយោបាយ ឈ្នះ-ឈ្នះ ដោយការធ្វើសមាហរណកម្មអតីតកងកម្លាំងខ្មែរក្រហមក្នុងមហាគ្រួសារខ្មែរនាឆ្នាំ១៩៩៨ បាននាំមកនូវសន្តិភាពនិងការឯកភាពទឹកដីទាំងមូល គួបផ្សំនឹងគោលនយោបាយអនុគ្រោះដល់ការវិនិយោគនិងការហូរចូលវិនិយោគិនបរទេស ចរន្តនៃការឡើងថ្លៃអចលនវត្ថុកើតមានជាគំហុកនៅអំឡុងឆ្នាំ២០០២-២០០៥ និងឈានដល់កម្រិតកំពូលនៅឆ្នាំ២០០៧-២០០៨។

## ១.២- បញ្ហាប្រឈមពាក់ព័ន្ធនឹងដីធ្លី

ការវិវឌ្ឍទីផ្សារអចលនទ្រព្យជាសញ្ញាវិជ្ជមានមួយនៃសេដ្ឋកិច្ចជាតិ។ ប្រជាជនមួយចំនួនទាំងនៅទីប្រជុំជន ទាំងនៅទីជនបទ បានទទួលផលពីការលក់ដូរដីធ្លីខ្លះរបស់ខ្លួននៅឱកាសដែលថ្លៃដីកើនឡើង និងបានកែលម្អជីវភាពគ្រួសារបានមួយកម្រិត។ ជាមួយគ្នានេះ ក៏លេចចេញសកម្មភាពអវិជ្ជមាននៃចលនាទន្ទ្រានកាន់កាប់ដីព្រៃរបស់រដ្ឋ ដីទំនេរមិនទាន់ប្រើប្រាស់ដីព្រៃលិចទឹក ដីព្រៃកោងកាង ដីមានបេតិកភណ្ឌ ដីបម្រុងសម្រាប់ប្រយោជន៍សាធារណៈ ... ដែលបង្កឡើងដោយពួកជនឱកាសនិយមនិងអ្នកមានឥទ្ធិពល និងភាពមានកម្រិតនៃស្ថាប័នមានសមត្ថកិច្ចមួយចំនួន៖

- នៅតាមជនបទ ដីព្រៃឈើ ដីតំបន់ការពារអភិរក្សធម្មជាតិ ដីរដ្ឋបម្រុងទុកមិនទាន់ប្រើប្រាស់ បានទទួលរងនូវការរំលោភកាន់កាប់ធ្វើជាសម្បត្តិផ្ទាល់ខ្លួន។ ខ្លះកាប់រានទន្ទ្រានដីព្រៃឈើ

ខ្លះប្រមូលទិញដីពីអ្នកកាប់រានដីព្រៃឈើក្នុងចេតនាប្រមូលដីបង្កកទុកលក់យកចំណេញ ខ្លះជួលប្រជាពលរដ្ឋឱ្យកាប់ឆ្ការព្រៃដើម្បីយកដី និងមានប្រជាពលរដ្ឋខ្លះទៀតឆ្លៀតឱកាសតាំងទីរស់នៅក្នុងដែនព្រៃឈើ បន្តកាប់រានព្រៃយកដីបន្ថែមទៀត។ ជាមួយនេះក៏មានការគប់គិតពីអ្នកមានអំណាច មានឥទ្ធិពល និងអ្នកមានភោគទ្រព្យមួយចំនួនផងដែរ។

- ការធ្វើចំណាកស្រុករបស់ប្រជាជនពីទីជនបទ ដើម្បីស្វែងរកការងារធ្វើតាមរដូវឬជាអចិន្ត្រៃយ៍នៅតាមទីក្រុង ទីប្រជុំជន ដែលក្នុងចំណោមនោះ អ្នកខ្លះបានចូលទៅស្នាក់នៅលើដីសាធារណៈរបស់រដ្ឋឬលើដីរបស់បុគ្គលឯកជនដែលនៅទំនេរ ជាដើមហេតុមួយនៃទំនាស់ដីធ្លី នៅពេលដែលរដ្ឋត្រូវការប្រើប្រាស់ដីនោះជាប្រយោជន៍សាធារណៈឬម្ចាស់ដីត្រូវការដីដើម្បីអភិវឌ្ឍ។ ការទាមទារសិទ្ធិកាន់កាប់ដីនៃទីតាំងសំណង់បណ្ដោះអាសន្ននៅតាមទីក្រុង និងទីប្រជុំជនកាន់តែមានភាពស្រួចស្រាល់នៅពេលដែលតម្លៃថ្លៃដីកាន់តែឡើងខ្ពស់ ហើយការដោះស្រាយមិនបានគ្រប់ជ្រុងជ្រោយនិងមានការជ្រៀតជ្រែកពីជនឱកាសនិយម។
- ដីរដ្ឋជាច្រើនពុំទាន់បានធ្វើអត្តសញ្ញាណកម្ម ការបោះបង្គោលកំណត់ព្រំប្រទល់ដីរដ្ឋទើបធ្វើបានមួយចំនួនតូច គួបផ្សំនឹងវិធានការគ្រប់គ្រង និងប្រើប្រាស់មិនបានជិតដល់ នាំឱ្យមានឱកាសនៃការរំលោភយកដីរដ្ឋតាមរូបភាពផ្សេងៗ។ ម្យ៉ាងទៀត កិច្ចសហការរវាងសមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីរដ្ឋ នៅមិនទាន់មានភាពរលូនល្អនៅឡើយ។
- ការធ្វើផែនការប្រើប្រាស់ដី រួមទាំងការរៀបចំគោលការណ៍និងលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្ត ដែលធ្វើឱ្យការពង្រីកទីក្រុង ទីប្រជុំជន មិនបានស្របតាមការរំពឹងទុកជួនកាលមិនធានាសណ្ដាប់ធ្នាប់ក្នុងការរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាការរៀបចំបណ្ដាញគមនាគមន៍ អាងរំដោះទឹក លំហាបៃតង សួនសាធារណៈ។ល។ ឬអាចធ្វើឱ្យប៉ះពាល់ដល់ដីដែលមានសក្ដានុពលកសិកម្មដោយការប្ដូរប្រភេទប្រើប្រាស់ដីខុសពីអំណោយផលពីធម្មជាតិនៃដី។

## ១.៣- គោលនយោបាយដីធ្លី ឬ "សៀវភៅសដីធ្លី"

ឯកសារបឋមនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលឆ្នាំ២០០២ ឬហៅថា "ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី" បានឆ្លុះបញ្ចាំងនូវបញ្ហាជាច្រើនពាក់ព័ន្ធនឹងផ្នែកទាំង៣នៃការងារដីធ្លី គឺរដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី ហើយបានគូសបញ្ជាក់ឱ្យបង្កើតក្រុមការងារសម្រាប់សិក្សានិងតាក់តែងគោលនយោបាយនិងបទដ្ឋានគតិយុត្តមួយចំនួនដែលច្បាប់ភូមិបាលបានចែងតម្រូវ។ ក្នុងបរិបទនេះ ការតាក់តែងគោលនយោបាយតាមផ្នែកការរៀបចំសេចក្ដីព្រាងច្បាប់ អនុក្រឹត្យ និងបទដ្ឋានគតិយុត្តនានា ត្រូវបានដំណើរការយ៉ាងសកម្មដោយអនុវត្តនីតិវិធីពិគ្រោះយោបល់ជាមួយស្ថាប័ននានានិងអ្នកពាក់ព័ន្ធ។

ជាលទ្ធផល គោលនយោបាយ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋានត្រូវបានសម្រេចនិងដាក់ឱ្យដំណើរការ ជាអាទិ៍ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការចុះបញ្ជី

ដីធ្លីមានលក្ខណៈដាច់ដោយដុំ ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ការគ្រប់គ្រងដីរដ្ឋ ការផ្តល់សម្បទានដីសង្គមកិច្ច ការផ្តល់សម្បទានដីសេដ្ឋកិច្ច ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ ការគ្រប់គ្រងបុរី ការដាក់ប្រាតិភោគ ការផ្ទេរនូវសិទ្ធិលើការជួលអចិន្ត្រៃយ៍ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ការផ្តល់កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ការរៀបចំនិងអភិវឌ្ឍតំបន់ឆ្នេរ ការដោះស្រាយការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។ល។

ទន្ទឹមនឹងនេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតក៏កំពុងត្រូវបានអភិវឌ្ឍឬធ្វើវិសោធនកម្មឱ្យស្របទៅតាមការវិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ជាអាទិ៍ ច្បាប់ស្តីពីការគ្រប់គ្រងការវាស់វែងនិងការផលិតផែនទី ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ច្បាប់ភូមិបាល ឆ្នាំ២០០១ និងឯកសារ "ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ឆ្នាំ២០០២" ឱ្យក្លាយទៅ ជាគោលនយោបាយដីធ្លីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយឬហៅថា"សៀវភៅសដីធ្លី"។ល។

គោលនយោបាយដីធ្លីឬហៅថា "សៀវភៅសដីធ្លី" គឺជាឯកសារវិភាគនូវស្ថានភាពនៃការកាន់កាប់ ការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិដែលត្រូវឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមចំពោះមុខ តាមរយៈការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងវិធាននានាជាធរមាន និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍតាមដំណាក់កាល ដើម្បីគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព ផលិតភាព និងនិរន្តរភាពសម្រាប់មនុស្សជំនាន់នេះនិងជំនាន់ក្រោយៗទៀត។

គោលនយោបាយដីធ្លី គឺជាក្របខណ្ឌកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិ ដែលជាប្រភពសម្រាប់ជីវភាពរស់នៅនិងរកប្រាក់ចំណូលរបស់ប្រជាជនទូទៅ។ យុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីនឹងទទួលបានលទ្ធផលល្អនៅពេលដែលធ្វើសមាហរណកម្មវិស័យពាក់ព័ន្ធផ្សេងទៀតនៃសេដ្ឋកិច្ចនិងសង្គមឱ្យបានរលូនជាមួយគ្នា។ ដូច្នេះការសម្របសម្រួលស្ថាប័នរវាងអាជ្ញាធរដែលមានអាណត្តិគ្រប់គ្រង កាន់កាប់និងប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ ជាកត្តាគន្លឹះក្នុងការអនុវត្តគោលនយោបាយដីធ្លី ដែលគ្របដណ្តប់លើទិដ្ឋភាពសង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន ព្រមទាំងផ្នែកពាក់ព័ន្ធនឹង៖

- សមធម៌និងយុត្តិធម៌ដល់គ្រប់ប្រជាជននៅទូទាំងប្រទេស
- ការរក្សាការពារសេចក្តីថ្លៃថ្នូរនិងសិទ្ធិមនុស្ស
- ការកាត់បន្ថយភាពក្រីក្រនិងវិសមភាពយេនឌ័រ
- ការលើកកម្ពស់ការអនុវត្តវិធានការដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព
- អភិបាលកិច្ចល្អលើការកាន់កាប់ដីធ្លី ការគ្រប់គ្រងព្រៃឈើ ដែននេសាទ

- ការធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី
- ការលើកកម្ពស់កិច្ចសហការអន្តរវិស័យនិងទំនាក់ទំនងអន្តរជំនាញ
- ការពង្រឹងការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត
- ការគោរពប្រពៃណី វប្បធម៌ និងការរក្សាការពារបេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ
- ការបង្កើនការចូលរួមនិងតម្លាភាពនៃដំណើរការអនុវត្តក្របខ័ណ្ឌការងារដីធ្លី ជាអាទិ៍ ផែនការប្រើប្រាស់ដីនិងរដ្ឋបាលដីធ្លី ការវាយតម្លៃថ្លៃដីនិងការកំណត់ពន្ធផ្សេងៗលើដីធ្លី ទីផ្សារដី ការត្រៀមបម្រុងដីសម្រាប់តម្រូវការនាពេលខាងមុខ
- ការរៀបចំប្រព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ
- ការត្រៀមលក្ខណៈចំពោះនិន្នាការនៃការប្រែប្រួលអាកាសធាតុ កំណើនប្រជាជននិងការធ្វើសមាហរណកម្មប្រទេសទៅក្នុងតំបន់និងក្នុងសកលលោក
- ការតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ច្បាប់ បទដ្ឋានគតិយុត្តនិងការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការងារដីធ្លី
- ការពង្រឹងគោលការណ៍អភិបាលកិច្ចល្អ និងការអនុវត្តដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវតាមគោលការណ៍វិមជ្ឈការ/វិសហមជ្ឈការ រួមទាំងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍ក្នុងមូលដ្ឋាន និង
- ការកសាងសមត្ថភាពជំនាញ វិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងការអនុវត្តការងារដីធ្លី។

កន្លងមក ក្នុងឋានៈជារដ្ឋហត្ថលេខីនៃសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ជាពិសេសការអនុវត្តនូវសេចក្តីថ្លែងការណ៍នៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស ដែលនឹងក្លាយជាគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាពនៅក្រោយឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ការកាត់បន្ថយនិងលុបបំបាត់ភាពក្រីក្រ ការថែរក្សាការពារបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ ការប្រយុទ្ធប្រឆាំងនឹងភាពរហោឋាន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍និងវិធានការជាច្រើនក្នុងវិស័យដីធ្លី ដែលក្រសួងស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល វិស័យឯកជន និងប្រជាជនត្រូវចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងនិងគោលដៅនៃការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លី។

## ១.៤- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី

### ១.៤.១- រដ្ឋធម្មនុញ្ញ

ពាក់ព័ន្ធនឹងសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ មាត្រា៤៤នៃរដ្ឋធម្មនុញ្ញបានចែងថា "*ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលលិខិតបទដ្ឋានគតិយុត្តបានបញ្ញត្តទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌។*"

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងជំពូកស្តីពីសេដ្ឋកិច្ច មាត្រា៥៨បានចែងថា *"ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់។"*។ ឯមាត្រា៥៩ បានកំណត់ថា *"រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ អនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល។"*។

## ១.៤.២- ច្បាប់ភូមិបាល

ច្បាប់ភូមិបាលឆ្នាំ២០០១ ដែលផ្អែកទាំងស្រុងលើរដ្ឋធម្មនុញ្ញនិងលើមូលដ្ឋាននៃការប្រែប្រួលនៃរបបកម្មសិទ្ធិលើដីធ្លី និងស្ថានភាពជាក់ស្តែងនៃការកាន់កាប់ដីធ្លីបានចែងបញ្ជាក់នៅក្នុងមាត្រា៦ថា *"មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលនាំឱ្យបានកម្មសិទ្ធិ។ រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុដែលជារបស់រដ្ឋក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ។* ចំពោះលទ្ធកម្មនៃកម្មសិទ្ធិ ច្បាប់នេះបានបញ្ជាក់ថា *ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេសនូវសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្មនៃកម្មសិទ្ធិដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ"*។ តាមមាត្រា៣៨ *"ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត"*។ ជារួម ភោគៈស្របច្បាប់ដែលនឹងក្លាយជាកម្មសិទ្ធិបាន គឺភោគៈស្របតាមលក្ខខណ្ឌទាំងប្រាំខាងលើ កើតឡើងនៅមុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន នៅលើដីដែលមិនមែនជាចំណែកដីសាធារណៈរបស់រដ្ឋនិងអនុវត្តបានយ៉ាងតិចប្រាំឆ្នាំ។

តាមមាត្រា២២៦នៃច្បាប់ភូមិបាលឆ្នាំ២០០១ *កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ តាមគោលដៅនេះ រដ្ឋបាលសុរិយោដី ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញបណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមាននៅលើក្បាលដីនោះ។*

ច្បាប់នេះក៏បានចែងអំពីលទ្ធកម្មនៃកម្មសិទ្ធិ អំពីកម្មសិទ្ធិឯកជន កម្មសិទ្ធិសាធារណៈ អំពីប្រភេទនិងទម្រង់ផ្សេងៗនៃកម្មសិទ្ធិ។ល។ ដែលមួយភាគធំទាក់ទងនឹងនីតិឯកជនហើយត្រូវបានបញ្ចូលនិងចែងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ចំពោះទ្រព្យដែលចាត់ជាសម្បត្តិសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈ មាត្រា១៥នៃច្បាប់ភូមិបាលបានចែកទ្រព្យនោះជា៧ប្រភេទគឺៈ

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិ
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីការរៀបចំ
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

លើសពីនេះ មាត្រា៤នៃអនុក្រឹត្យលេខ១១៨ស្តីពីការគ្រប់គ្រងដីរដ្ឋបានចែងបន្ថែមលើទ្រព្យសាធារណៈរបស់រដ្ឋ នូវដីផ្សេងៗទៀតដែលមានចរិតបម្រើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ។

តាមមាត្រា១៦នៃច្បាប់ភូមិបាលឆ្នាំ២០០១ *"ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាលបានទេ។ ... ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ឬប្រើប្រាស់ជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិឬជាសិទ្ធិភណ្ឌិកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនោះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។* មាត្រា១៧នៃច្បាប់**ភូមិបាល បានបញ្ជាក់ថា** *"ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ**អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់**ដោយច្បាប់។ ទ្រព្យទាំងនោះអាចផ្តល់ឱ្យតាមរយៈភតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យា...ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចត្រូវបានបែងចែកទៅឱ្យបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គមកិច្ចតាមលក្ខខណ្ឌដែលកំណត់ដោយអនុក្រឹត្យ"*។

### ១.៤.៣- ក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណី ដែលជាច្បាប់មូលដ្ឋានក្នុងការកំណត់គោលការណ៍ទូទៅនៃទំនាក់ទំនងគតិយុត្ត ផ្នែករដ្ឋប្បវេណី ទំនាក់ទំនងជាមួយទ្រព្យសម្បត្តិ ទំនាក់ទំនងញាតិ ត្រូវបានអនុម័តនៅឆ្នាំ២០០៧ និងត្រូវបានចាប់ផ្តើមអនុវត្តនៅខែធ្នូ ឆ្នាំ២០១១។ ដូច្នេះ ផ្នែកពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលលើអចលនទ្រព្យ ដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវអនុវត្តទៅតាមបញ្ញត្តិដែលមានចែងលម្អិតក្នុងក្រមរដ្ឋប្បវេណីវិញ។ ទោះជាយ៉ាងណាក៏ច្បាប់

ទាំងពីរនេះរក្សាអត្ថន័យនៃការគ្រប់គ្រងអចលនវត្ថុដែលធ្លាប់បានអនុវត្តពីមុនមក ដោយកំណត់ឱ្យមានការចុះបញ្ជីអចលនវត្ថុនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

នៅព្រះរាជាណាចក្រកម្ពុជាការគ្រប់គ្រងដីធ្លីឬរដ្ឋបាលដីធ្លី ត្រូវអនុវត្តតាមប្រព័ន្ធចុះបញ្ជីក្បាលដីក្នុងសៀវភៅគោលបញ្ជីដីធ្លីនិងប្លង់សុរិយោដី នៅរដ្ឋបាលសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។ ក្នុងន័យនេះ ពិតមែនតែមាត្រា១៣៣ នៃក្រមរដ្ឋប្បវេណីបានចែងថា *ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាពតាមការព្រមព្រៀងរវាងភាគី* ប៉ុន្តែមាត្រា១៣៤ បានចែងថា "*ការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅមិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះតាមបញ្ញត្តិនៃច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងដែលទាក់ទងនឹងការចុះបញ្ជី*" ហើយជាពិសេសមាត្រា១៣៥នៃក្រមនេះបានចែងបញ្ជាក់ថា "*ទោះបីមានបញ្ញត្តិនៃមាត្រា១៣៣(ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) និងមាត្រា១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះក៏ដោយក៏ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់និងបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី*"។

## ២- ចក្ខុវិស័យនៃគោលនយោបាយដីធ្លី

តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល កម្ពុជាទើបឈានចូលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ឆ្លើយតបនឹងចក្ខុវិស័យនេះ គោលនយោបាយដីធ្លីត្រូវមានវិធានការរៀបចំការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លី ប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព តាមគោលដៅជាតិនៃការកាត់បន្ថយនិងការលុបបំបាត់ភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ កិច្ចការពារជាតិនិងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារ។ ការចូលរួមរបស់វិស័យដីធ្លីតាមស្មារតីនៃ ***សៀវភៅសដីធ្លី*** នឹងរួមចំណែកដល់ការពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាពក្រោយឆ្នាំ២០១៥ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ដែលជាកត្តាសំខាន់ក្នុងការរក្សាស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គមនិងនយោបាយ។ ក្នុងទស្សនៈនេះ ក្រសួងស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រង ការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិត្រូវរៀបចំផែនការសកម្មភាពតាមវិស័យរៀងៗខ្លួនដើម្បីចូលរួមឱ្យបានសកម្មក្នុងកម្មវិធីកាត់បន្ថយនិងលុបបំបាត់ភាពក្រីក្រ។

## ៣- គោលបំណងនិងគោលដៅនៃគោលនយោបាយដីធ្លី

ចក្ខុវិស័យនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល គឺជាត្រីវិស័យសម្រាប់កំណត់គោលបំណងនិងគោលដៅនៃការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លី ដែលចាំបាច់

ត្រូវធ្វើការសម្របសម្រួលការគ្រប់គ្រង ការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឱ្យមានសមធម៌និងនិរន្តរភាព។

## ៣.១- គោលបំណង

គោលបំណងនៃគោលនយោបាយដីធ្លី គឺ៖

- ពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីនិងប្រសិទ្ធភាពនៃអភិបាលកិច្ចលើការងារដីធ្លីដើម្បីធានានូវទំនុកចិត្តនិងប្រសិទ្ធភាពនៃទីផ្សារដីធ្លី
- ផ្តល់ទិសដៅច្បាស់លាស់ ប្រកបដោយតម្លាភាពនិងសមធម៌ក្នុងការបែងចែកនិងការប្រើប្រាស់ដីរបស់រដ្ឋសម្រាប់គោលដៅឯកជននិងសាធារណៈ
- តម្រង់ទិសនៃការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច ការពារនិងឆ្លើយតបទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិឬគ្រោះមហន្តរាយផ្សេងៗ។

## ៣.២- គោលដៅ

គោលដៅនៃគោលនយោបាយដីធ្លី គឺ៖

- ធ្វើការចុះបញ្ជីកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់ ទាំងដីរបស់រដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជនឱ្យបានច្បាស់លាស់និងឆាប់រហ័ស និងសហការអនុវត្តការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះក្នុងប្រព័ន្ធផ្លូវការ
- ទប់ស្កាត់និងដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការចំពោះដីដែលមិនទាន់បានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី
- បង្កើតបញ្ជីសារពើភណ្ឌអចលនវត្ថុរបស់រដ្ឋដែលភ្ជាប់ទៅនឹងផែនទីនៃទីតាំងអចលនវត្ថុនីមួយៗដើម្បីចងក្រងជាប្រព័ន្ធទិន្នន័យដីរដ្ឋ
- កសាងប្រព័ន្ធព័ត៌មានដីធ្លីសម្រាប់ជាមូលដ្ឋាននៃការរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ បម្រើពហុគោលបំណង
- រៀបចំប្រព័ន្ធព័ត៌មានវាយតម្លៃថ្លៃអចលនទ្រព្យ ដែលមានលក្ខណៈចូលរួមនិងមានតម្លាភាពសម្រាប់ប្រើប្រាស់ជាផ្លូវការ ទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន
- សិក្សាបង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រនិងធ្វើចំណាត់ថ្នាក់ប្រភេទដីតាមលក្ខណៈពីធម្មជាតិនៃដីដើម្បីប្រើប្រាស់សក្តានុពលដីឱ្យបានសមស្រប មានប្រសិទ្ធភាព និងនិរន្តរភាព
- កសាងគោលនយោបាយ ក្របខណ្ឌគតិយុត្ត និងនីតិវិធីសម្រាប់គ្រប់គ្រងការអភិវឌ្ឍដី ទាំងដីបង្កបង្កើនផល ទាំងដីបម្រើការសាងសង់និងការតាំងទីលំនៅថ្មី
- ជំរុញការធ្វើផែនការរៀបចំដែនដីថ្នាក់ជាតិនិងផែនការប្រើប្រាស់ដីថ្នាក់ក្រោមជាតិនៅតំបន់អាទិភាព ដើម្បីកំណត់តំបន់ប្រើប្រាស់ដី ទប់ស្កាត់ការកែប្រែប្រភេទប្រើប្រាស់ដីខុសពីផែនការកំណត់ ឬការប្រើប្រាស់ដីដែលធ្វើឱ្យបាត់បង់សក្តានុពលដី
- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រនិងក្របខណ្ឌនៃការបែងចែកដី សម្រាប់រយៈពេលមធ្យមនិងវែង ក្នុងគោលដៅសង្គមកិច្ចនិងសេដ្ឋកិច្ច

- ជំរុញការអនុវត្តភាពជាដៃគូរវាងកសិដ្ឋានខ្នាតធំ សហគ្រាសកសិកម្ម និងកសិករម្ចាស់ចម្ការតូចៗ តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានិងជម្រើសផ្សេងៗទៀត
- ពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងវិស័យដីធ្លី និងអភិវឌ្ឍគោលនយោបាយ ក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ស្របតាមការវិវឌ្ឍនៃសភាពការណ៍ប្រទេសជាតិ
- លើកកម្ពស់ដល់ការឆ្លើយតបឱ្យបានសមស្រប ទៅនឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយផ្សេងៗជាយថាហេតុ។

## ៤- យុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី

យុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី គឺ៖

- តាមដាននិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានជាធរមានពាក់ព័ន្ធនឹងការងារដីធ្លីនៅតាមក្រសួងស្ថាប័ននិងនៅថ្នាក់ក្រោមជាតិ
- អនុវត្តគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការដល់ថ្នាក់ក្រោមជាតិក្នុងការធ្វើចរន្តការទិន្នន័យក្បាលដីទាំងអស់ក្នុងដែនយុត្តាធិការរបស់ខ្លួន និងការពិគ្រោះយោបល់លើគម្រោងប្រើប្រាស់ដីធ្លីក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់មូលដ្ឋាន
- រៀបចំគោលនយោបាយតាមវិស័យជំនាញ ដើម្បីកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារដីធ្លី ឬបំពេញបន្ថែមតាមសេចក្តីត្រូវការជាក់ស្តែង ឱ្យឆ្លើយតបទៅនឹងការវិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសង្គម សម្រាប់រយៈពេលខ្លី មធ្យម និងវែង
- ដកពិសោធន៍និងសិក្សាកែលម្អឬធ្វើវិសោធនកម្មច្បាប់ បទប្បញ្ញត្តិនានាឱ្យបានរលូននិងស៊ីចង្វាក់គ្នា។

## ៤.១- ការធ្វើសមាហរណកម្មគោលនយោបាយតាមវិស័យ

### ៤.១.១- ការគ្រប់គ្រងដីកសិកម្ម

វិស័យកសិកម្មជាជ្រុងទី១នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កសិកម្មកម្ពុជាមានការលូតលាស់ប្រមាណពី៣%ទៅ៤%ក្នុងមួយឆ្នាំ ហើយផ្ទៃដីកសិកម្មអាចមានលទ្ធភាពពង្រីកប្រមាណ១,៥លានហិកតាទៀត។

នៅទូទាំងប្រទេស ស្រូវជាដំណាំសំខាន់បំផុត ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីស្ថានចំនួន២ ស្ថិតនៅជុំវិញប្រព័ន្ធទន្លេមេគង្គ-ទន្លេបាសាក់ និងទន្លេសាប ក្នុងតំបន់ទំនាបកណ្តាល គឺ(១) តំបន់ទំនាបល្បាប់ចាស់ភាគខាងលើដែលពឹងលើទឹកភ្លៀងស្ទើរទាំងស្រុង និងទឹកអូរ បឹងបួរ បន្តិចបន្តួច និង(២) តំបន់ទំនាបលិចទឹកសកម្មពីទឹកជំនន់ទន្លេ។ ប្រព័ន្ធអេកូឡូស៊ីស្ថានទាំងពីរនេះលាតសន្ធឹងលើផ្ទៃដីប្រមាណ៩៧%នៃផ្ទៃដីដាំដុះសរុបក្នុងប្រទេស។ ធនធានដីជាងពាក់កណ្តាលជាដីមានជីជាតិតិច ហើយជីជាតិដីក៏មានការប្រែប្រួលខុសៗគ្នា ដែលជះឥទ្ធិពលដល់ការប្រើប្រាស់ដីសម្រាប់ដំណាំនិងរុក្ខជាតិផ្សេងៗ។ ភាគច្រើននៃដីមានជីជាតិខ្ពស់និងមធ្យមប្រមូលផ្តុំនៅតំបន់ទំនាប ប្រមាណជា៤៣%នៃតំបន់វាលទំនាបទាំងមូល។ ដីជីជាតិទាំងនោះនៅរាយប៉ាយជាប់គ្នានឹងតំបន់ខ្ពង់រាបដែលមានជីជាតិតិចតួច។ បច្ចុប្បន្ន វិស័យកសិកម្មកំពុងជំរុញការធ្វើប្រពលវប្បកម្មដំណាំ ជាពិសេស ដំណាំស្រូវ ការធ្វើពិពិធកម្មកសិកម្ម

និងពាណិជ្ជោបនីយកម្ម ជាអាទិ៍ ការប្រើប្រាស់ពូជថ្មីមានសក្តានុពលទិន្នផលខ្ពស់ គុណភាពល្អ និងការប្រើពូជដំណាំមានអាយុកាលខ្លី ការអនុវត្តកសិកម្មល្អក្នុងផលិតកម្មដំណាំ ការការពារផលិតផលសម្គាល់ភូមិសាស្ត្រ ការធ្វើកសិកម្មសរីរាង្គ ការអនុវត្តបច្ចេកវិទ្យាក្រោយការប្រមូលផល ការដោះស្រាយបញ្ហាដីខ្សោះជីជាតិ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងការរិះរកវិធីកាត់បន្ថយនិងបន្ស៊ាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។

ដីកសិកម្មដែលបានប្រើប្រាស់និងមិនទាន់ប្រើប្រាស់ កំពុងប្រឈមនឹងការផ្ទេរទៅប្រើប្រាស់ផ្សេង និងទទួលបានការការពារ ថែរក្សាតិចតួចសម្រាប់ជាដីបង្កបង្កើនផល ជាពិសេសតំបន់ដីកសិកម្មដែលទទួលបានការវិនិយោគហេដ្ឋារចនាសម្ព័ន្ធបានសមស្របហើយ គួរត្រូវបានការពារសម្រាប់ធ្វើកសិកម្មប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឱ្យផ្ទេរឬប្រើប្រាស់លើមុខសញ្ញាផ្សេងៗទេ។ ប្រឈមនឹងហានិភ័យទាំងនេះ ទាមទារឱ្យមានវិធានការគ្រប់គ្រងតំបន់អភិរក្សជីវៈចម្រុះកសិកម្មដើម្បីរក្សាសុវត្ថិភាពដល់ធនធានសេណេទិកនិងប្រព័ន្ធអេកូឡូស៊ី។ ទន្ទឹមនឹងនេះក៏ត្រូវធ្វើចំណាត់ថ្នាក់ប្រភេទដីផ្សេងៗរួមទាំងប្រភេទពូជដំណាំរុក្ខជាតិនិងប្រភេទសត្វផ្សេងៗផងដែរ ដើម្បីជៀសវាងការផ្លាស់ប្តូរប្រភេទប្រើប្រាស់ដី ដែលនាំឱ្យប៉ះពាល់ដល់ជីវៈចម្រុះណាមួយជាយថាហេតុ។ក្នុងន័យនេះគួរជំរុញកិច្ចសហការក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សម្រាប់ការគ្រប់គ្រងនិងការប្រើប្រាស់ដីកសិកម្ម និងជំរុញការសិក្សាកំណត់តំបន់ដាំដុះ កសិកម្ម ដើម្បីឈានទៅកំណត់វិធានការអនុវត្តសកម្មភាពអភិបាលកិច្ចដីកសិកម្មសំដៅធានានូវការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

### ៤.១.២- ការគ្រប់គ្រងព្រៃឈើ

ប្រជាជនកម្ពុជាមួយភាគដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ពឹងអាស្រ័យស្ទើរទាំងស្រុងទៅលើធនធានធម្មជាតិ ដែលកំពុងតែថយចុះទាំងបរិមាណ ទាំងគុណភាព។ ល្បឿននៃការបាត់បង់ផ្ទៃដីគម្របព្រៃឈើក្នុងចន្លោះឆ្នាំ២០០២និង២០១០ មានប្រមាណ០,៥០ភាគរយក្នុងមួយឆ្នាំ។ ការថយចុះនេះបានធ្វើឱ្យបាត់បង់ទីជម្រកជីវៈចម្រុះ ភាពសម្បូរបែបនៃធនធានព្រៃឈើ និងតម្លៃប្រើប្រាស់នាពេលអនាគត ព្រមទាំងបង្កឱ្យមានការហូរច្រោះដីស្រទាប់លើដែលជាស្រទាប់មានជីជាតិទៅគ្របលើដីនៅតំបន់ទំនាប ហើយនៅឆ្នាំបន្តបន្ទាប់មកទៀត ខ្សែទឹកខាងលើហូរនាំកម្ទេចគ្រួសខ្សាច់ ទៅគ្របដណ្តប់លើដីកសិកម្មនៅតំបន់ខ្សែទឹកខាងក្រោមដែលនាំឱ្យគុណភាពដីថយចុះឬអស់ផលិតភាព។ ដូច្នេះ ប្រសិនបើមិនមានវិធានការទប់ស្កាត់ឱ្យមានប្រសិទ្ធភាពទេ នោះហេតុការណ៍នេះនឹងធ្វើឱ្យមានឱនភាពដីទាំងនៅតំបន់ធ្លាប់មានព្រៃឈើទាំងនៅតំបន់វាលទំនាប ហើយនៅទីបំផុត វានឹងធ្វើឱ្យបាត់បង់ដីកសិកម្ម ក្នុងតំបន់ទាំង២។ ការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេស គម្របរុក្ខជាតិសម្រាប់ការពារជីវៈចម្រុះ គប្បីរៀបចំវិធាននៃការប្រើប្រាស់និងការគ្រប់គ្រងឱ្យមាននិរន្តរភាព។

ច្បាប់ស្តីពីព្រៃឈើបានកំណត់ថា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍មានព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន។ ព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានចែកជាបីប្រភេទគឺ **១- ព្រៃផ្តល់ផល** ដែលត្រូវរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើ ដូចជាព្រៃសម្បទាន ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ព្រៃឈើត្រូវស្តារឡើងវិញឬសម្រាប់បន្តពូជព្រៃឈើ ផ្ទៃដីព្រៃរេចរឹល ព្រៃសហគមន៍

**២-ព្រៃការពារ** ដែលត្រូវរក្សាទុកជាចម្បងដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ ដូចជាព្រៃសម្រាប់ការសិក្សាស្រាវជ្រាវ ព្រៃនិយ័តកម្មប្រភពទឹក ឬការពារទីជម្រាល ព្រៃលំហែកម្សាន្ត ព្រៃជំនឿសាសនា ដែលអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីនិង**៣- ផ្ទៃដីព្រៃសម្រាប់ផ្ទេរ** ដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរ ដុះរុក្ខជាតិបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ។ មាត្រា១៥ នៃច្បាប់នេះបានចែងថា *"សម្បទានិកព្រៃឈើមានសិទ្ធិគ្រប់គ្រងនិងប្រមូលផល អនុផលព្រៃឈើក្នុងដែនសម្បទានរបស់ខ្លួន ដោយធានាថាប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ ១- សិទ្ធិប្រើប្រាស់ជាប្រពៃណីដែលអនុវត្តនៅលើដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីដោយរដ្ឋ ស្របតាមច្បាប់ភូមិបាល ២- សិទ្ធិចេញចូលនិងសិទ្ធិប្រើប្រាស់ជាប្រពៃណីអនុវត្តដោយសហគមន៍ ដែលមានទីតាំងក្នុងឬក្បែរព្រៃសម្បទាន។"* ករណីទាំងនេះជាបញ្ហាប្រឈមមួយ នៅពេលដែលដីធ្លីរបស់ជនជាតិដើមភាគតិចនៅពុំទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើការចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ហើយការអះអាងពីការប្រើប្រាស់ព្រៃឈើជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចនៅមិនទាន់មានការកម្រិតច្បាស់លាស់នៅឡើយ។

### ៤.១.៣- ការគ្រប់គ្រងធនធានទឹក

ទឹកនិងដីជាធនធានគ្រឹះនៃវិស័យកសិកម្ម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពលើការស្តារ ការកសាង ការថែទាំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច និងធានានូវផលនៃការវិនិយោគលើអាងស្តុកទឹក ប្រឡាយទឹក សំណង់ទ្វារទឹក លូទឹក ប្រឡាយនាំដីល្បាប់ ប្រព័ន្ធដោះទឹក ទំនប់ការពារ ស្ថានីយបូមទឹកជាដើមដើម្បីបង្កើនផ្ទៃដីស្រោចស្រព ជំរុញការបង្កបង្កើនផល និងពង្រីកវារីវប្បកម្ម។ ទន្ទឹមនឹងការរៀបចំបណ្តាញស្រោចស្រពនិងប្រព័ន្ធធារាសាស្ត្រ ការការពារគុណភាពទឹក ការការពារគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត គឺជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់វិស័យកសិកម្ម។

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកបានប្រគល់ភារកិច្ចឱ្យក្រសួងធនធានទឹកនិងឧតុនិយមកំណត់គោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកស្របតាមតម្រូវការរបស់តំបន់នីមួយៗ និងការការពារគ្រោះទឹកជំនន់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងការប្រកាសកំណត់តំបន់ទំនាបជាតំបន់ស្រូបយកទឹកជំនន់។ នៅក្នុងតំបន់ការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹកនិងឧតុនិយម រួមជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ត្រូវរៀបចំផែនការស្តីពីវិធានការទប់ស្កាត់និងត្រួតពិនិត្យគ្រោះទឹកជំនន់ ដើម្បីធានាសុវត្ថិភាពជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិ។ល។

ការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែកដីធ្លីប្រកបដោយប្រសិទ្ធភាពគឺជាមូលដ្ឋានគ្រឹះដែលត្រូវរួមផ្សំជាមួយនឹងការរៀបចំប្រព័ន្ធស្រោចស្រព ការផ្តល់ចំណេះដឹងនិងបច្ចេកទេសកសិកម្ម ការកែច្នៃផលិតផលកសិកម្ម ការផ្តល់ព័ត៌មានពីទីផ្សារផលិតផលកសិកម្ម។ល។ ក្នុងបរិបទនេះការការពារគុណភាពទឹក ការរៀបចំប្រព័ន្ធធារាសាស្ត្រស្របទៅតាមគោលការណ៍នៃការថែរក្សា ការពារបរិស្ថាន ការការពារគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត គឺជាយុទ្ធសាស្ត្រគន្លឹះនៃការកាត់បន្ថយភាពក្រីក្រនិងការធានាសន្តិសុខស្បៀង។ ប្រព័ន្ធអាងទន្លេមេគង្គនិងអាងទន្លេ

សាបដែលប្រមូលផ្ដុំប្រជាជនជិត៩០% ជាវាលទំនាបដែលងាយនឹងរងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ប្រសិនបើមានការបង្ស៊ីចង្វាក់ជាមួយនឹងទឹកភ្លៀងប្រដេញពីអាងទន្លេដើមខ្សែទឹក។ ដូច្នេះការផ្ដល់ព័ត៌មានពីគ្រោះធម្មជាតិ ការរៀបចំវិធានការទប់ទល់និងទប់ស្កាត់គ្រោះទឹកជំនន់ និងការត្រួតពិនិត្យតំបន់ដែលអាចងាយរងគ្រោះដោយទឹកជំនន់ជារបៀបវារៈសំខាន់ផ្សារភ្ជាប់នឹងគោលនយោបាយដីធ្លី និងគម្រោងអភិវឌ្ឍក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។

### ៤.១.៤- ការគ្រប់គ្រងដែននេសាទ

ច្បាប់ស្ដីពីជលផលឆ្នាំ២០០៦បានចែងកំណត់ក្នុងមាត្រា៨ថា *"ដែននេសាទរួមមានដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ ដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រ ដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផល"*។ ប្រភេទដែននេសាទទាំង ៣ ខាងលើគឺ (១)*ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ* (២)*ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលភក់ ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក* និង(៣)*ដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង*។ ដែននេសាទសមុទ្រលាតសន្ធឹងចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្ររបស់កម្ពុជា។ ឯដែននេសាទទឹកសាបត្រូវបានបែងចែកជាឡូត៍នេសាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹក កន្លែងនេសាទគ្រួសារ កន្លែងនេសាទបម្រុង កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម និងទំនាបលិចទឹកក្នុងរដូវជំនោរឡើង។ តាមមាត្រា៩នៃច្បាប់ស្ដីពីជលផល ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយព្រំប្រទល់ត្រូវកំណត់ដោយអនុក្រឹត្យ។ ដូច្នេះ ដែននេសាទអាចគ្របដណ្ដប់លើដីសាធារណៈឬដីកម្មសិទ្ធិឯកជននៅរដូវជំនោរឡើង ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះទេ។ យ៉ាងណាក៏ដោយ តំបន់គ្រប់គ្រងជលផលដែលបានរៀបចំចាត់ថ្នាក់ជាកន្លែងការពារនិងអភិរក្ស ដូចជាតំបន់ទឹកជ្រៅអន្លង់ជ្រៅៗតាមដងទន្លេ បឹងទន្លេសាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ការធ្វើនេសាទគ្រប់ប្រភេទត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការពិសោធស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល។

ដែននេសាទជាដែនដីទទួលរបបទឹកទន្លេមេគង្គ នៅពេលដែលបានគោករីងរាក់ហើយមិនអាចស្ដារឡើងវិញបាន ទ្រព្យសម្បត្តិទាំងនេះអាចនឹងបាត់បង់ផលប្រយោជន៍សាធារណៈ។ ដោយការប្រែប្រួលស្ថានភាពដី ដែននេសាទមួយចំនួនត្រូវបានប្រជាជនកាន់កាប់ ប្រើប្រាស់ជាភូមិឋានឬជាដីបង្កបង្កើនផលនារដូវសម្រកនៃទឹកទន្លេមេគង្គ។ ផ្អែកតាមមាត្រា១៣នៃច្បាប់ស្ដីពីជលផល *"ការផ្ដល់កម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់គ្រប់គ្រងជលផល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានសម្រេចឱ្យធ្វើការចុះបញ្ជីដីតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវជំនោរឡើងនៃទឹកទន្លេមេគង្គដល់ព្រំប្រទល់ខេត្តកណ្ដាល និងផ្ដល់បណ្ណកម្មសិទ្ធិជូនប្រជាជនដែលបានកាន់

កាប់និងប្រើប្រាស់ជាក់ស្តែង ដោយកម្រិតការប្រើប្រាស់តាមវិធានដី។ ចំពោះដីនៅជុំវិញបឹងទន្លេសាប ដែលផ្នែកខ្លះជាតំបន់ដីទំនាបលិចទឹកក្នុងរដូវជំនោរឡើង ហើយដែលប្រជាជនធ្លាប់បានបង្កបង្កើនផលនារដូវសម្រក នឹងត្រូវធ្វើការសិក្សាលើលទ្ធភាពនៃការផ្តល់សិទ្ធិកាន់កាប់និងប្រើប្រាស់ទៅតាមករណី។ ការការពារនិងថែរក្សាដែននេសាទឱ្យមានប្រសិទ្ធភាពតម្រូវឱ្យមានការចូលរួមពីគ្រប់សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងសហគមន៍មូលដ្ឋាន។

## ៤.១.៥- បរិស្ថាននិងតំបន់ការពារធម្មជាតិ

ក្នុងដំណើរការនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានបានធ្វើការកំណត់តំបន់គ្រប់គ្រងជា៤តំបន់ ដោយអនុលោមតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិរួមមាន តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយចីរភាព និងតំបន់សហគមន៍។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាអាចប្រព្រឹត្តទៅបាននៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយចីរភាព។

ជាយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានបានរៀបចំខ្សែក្រវាត់បៃតងដើម្បីទប់ស្កាត់ការរុលចូលទៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស តាមរយៈវិធានការពីរយ៉ាងគឺ ទីមួយ ផ្តល់ជូនប្រជាសហគមន៍មូលដ្ឋាននូវដីព្រៃក្នុងតំបន់ប្រើប្រាស់ប្រកបដោយចីរភាព ដើម្បីរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ ក្នុងគោលបំណងផ្តល់សិទ្ធិប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលរស់នៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ ដោយប្រែក្លាយសហគមន៍តំបន់ការពារធម្មជាតិទៅជាការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងទេសចរណ៍សហគមន៍ សំដៅបង្កើនប្រាក់ចំណូលដល់ប្រជាសហគមន៍មូលដ្ឋាននិងផ្លាស់ប្តូរមុខរបរពីការពឹងអាស្រ័យលើធនធានធម្មជាតិទាំងស្រុងទៅជាការផ្តល់សេវាកម្មទេសចរណ៍ និងទីពីរ បង្កើតជាគម្រោងវិនិយោគអភិវឌ្ឍន៍នៅតាមតំបន់ជាយៗនៃតំបន់ការពារធម្មជាតិ ដោយមានការសិក្សាលម្អិតលើផលប៉ះពាល់បរិស្ថាននិងសង្គម ដើម្បីជារបងធម្មជាតិសម្រាប់ការពារនិងទប់ស្កាត់ការរុករានទន្ទ្រានយកដីនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស សំដៅការពារធនធានជីវៈចម្រុះ រក្សាប្រភពទឹកនិងការហូរច្រោះបាក់ដី។ ទន្ទឹមនឹងនេះ គម្រោងវិនិយោគអភិវឌ្ឍន៍ ក៏បានបង្កើតការងារដល់ប្រជាជន កាត់បន្ថយចំណាកស្រុកនិងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាសហគមន៍។

ដើម្បីគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិឱ្យមានចីរភាពបរិស្ថាន រក្សាបាននូវគុណភាពទឹក ដី ខ្យល់ និងប្រព័ន្ធអេកូឡូស៊ី និងលើកកម្ពស់សុខភាពសាធារណៈ រាជរដ្ឋាភិបាលបានរក្សាទុកព្រៃឈើធម្មជាតិក្នុងតំបន់ស្នូល និងតំបន់អភិរក្សសម្រាប់គម្រោងវិនិយោគឥណទានកាបូននិងការពារធនធានជីវៈចម្រុះ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការគ្រប់គ្រងតំបន់ដីសើមនិងតំបន់ឆ្នេរ ដោយបានដាក់បញ្ចូលតំបន់ដីសើមដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជាសាកល ជា

តំបន់រ៉ាមសារ និងបណ្ដាញអន្តរជាតិផ្សេងទៀត ដូចជាតំបន់ឋបនីយជីវមណ្ឌលនានា មានផ្លូវហើររបស់សត្វស្លាបទឹកជាដើម។ ម្យ៉ាងទៀត គោលនយោបាយកែទម្រង់វិស័យជលផលនឹងបង្កើនការអភិរក្សជីវៈចម្រុះក្នុងតំបន់ដីសើម និងបង្កើនទិន្នផលជលផលសម្រាប់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាននិងសេដ្ឋកិច្ចជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការគ្រប់គ្រងតំបន់ដីសើមនិងតំបន់ឆ្នេរត្រូវបានអនុវត្តតាមរយៈកម្មវិធីនិងគម្រោងមួយចំនួន ដើម្បីអភិរក្សតំបន់ផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង ព្រៃស្នាច់ ដើម្បីរក្សានូវតុល្យភាពរវាងការអភិរក្សនិងការអភិវឌ្ឍ។

## ៤.១.៦- ទេសចរណ៍បេតិកភណ្ឌនិងធនធានធម្មជាតិ

កម្ពុជាជាប្រទេសចំណាស់ជាងគេមួយនៅក្នុងឧបទ្វីបឥណ្ឌូចិន សម្បូរដោយបេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ។ ក្នុងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌និងទីតាំងប្រវត្តិសាស្ត្រ ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ឆ្នាំ១៩៩៦ បានចែងក្នុងមាត្រា៦អំពីរមណីយដ្ឋានដែលត្រូវការពារ មានជាអាទិ៍ ឧទ្យានដែលមានវត្ថុបុរាណ រមណីយដ្ឋាននានាដែលមានអត្ថប្រយោជន៍សម្រាប់បុរាណវិទ្យា នរវិទ្យា ឬប្រវត្តិសាស្ត្រ ដើម្បីអភិរក្សកេរដំណែលវប្បធម៌ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា និងប្រវត្តិវិទ្យា អភិរក្សទេសភាពវប្បធម៌ និងអភិវឌ្ឍទេសចរណ៍ព្រមទាំងការពារបរិស្ថាន ធម្មជាតិ។ ពាក់ព័ន្ធនឹងការជីកកកាយបេតិកភណ្ឌវប្បធម៌ ក្រមរដ្ឋប្បវេណីបានចែងក្នុងមាត្រា១៩១ត្រង់កថាខណ្ឌទី១ថា *"កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើគ្រប់ប្រភេទនៃបដិមា ចម្លាក់ ក្រឡោត បុរាណវត្ថុ ឬបេតិកភណ្ឌវប្បធម៌ផ្សេងទៀតដែលរកឃើញនៅក្នុងដីរបស់ខ្លួនបានឡើយ។ វត្ថុទាំងនេះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយកម្មសិទ្ធិករនៃដី ដែលបានរកឃើញវត្ថុទាំងនេះ មានករណីយកិច្ចប្រគល់ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ"*។

សម្បត្តិវប្បធម៌គឺជាទុនដ៏សំខាន់ជួយបង្កើនសក្ដានុពលដល់វិស័យទេសចរណ៍។

វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ គឺជាវិស័យអាទិភាពមួយត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ វិស័យនេះរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចសង្គម ផ្ដល់ឱកាសការងារ មុខរបរ ប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាជាមាសបៃតង ជាផ្នែកដ៏សំខាន់នៃសេដ្ឋកិច្ចបៃតង ដែលចំណូលនៃវិស័យនេះត្រូវបានចាក់បញ្ចូលភ្លាមៗទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ រួមចំណែកជំរុញកំណើនផលិតផលក្នុងស្រុកសរុប។

ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងក្នុងគោលដៅបង្កើនបរិមាណភ្ញៀវទេសចរឱ្យបាន៤,៥លាននាក់នៅឆ្នាំ២០១៥ និងឱ្យបាន៧លាននាក់នៅឆ្នាំ២០២០ តម្រូវឱ្យមានការរៀបចំបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនផលិតផលទេសចរណ៍ថ្មីៗឱ្យសម្បូរបែប ការកសាងនិងពង្រឹងមូលដ្ឋានផលិតនិងការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយគុណភាព ការបណ្ដុះបណ្ដាលធនធានមនុស្ស និងការពង្រឹងសន្តិសុខសុវត្ថិភាពសាធារណៈនិងទេសចរ។

តំបន់ទេសចរណ៍សំខាន់ៗត្រូវគ្រប់គ្រងនិងអភិវឌ្ឍជាបណ្ដាញផ្សារភ្ជាប់គ្នា ជាអាទិ៍៖

- តំបន់អង្គរនិងតំបន់ជុំវិញអង្គរជាប៉ូលទីមួយ ដែលតភ្ជាប់ទៅនឹងបេតិកភណ្ឌវប្បធម៌ផ្សេងៗទៀត និងបឹងទន្លេសាប រួមមានចុងឃ្នៀសនិងផ្នែកខ្លះនៃទន្លេសាប។
- រាជធានីភ្នំពេញនិងតំបន់ជុំវិញ ជាបេះដូងនិងជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ និងទេសចរណ៍ ដែលប្រមូលផ្តុំនូវរតនសម្បត្តិសម្បូរបែបនិងសំណង់ស្ថាបត្យកម្មតាមសម័យកាល។
- តំបន់ឆ្នេរដែលស្ថិតក្នុងច្រករបៀងទេសចរណ៍ភាគនិរតីរួមបញ្ចូលនូវខេត្តចំនួន៤។ ឆ្នេរសមុទ្រកម្ពុជាទើបនឹងបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនៅខែឧសភាឆ្នាំ២០១១ ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណិតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ីសេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការកសាងផែនការអភិវឌ្ឍដើម្បីថែរក្សា ប្រណិតភាពនៃតំបន់ឆ្នេរ ទាមទារនូវការចូលរួមពីក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ប្រជាជន និងសហគមន៍ក្នុងមូលដ្ឋាន ស្របតាមខ្លឹមសារនៃសារាចរណែនាំលេខ០១ សរណន. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។ សារាចរនេះបានកំណត់ការប្រើប្រាស់តំបន់ទាំងឡាយ ជាអាទិ៍ (ក)ឆ្នេរសមុទ្រដែលចាប់ពីខ្សែបន្ទាត់ទឹកសមុទ្រហូតដល់ខ្សែបន្ទាត់ហាមឃាត់ ការកាន់កាប់ (ខ)ដីចំណីឆ្នេរសមុទ្រ (គ)ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ (ឃ) តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ (ង)ផ្លូវសាធារណៈ ផ្លូវថ្មើរជើងនិងសួនច្បារ ឬតំបន់បៃតងឆ្ពោះទៅមាត់សមុទ្រ (ច)ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ (ឆ)កោះតូចធំក្នុងដែនសមុទ្រកម្ពុជា (ជ)ដែនទឹកសមុទ្រ និង(ឈ)ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ។
- ភូមិភាគឦសាន ជាតំបន់មានសក្តានុពលអេកូទេសចរណ៍ ដោយសារសម្បត្តិវប្បធម៌និងធនធានធម្មជាតិ ជាពិសេស វប្បធម៌ ប្រពៃណី និងរបៀបរស់នៅរបស់ជនជាតិដើមភាគតិច និងទេសភាពធម្មជាតិនៃតំបន់ខ្ពង់រាប។ តំបន់នេះជាប៉ូលអាទិភាពមួយ ស្ថិតក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ។
- តំបន់ជុំវិញបឹងទន្លេសាប តភ្ជាប់ខេត្តនៅជុំវិញបឹងទន្លេសាបដែលមានប្រជាជនកុះករ និងមានហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ជាតំបន់សម្បូរបែបនៃផលិតផលទេសចរណ៍ដូចជា នាវាចរណ៍កម្សាន្តតាមផ្លូវទឹក ទស្សនាភូមិបណ្តែតទឹក ប្រាង្គប្រាសាទ ផ្ទះខ្មែរបុរាណ អគារស្ថាបត្យកម្ម សិប្បកម្មប្រពៃណី។ល។

កន្លងមក ក្រសួងទេសចរណ៍បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ ២០១២-២០២០ ដែលផ្តោតជាសំខាន់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ(ទន់និងរឹង) និងផលិតផលទេសចរណ៍ ព្រមជាមួយនឹងការធ្វើឱ្យប្រសើរឡើងនូវអេកូទេសចរណ៍និងទេសចរណ៍សហគមន៍ ដែលជាគោលដៅថ្មីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទប់ទល់ទៅនឹងបម្រែបម្រួលអាកាសធាតុសកលផង និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅកម្ពុជាផង។ចំពោះផែនការសកម្មភាពលម្អិត នឹងត្រូវរៀបចំដោយយកចិត្តទុកដាក់លើការលើកកម្ពស់សេវាទេសចរណ៍ ការកសាងមូលដ្ឋានផ្គត់ផ្គង់ស្បៀងដោយគុណភាព ការថែរក្សាបរិស្ថាន

នៅតាមតំបន់បេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ តំបន់ឆ្នេរសមុទ្រ រមណីយដ្ឋាន និងការថែរក្សាវប្បធម៌ព្រៃឈើជាតិ។

### ៤.១.៧- ការប្រើប្រាស់ដីធ្លីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

រាជរដ្ឋាភិបាលបានផ្តល់សារៈសំខាន់លើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលមានស្រាប់និងស្ថាបនាបន្ថែមថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជាអាទិ៍ ផ្លូវថ្នល់ ស្ពាន កំពង់ចម្លង ផ្លូវដែក ផ្លូវទឹក កំពង់ផែ កន្លែងលើកដាក់ទំនិញ ឃ្លាំងផ្ទុកទំនិញ អាកាសយានដ្ឋាន កំពុងរៀបចំឱ្យក្លាយជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនមួយដែលមានលក្ខណៈងាយស្រួល មានសុវត្ថិភាព តភ្ជាប់តំបន់ជនបទនៅទូទាំងប្រទេសមកកាន់ទីក្រុង ទីប្រជុំជន រមណីយដ្ឋាន និងសម្រួលដល់ការដឹកជញ្ជូនឬការផ្លាស់ប្តូរផលិតផលកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ ដើម្បីបង្កើនការងារនិងប្រាក់ចំណូលដល់ប្រជាជន និងតភ្ជាប់ទៅនឹងប្រទេសជិតខាងក្នុងតំបន់និងសកលលោក។

ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់យល់ព្រមលើឧបសម្ព័ន្ធទី១១ បទដ្ឋានឬមាត្រដ្ឋាន ស្តង់ដា និងលក្ខណៈបច្ចេកទេសសម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាងប្រទេសមហាអនុតំបន់ទន្លេមេគង្គ (GMS) នៅឆ្នាំ២០០៦ និងច្បាប់យល់ព្រមលើពិធីសារទី១ របស់អាស៊ានស្តីពីកំណត់ផ្លូវនិងមធ្យោបាយបំពាក់លើផ្លូវដឹកជញ្ជូនឆ្លងកាត់សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់នៅឆ្នាំ២០០៨ ព្រមទាំងបានអនុម័តច្បាប់យល់ព្រមលើកិច្ចព្រមព្រៀងទ្វេភាគីនិងកិច្ចព្រមព្រៀងត្រីភាគី ស្តីពីការដឹកជញ្ជូនតាមផ្លូវគោកជាមួយប្រទេសជិតខាងបន្តបន្ទាប់។ ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមរូបភាពទ្វេភាគី ត្រីភាគី (CLV) មហាអនុតំបន់មេគង្គនិងអាស៊ាន (ASEAN) តម្រូវឱ្យភាគីនៃប្រទេសនីមួយៗកំណត់បណ្តាញផ្លូវថ្នល់ ស្ពាន សម្រាប់រថយន្តដឹកទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ហើយក៏តម្រូវឱ្យភាគីនៃប្រទេសហត្ថលេខីនីមួយៗរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ស្ថានីយចំណតរួមទាំងសំណង់សិល្បការ្យផ្លូវថ្នល់ ឱ្យស្របតាមបទដ្ឋានឬមាត្រដ្ឋាន ស្តង់ដា និងលក្ខណៈបច្ចេកទេស ដែលបានកំណត់ក្នុងពិធីសារនិងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង។

ផ្លូវដែកជាមធ្យោបាយដឹកជញ្ជូនដ៏សំខាន់ក្នុងការបម្រើដល់សេដ្ឋកិច្ច-សង្គម នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ កម្ពុជាមានផ្លូវដែកពីរខ្សែគឺ *ផ្លូវដែកខ្សែទិសពាយ័ព្យ* ភ្នំពេញ-ប៉ោយប៉ែតប្រវែង៣៨៦គ.ម. និង *ផ្លូវដែកខ្សែទិសនិរតី*ភ្នំពេញ-ក្រុងព្រះសីហនុប្រវែង២៦៦គ.ម.។ ផ្លូវដែកទាំងពីរខ្សែនេះត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសង្គ្រាម ហើយកំណាត់ផ្លូវសិរីសោភ័ណ-ប៉ោយប៉ែតចម្ងាយ៤៨គ.ម. ត្រូវបានកាត់ផ្តាច់ទាំងស្រុង ដោយមានសំណង់រឹងមាំនៅលើទីតាំងនោះ។ នៅដើមឆ្នាំ២០០៨ រាជរដ្ឋាភិបាលចាប់ផ្តើមស្តារឡើងវិញនូវផ្លូវដែកទាំងពីរខ្សែនេះ និងតភ្ជាប់ការដឹកជញ្ជូនរវាងប្រទេសកម្ពុជានិងថៃនិងសម្រាប់ជាផ្លូវដែកអាស៊ី ពីសិង្ហបូរីទៅគុនមីង(ចិន) ដោយកាត់តាមម៉ាឡេស៊ី ថៃ កម្ពុជា វៀតណាម រហូតដល់...

ប្រទេសចិន។ ដូច្នេះ ដើម្បីតភ្ជាប់បណ្ដាញផ្លូវដែកអាស៊ាន-គុនមីង កម្ពុជាត្រូវកសាងកំណាត់ផ្លូវដែកថ្មីប្រវែង២៥៥គ.ម. ពីស្ពានីយបាត់ដឹងទៅលុកនីញប្រទេសវៀតណាម។

ផ្លូវទឹកនិងកំពង់ផែមានតួនាទីសំខាន់ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ។ ការអនុវត្តគោលនយោបាយបើកចំហ ធ្វើឱ្យកម្ពុជាទទួលបាននូវការវិនិយោគជាបន្តបន្ទាប់ពីវិស័យឯកជនលើផ្នែកកំពង់ផែ និងកំពុងបន្តទាក់ទាញការវិនិយោគថ្មីៗបន្ថែមទៀត។ ទន្ទឹមនឹងការស្ដារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រាជរដ្ឋាភិបាលបាននិងកំពុងគិតគូរដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងការបញ្ចេញកាកសំណល់រាវនិងរឹងនៅតាមទីក្រុងធំៗ ដោយស្ដារឡើងវិញឬកសាងបន្ថែមនូវប្រព័ន្ធលូបង្ហូរនិងស្ថានីយចម្រោះទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរបញ្ចៀសជំនន់ទឹកភ្លៀង។ ការកសាងផែនការរៀបចំដែនដី និងផែនការប្រើប្រាស់ដី ត្រូវគិតគូរជាពិសេសដល់ការកសាងឬពង្រីកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ស្ថានីយចម្រោះទឹកកខ្វក់ កំពង់ផែថ្មី។ល។ និងត្រូវពង្រឹងការអនុវត្តផែនការនិងលិខិតបទដ្ឋានជាធរមាន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងលៃបម្រុងទុកដីសម្រាប់បម្រើដល់ការអភិវឌ្ឍនៅថ្ងៃអនាគត។

## ៤.១.៨- ការប្រើប្រាស់ដីធ្លីនិងការធ្វើអាជីវកម្មធនធានរ៉ែ

ធនធានរ៉ែ ជាសារធាតុមានទម្រង់រឹង រាវ ឬឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រជាអាទិ៍ ត្បូងថ្ម ថ្ងូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម គ្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន។ ច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ បានចាត់ទុកជាសម្បត្តិរបស់រដ្ឋនូវធនធានរ៉ែទាំងអស់ដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះបានកំណត់ថា គ្មានបុគ្គលណាអាចស្វែងរុករកឬធ្វើអាជីវកម្មធនធានរ៉ែដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែដែលចេញដោយស្ថាប័នមានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ដីស្របច្បាប់ដែលអាចប្រើប្រាស់រ៉ែនោះបានដោយមិនចាំបាច់មានអាជ្ញាបណ្ណតែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដែននៃដីជាកម្មសិទ្ធិនោះឡើយ។

ប្រតិបត្តិការធនធានរ៉ែ គឺការធ្វើសកម្មភាពស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដែលអាចមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី និងសកម្មភាពធ្វើអាជីវកម្មធនធានរ៉ែ។ ការស្វែងរុករកធនធានរ៉ែ គឺជាការសិក្សាស្រាវជ្រាវ ដើម្បីកំណត់សក្ដានុពល ទំហំ គុណភាព និងបរិមាណធនធានរ៉ែ ដែលអាចមានតម្លៃពាណិជ្ជកម្មដើម្បីធ្វើអាជីវកម្ម។ ការធ្វើអាជីវកម្មធនធានរ៉ែ ដែលមានការយកចេញពីជម្រករ៉ែ ការធ្វើប្រព្រឹត្តកម្ម ការដឹកជញ្ជូន។ល។ នឹងមានផលប៉ះពាល់ដល់ស្រទាប់ដីលើនិង/ឬដល់សុខភាព។ ដូច្នេះ ប្រតិបត្តិការស្វែងរុករកនិងអាជីវកម្មធនធានរ៉ែ ត្រូវអនុវត្តតាមការកំណត់ដែលមានចែងក្នុងមាត្រា២១នៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ជាអាទិ៍ ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការ

លុបអណ្ដូងរ៉ែ ការការពារសុខភាព និងសុវត្ថិភាពពលករ ការការពារសុវត្ថិភាពដល់សាធារណជន នៅក្នុងនិងជុំវិញតំបន់អណ្ដូងរ៉ែជាដើម។

ការផ្ដល់សម្បទានដល់ក្រុមហ៊ុនវិនិយោគលើអាជីវកម្មធនធានរ៉ែអាចប៉ះពាល់លើដីក្នុងតំបន់ដែលបានផ្ដល់សម្បទានដីសេដ្ឋកិច្ចនិង/ឬដីជាកម្មសិទ្ធិឯកជន ដែលតម្រូវឱ្យមានការសម្របសម្រួលជាចាំបាច់ជាមួយអ្នកពាក់ព័ន្ធ ស្របតាមគោលការណ៍និងបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីអស្សាមិករណ៍។ល។ ផ្អែកលើតម្រូវការនៃផលប្រយោជន៍ជាតិ ការផ្ដល់សេវភាព ឬការធ្វើអស្សាមិករណ៍ទីតាំងសម្រាប់ការជីកឬការបូមយករ៉ែ សម្រាប់ការដឹកជញ្ជូនរ៉ែឬកប់បំពង់បង្ហូរប្រេងឬឧស្ម័ន ជាជម្រើសដែលត្រូវតែអនុវត្ត។ យ៉ាងណាក៏ដោយពាក់ព័ន្ធនឹងការជីកកកាយរុករករ៉ែ ក្រមរដ្ឋប្បវេណីបានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រា១៩១ ថា"*កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែនៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ។ វត្ថុទាំងនេះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអ្នកដែលបានទទួលស្គាល់នូវសិទ្ធិជីកដោយរដ្ឋតាមបញ្ញត្តិនៃច្បាប់ផ្សេង មានសិទ្ធិជីកនិងទទួលវត្ថុនោះ*"។

ទន្ទឹមនឹងការកំណត់តំបន់អាជីវកម្មធនធានរ៉ែ តំបន់ភូមិសាស្ត្រស្រែអំបិលក៏ត្រូវមានវិធានការការពារនិងថែរក្សាឱ្យបានគង់វង្ស ទប់ស្កាត់ការផ្លាស់ប្ដូររូបភាពប្រើប្រាស់ដី ដែលនាំឱ្យទំហំផ្ទៃក្រឡាស្រែអំបិលរួមតូច។

## ៤.២- ការសម្របសម្រួលជាមួយវិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ

ការកាន់កាប់និងប្រើប្រាស់ដីធ្លីទាក់ទងនឹងប្រជាជនគ្រប់ស្រទាប់។ ក្នុងបេសកកម្មរបស់ខ្លួន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកសាងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តជាច្រើនសម្រាប់អនុវត្ត និងសម្របសម្រួលការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លីឱ្យមានតម្លាភាព សមធម៌ និងប្រកបដោយបរិយាបន្ន។ យ៉ាងណាក៏ដោយ ការផ្សព្វផ្សាយគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារដីធ្លី នៅមានកម្រិត។

ដើម្បីធានានូវការអភិវឌ្ឍមួយប្រកបដោយសុខដុមភាព ចាំបាច់ត្រូវបង្កើនទំនាក់ទំនងរវាងវិស័យសាធារណៈនិងវិស័យឯកជន ឬរវាងរដ្ឋនិងស្ថាប័នមិនមែនរដ្ឋ (វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ) ដើម្បីកសាងនូវវប្បធម៌មិត្តភាពជាដៃគូ ក្នុងការផ្លាស់ប្ដូរយោបល់និងស្វែងរកដំណោះស្រាយសមស្រប។ ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ការសម្របសម្រួលជាមួយវិស័យឯកជននិងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល នឹងពង្រឹងការយោគយល់គ្នា និងពន្លឿនការអភិវឌ្ឍ។

**វិស័យឯកជន រួមទាំងផ្នែកធនាគារ និងផ្នែកមីក្រូហិរញ្ញវត្ថុ** ជាដៃគូដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសហគមន៍មូលដ្ឋាន តាមរយៈកិច្ចសហការជាមួយរដ្ឋនិង/ឬជាមួយសហគមន៍ផ្ទាល់ ក្នុងការរៀបចំគម្រោងវិនិយោគនានាសម្រាប់អភិវឌ្ឍដីធ្លី គម្រោងវិនិយោគ

ផ្តែកកសិឧស្សាហកម្មលើតំបន់សម្បទានដីសេដ្ឋកិច្ច គម្រោងផ្តល់ហិរញ្ញប្បទានសម្រាប់បង្កើតមុខរបរឬពង្រីកមុខរបរ គម្រោងអភិវឌ្ឍលំនៅឋានដែលមានថ្លៃទាបសម្រាប់អ្នកមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងជនងាយរងគ្រោះ និងការអភិវឌ្ឍតំបន់មិនរៀបរយ គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មក្នុងមូលដ្ឋាន។ល។ ដោយការយល់ដឹងរបស់ប្រជាជនលើវិស័យសេដ្ឋកិច្ចនៅមានកម្រិត ការទាក់ទាញនិងកិច្ចសហការល្អជាមួយវិស័យឯកជនក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារ ត្រូវស្ថិតក្នុងក្របខណ្ឌនៃការចែករំលែកដោយសមធម៌នូវផលចំណេញរវាងវិនិយោគិន ប្រជាពលរដ្ឋក្នុងសហគមន៍ និងរដ្ឋ។ ដូច្នេះ តម្រូវឱ្យមានអន្តរាគមន៍ពីរដ្ឋក្នុងកម្រិតណាមួយ (ដូចជាកិច្ចសន្យា ការបណ្តុះបណ្តាល ការផ្តល់ព័ត៌មានជាក់លាក់) ដើម្បីកុំឱ្យកិច្ចសហការទាំងឡាយក្លាយជាការធ្វើអាជីវកម្មលើប្រជាពលរដ្ឋក្រីក្រ។ ការអភិវឌ្ឍភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនបានដំណើរការមួយជំហានធំហើយ តែការចូលរួមពីប្រជាជននៅមិនទាន់រលូននៅឡើយ ហើយការងារនេះត្រូវមានការចូលរួមពីរដ្ឋ ទាំងការរៀបចំបទដ្ឋានគតិយុត្ត ទាំងការសម្របសម្រួលដំណើរការអនុវត្ត។

**សង្គមស៊ីវិល** ជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្ត និងការអនុវត្តនូវសិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសជាតិ ដើម្បីធ្វើឱ្យសង្គមរីកចម្រើន។ ក្នុងភារកិច្ច នេះ សង្គមស៊ីវិល គួររួមចំណែកដល់ការអប់រំបណ្តុះបណ្តាលដល់សហគមន៍ ការបណ្តុះបណ្តាលមុខរបរ វិជ្ជាជីវៈ ការរៀបចំផែនការអភិវឌ្ឍសហគមន៍ ការប្រើប្រាស់ដីធ្លីឱ្យមានផលិតភាពនិងចីរភាព និងការធ្វើសេចក្តីសម្រេចចិត្តនានាដែលអាចជួយលើកកម្ពស់ជីវភាពព្រមទាំងការឧបត្ថម្ភមធ្យោបាយ បច្ចេកទេស សម្ភារៈ ការរៀបចំគម្រោងសន្សំប្រាក់សម្រាប់អភិវឌ្ឍសហគមន៍ ការចូលរួមក្នុងដំណើរការសិក្សា និងការដោះស្រាយទីតាំងលំនៅឋានបណ្តោះអាសន្ន។ល។ ទន្ទឹមនឹងនេះ សង្គមស៊ីវិលក៏អាចបញ្ចេញមតិយោបល់ក្នុងការការពារផលប្រយោជន៍ប្រជាជន។

**ដៃគូអភិវឌ្ឍ** តាមរយៈទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិឬតាមរយៈជំនួយទ្វេភាគីនិងពហុភាគីក្នុងបេសកកម្មជួយអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃប្រទេសដែលមានការអភិវឌ្ឍតិចតួចអាចផ្តល់បទពិសោធ បច្ចេកទេសនិងហិរញ្ញប្បទាន សំដៅជំរុញការកាត់បន្ថយភាពក្រីក្រនិងធានាសន្តិសុខស្បៀង។ កន្លងមក ការរួមចំណែករបស់ដៃគូអភិវឌ្ឍក្នុងវិស័យដីធ្លី បានរួមចំណែកដល់ការកសាងនូវមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងដីធ្លី ការចុះបញ្ជីដីធ្លី ការពង្រឹងការងាររៀបចំដែនដី និងនីតិវិធីនៃការបែងចែកដីធ្លី។ ដូច្នេះ ការបន្តកិច្ចសហការក៏ដូចជាការផ្តល់ព័ត៌មាននិងការផ្លាស់ប្តូរបទពិសោធជាមួយដៃគូអភិវឌ្ឍនឹងធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លីកាន់តែប្រសើរឡើង ស្របតាមនិន្នាការក្នុងតំបន់និងលើសកលលោក។

## ៥- ផែនការសកម្មភាពនៃគោលនយោបាយដីធ្លី

ការគ្រប់គ្រងដីធ្លីនៅកម្ពុជាជួបនឹងផលវិបាកធ្ងន់ធ្ងរដោយសារតែឯកសារពាក់ព័ន្ធនឹងដីធ្លីត្រូវបានបំផ្លាញចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍។ នៅពេលដែលទីផ្សារដីធ្លីចាប់មានសន្ទុះ បាតុភាពនៃការរំលោភលើដីរដ្ឋ ការដណ្តើមកាន់កាប់ ដីនិងទំនាស់ដីធ្លីកើតមានជា

បន្តបន្ទាប់ដែលទាមទារឱ្យមានការខិតខំពន្លឿនការចុះបញ្ជីដីធ្លី។ ម្យ៉ាងទៀត ការយឺតយ៉ាវក្នុងការកំណត់តំបន់ប្រើប្រាស់ដី និងការធ្វើផែនការប្រើប្រាស់ដីនៅទីតាំងដែលមានសក្តានុពលសេដ្ឋកិច្ចនិងនៅទីប្រជុំជន ទីក្រុងមួយចំនួនធ្វើឱ្យការអភិវឌ្ឍមិនទាន់មានភាពរលូនល្អ។ ប្រឈមនឹងបញ្ហាទាំងនេះ គោលដៅជាក់លាក់មួយចំនួនត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពនៃគោលនយោបាយដីធ្លីតាមអនុវិស័យនីមួយៗ៖

## ៥.១- អនុវិស័យរដ្ឋបាលដីធ្លី

ដើម្បីធានាប្រសិទ្ធភាពនៃរដ្ឋបាលដីធ្លី ចាំបាច់ត្រូវមានវិធានការពង្រឹងសិទ្ធិលើដីធ្លីនិងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលគ្របដណ្តប់លើរាល់សកម្មភាពនៃការបង្កើត ការផ្ទេរ និងការកាន់កាប់ជាសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានចែងក្នុងច្បាប់ទាំងឡាយរបស់កម្ពុជា ក្នុងច្បាប់ភូមិបាល ក្រមរដ្ឋប្បវេណី ច្បាប់ពាក់ព័ន្ធនឹងសហកម្មសិទ្ធិ និងបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិ។ក្នុងចំណោមសិទ្ធិប្រត្យក្សទាំងនេះរាប់បញ្ចូលទាំងសិទ្ធិកម្មសិទ្ធិ សិទ្ធិកាន់កាប់ សិទ្ធិភោគៈ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិអាស្រ័យផល សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ សិទ្ធិសេវភាព សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការដាក់ប្រាតិភោគ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន។ សិទ្ធិលើដីធ្លីទាំងនេះគ្របដណ្តប់ផងដែរគ្រប់សិទ្ធិលើដីធ្លីរបស់ប្រជាជនគ្រប់រូបដែលមានកន្លងមក ហើយមានការទទួលស្គាល់និងធានាដោយបទដ្ឋានគតិយុត្តជាធរមានរបស់កម្ពុជា។

ដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី រដ្ឋបាលសុរិយោដីត្រូវជំរុញការចុះបញ្ជីកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ និងធ្វើការផ្ទេរសិទ្ធិលើអចលនទ្រព្យទាំងនោះជាផ្លូវការ ទប់ស្កាត់និងដោះស្រាយវិវាទដីធ្លី ដើម្បីធានានូវទំនុកចិត្តនិងប្រសិទ្ធភាពនៃទីផ្សារដីធ្លី។

### ៥.១.១- ក្របខណ្ឌគតិយុត្តនៃការកាន់កាប់ដីធ្លី

ពាក់ព័ន្ធនឹងសិទ្ធិលើការកាន់កាប់ដីធ្លី ច្បាប់ភូមិបាលក៏ដូចជាក្រមរដ្ឋប្បវេណីបានកំណត់ប្រភេទកម្មសិទ្ធិលើអចលនទ្រព្យ និងប្រភេទសិទ្ធិកាន់កាប់ដីផ្សេងៗទៀត ជាអាទិ៍៖

**សិទ្ធិកម្មសិទ្ធិ** សំដៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត។ ការកាន់កាប់ដីធ្លីចាប់ពីឆ្នាំ១៩៨៩មក ត្រូវបានទទួលស្គាល់ជាការកាន់កាប់ដីបែបភោគៈ ដែលអាចឈានទៅជាកម្មសិទ្ធិប្រសិនបើភោគីនោះជាភោគីស្របច្បាប់ គឺបានចូលកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាននិងដោយសុចរិត មុនខែសីហា ឆ្នាំ២០០១ ហើយដីនោះមិនមែនជាផ្នែកនៃដីដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ដូច្នេះបើភោគៈស្របច្បាប់អនុវត្តបាន៥ឆ្នាំរួចហើយ ភោគីអាចស្នើសុំទៅរដ្ឋបាលសុរិយោដីដើម្បីធ្វើការចុះបញ្ជីទ្រព្យរបស់ខ្លួននៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនិងទទួលបានបណ្ណកម្មសិទ្ធិលើអចលនទ្រព្យនោះ។

**កម្មសិទ្ធិឯកត្តជន** សំដៅលើកម្មសិទ្ធិដែលគ្រប់គ្រងដោយបុគ្គលម្នាក់ ជារូបវន្តបុគ្គលឬជានីតិបុគ្គល (ក្រុមហ៊ុនឯកជនដែលមានសញ្ជាតិជាខ្មែរ ស្ថាប័នរដ្ឋ ឬគ្រឹះស្ថានសាធារណៈ)។ ឯកម្មសិទ្ធិរបស់បុគ្គលច្រើននាក់លើទ្រព្យទាំងមូលដោយសាមគ្គីគ្នា ត្រូវចាត់ជាកម្មសិទ្ធិអវិភាគ។

**សហកម្មសិទ្ធិ** សំដៅលើកម្មសិទ្ធិរបស់បុគ្គលច្រើននាក់អនុវត្តសិទ្ធិឯកជនផ្តាច់មុខលើភាគខ្លះនៃទ្រព្យដែលជាចំណែកឯកជន ហើយភាគដទៃខ្លះទៀតដែលជាចំណែករួម ជាភាគ

ប្រើប្រាស់រួម។ សហកម្មសិទ្ធិករមានសិទ្ធិពេញលេញក្នុងការផ្ទេរ ជួល ឬដាក់ប្រាតិភោគនូវចំណែកឯកជនរបស់ខ្លួនដោយមិនបំពានឬរំខានដល់ការប្រើប្រាស់ចំណែករួមនៃសហកម្មសិទ្ធិករដទៃទៀត។

**កម្មសិទ្ធិសាធារណៈ** ជាកម្មសិទ្ធិរបស់រដ្ឋឬរបស់សមូហភាពដែនដីសាធារណៈ របស់គ្រឹះស្ថានសាធារណៈឬនីតិបុគ្គលនៃនីតិសាធារណៈ ដូចជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាទ្រព្យដែលមិនអាចលក់ដូរបាននិងមិនអាចកំណត់អាជ្ញាយុកាលបាន។ ប៉ុន្តែនៅពេលដែលទ្រព្យនោះបាត់បង់ផលប្រយោជន៍សាធារណៈ ទ្រព្យនោះអាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមច្បាប់អនុបយោគ សម្រាប់គោលដៅប្រើប្រាស់ផ្សេងៗ។ ការធ្វើអនុបយោគដី គឺជាការប្តូរចំណាត់ថ្នាក់ដី ពីឋានៈដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ដែលអាចធ្វើទៅបានដោយត្រូវភ្ជាប់សំណុំឯកសារពាក់ព័ន្ធ មានជាអាទិ៍ ទីតាំងដី ព្រំប្រទល់ដែលមាននិយាមកាច្បាស់លាស់ ការវាយតម្លៃពីការបាត់បង់ផលប្រយោជន៍សាធារណៈនៃដីនោះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធផង។ ដោយបច្ចុប្បន្នពុំទាន់មានច្បាប់ស្តីពីការធ្វើអនុបយោគ ការប្តូរចំណាត់ថ្នាក់ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋអាចធ្វើឡើងដោយអនុក្រឹត្យ ដោយផ្អែកលើព្រះរាជក្រឹត្យស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងនីតិបុគ្គលសាធារណៈ។ ចំពោះការប្តូរចំណាត់ថ្នាក់ដីពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋវិញ គឺអាចធ្វើឡើងជាស្វ័យប្រវត្តិដោយអនុក្រឹត្យ។

**កម្មសិទ្ធិសមូហភាព** ជាកម្មសិទ្ធិរួមរបស់បុគ្គលច្រើននាក់ដែលមានបុព្វសិទ្ធិរៀងៗខ្លួនលើទ្រព្យនោះ ដូចជាកម្មសិទ្ធិរបស់សាសនានិងកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច។ កម្មសិទ្ធិរបស់វត្តអារាមដែលដាក់ឱ្យពុទ្ធសាសនិកប្រើប្រាស់ក្រោមការថែទាំរបស់គណៈកម្មការវត្តមិនអាចលក់ដូរឬធ្វើអំណោយ ហើយគ្មានកំណត់អាជ្ញាយុកាល។ចំពោះកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច មានមួយផ្នែកជាដីឯកជនរបស់រដ្ឋដែលសហគមន៍បានរៀបចំនិវេសនដ្ឋាននិងដីដាំដុះដាក់ស្តែង និងមួយផ្នែកទៀតជាដីសាធារណៈរបស់រដ្ឋ ដូចជាដីសម្រាប់ដូរវេនដំណាំក្នុងការធ្វើកសិកម្មប្រពៃណី ដីព្រៃអារក្ស និងដីកប់ខ្មោច។

កម្មសិទ្ធិជាសិទ្ធិប្រត្យក្សខ្ពស់បំផុតនៃសិទ្ធិលើអចលនទ្រព្យ។ ក្រៅពីសិទ្ធិកម្មសិទ្ធិនៅមានសិទ្ធិប្រត្យក្សផ្សេងទៀតលើអចលនទ្រព្យដូចជា **សិទ្ធិកាន់កាប់ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និងសិទ្ធិប្រាតិភោគប្រត្យក្ស**។ សិទ្ធិប្រើប្រាស់និងអាស្រ័យផល និងសិទ្ធិប្រាតិភោគប្រត្យក្ស ជាសិទ្ធិប្រត្យក្សមានកម្រិតផ្សេងពីកម្មសិទ្ធិ។ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផលមានជាអាទិ៍ សិទ្ធិផលុបភោគ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅនិងសេវភាព។ ទោះជាយ៉ាងណា សិទ្ធិរបស់កម្មសិទ្ធិករលើអចលនទ្រព្យតែងតែផ្សារភ្ជាប់ទៅនឹងកាតព្វកិច្ចនិងការកម្រិតសិទ្ធិខ្លះលើអចលនទ្រព្យនោះ។

ដោយគោរពទៅតាមវិធាននៃការប្រើប្រាស់ដីដែលច្បាប់ភូមិបាលឆ្នាំ២០០១ មិនបានចែងលម្អិត សិទ្ធិទាំងនេះអាចនឹងត្រូវបានកម្រិតដោយផ្អែកលើផលប្រយោជន៍សាធារណៈឬ

បញ្ចូលផលប្រយោជន៍ទាំងនោះតាមទីកន្លែងខ្លះ ឬតាមពេលវេលាខ្លះ ដូចជាសិទ្ធិលើដីនៅរដូវប្រាំងក្នុងតំបន់ជុំវិញបឹងទន្លេសាបនិងបឹងធម្មជាតិនានា សិទ្ធិលើដីវាលទំនាបនិងដីជម្រាលប្រាំងប្រព័ន្ធទន្លេមេគង្គ សិទ្ធិលើអចលនទ្រព្យមួយដោយបុគ្គលច្រើននាក់បែងចែកតាមចំណែកពេល (Time share ownership)។ល។

**សិទ្ធិនិងការទទួលខុសត្រូវទាក់ទងនឹងកម្មសិទ្ធិនិងសិទ្ធិប្រត្យក្សផ្សេងទៀត** មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍនិងអភិបាលកិច្ចល្អលើការងារដីធ្លី។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវសិទ្ធិកម្មសិទ្ធិនិងសិទ្ធិប្រត្យក្សកាន់កាប់ផ្សេងៗលើអចលនវត្ថុ ដែលសិទ្ធិទាំងនេះ ត្រូវភ្ជាប់ជាមួយនឹងការទទួលខុសត្រូវនិងកាតព្វកិច្ច។ ផ្អែកលើទស្សនៈនេះ រាជរដ្ឋាភិបាលមានវិធានការជាក់លាក់ក្នុងការៈ

- ធានានូវរាល់សកម្មភាពទាក់ទងនឹងសិទ្ធិកម្មសិទ្ធិនិងសិទ្ធិកាន់កាប់ផ្សេងៗ ហើយការប្រើសិទ្ធិទាំងនោះនឹងមិនផ្លាស់ប្តូរនូវបុព្វសិទ្ធិនិងកាតព្វកិច្ចដែលមានស្រាប់ ស្របទៅនឹងច្បាប់ជាតិនិងច្បាប់អន្តរជាតិ
- បញ្ជាក់ជូនម្ចាស់កម្មសិទ្ធិនិងម្ចាស់សិទ្ធិកាន់កាប់ផ្សេងៗទៀតដែលបានទទួលស្គាល់រួចហើយថា សិទ្ធិកម្មសិទ្ធិឬសិទ្ធិកាន់កាប់ផ្សេងៗតែងផ្សារភ្ជាប់នឹងការកម្រិតដោយសិទ្ធិដទៃផ្សេងទៀត និងដោយវិធានការដែលរាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការបម្រើផលប្រយោជន៍សាធារណៈ ដូចជាវិធានការលើកកម្ពស់សុខុមាលភាពប្រជាជនទៅតាមច្បាប់កំណត់ រួមទាំងការការពារបរិស្ថានស្របតាមច្បាប់ជាធរមាន
- ផ្តល់នូវការគាំទ្រដល់ប្រជាជនគ្រប់រូបដោយគ្មានការរើសអើង និងការគាំទ្រជាពិសេសដល់ស្ត្រីភេទនិងប្រជាជនដែលមានភាពលំបាកក្នុងការទទួលបាននូវសិទ្ធិកម្មសិទ្ធិឬសិទ្ធិកាន់កាប់ផ្សេងៗសម្រាប់ការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន ដើម្បីទទួលបាននូវសេវានានា និងការចូលរួមក្នុងដំណើរការទាំងឡាយណាដែលអាចប៉ះពាល់ដល់សិទ្ធិកាន់កាប់របស់ពួកគាត់។

## ៥.១.២- ការចុះបញ្ជីដីធ្លី

## មូលដ្ឋានគតិយុត្តនៃការចុះបញ្ជីដីធ្លី

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣ បានចែងថា"*ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញបណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ...*" ជាមួយនេះមាត្រា២២៦ ក៏បានកំណត់ថា "*កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ ...រដ្ឋបាលសុរិយោដីក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាស្ថាប័នមានសមត្ថកិច្ចក្នុងការធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញបណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមានលើក្បាលដីនោះ។*

ការគ្រប់គ្រងដីឬរដ្ឋបាលដីធ្លីនៅព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមប្រព័ន្ធចុះបញ្ជីដីក្នុងសៀវភៅគោលបញ្ជីដីធ្លីនិងប្លង់សុរិយោដី នៅរដ្ឋបាលសុរិយោដីនៃក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ប្រព័ន្ធនេះមានភាពខុសប្លែកពីប្រទេសមួយចំនួនដែលគ្រប់គ្រងដីធ្លីដោយប្រើប្រព័ន្ធកត់ត្រា ដែលក្នុងនោះ ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សធ្វើឡើងទៅតាមការព្រមព្រៀងរវាងភាគីពាក់ព័ន្ធ។ ផ្អែកលើគោលការណ៍នេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងបញ្ជាក់ក្នុងមាត្រា១៣៤និងមាត្រា១៣៥ថា ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងមិនអាចតតាំងនឹងតតិយជនបាននិងមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់និងបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី។

ការចុះបញ្ជីអចលនទ្រព្យ គឺជាបញ្ហាគន្លឹះក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្រជាជាតិមួយ ទាំងទ្រព្យរបស់រដ្ឋទាំងទ្រព្យរបស់បុគ្គលឯកជន។ បច្ចុប្បន្ន ការចុះបញ្ជីដីផ្អែកទៅលើសិទ្ធិភោគៈស្របច្បាប់ដែលប្រជាពលរដ្ឋបានកាន់កាប់និងប្រើប្រាស់ជាក់ស្តែង ដោយអនុវត្តទៅតាមស្មារតីនៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នា២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លីឬហៅថាការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ឬទៅតាមស្មារតីនៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមការស្នើសុំពីបុគ្គលម្ចាស់សិទ្ធិ។ នីតិវិធីនិងដំណើរការនៃការចុះបញ្ជីដីធ្លីទាំងនេះជានីតិវិធីមានតម្លាភាព ដោយតម្រូវឱ្យមានការចូលរួមកំណត់ទីតាំងនិងព្រំប្រទល់ក្បាលដីពីអ្នកអះអាងថាជាម្ចាស់លើអចលនទ្រព្យ មានការព្រមព្រៀងពីអ្នកជាប់ព្រំ និងឆ្លងកាត់ការបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃ នូវទិន្នន័យដែលប្រមូលបាន សម្រាប់ការតវ៉ាផ្សេងៗ។ ការចុះបញ្ជីគឺផ្អែកទៅលើព័ត៌មានរបស់អ្នកអះអាងថាជាម្ចាស់ទ្រព្យដែលអាចជាទ្រព្យរួមប្តីប្រពន្ធ ទ្រព្យកូន(នីតិជន) ជាទ្រព្យដោយឡែករបស់ប្តីឬរបស់ប្រពន្ធ ទ្រព្យលីវ ទ្រព្យសម្ហូភាព ទ្រព្យរបស់នីតិបុគ្គលដែលមាននីតិបុគ្គលឯកជននិងនីតិបុគ្គលសាធារណៈ។ល។

ទន្ទឹមនឹងនេះ ទាក់ទងនឹងការចុះបញ្ជី ក៏មានប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ ស្តីពី "ការចុះបញ្ជីអចលនវត្ថុ ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី" និង លេខ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពី " នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី"។

## ប្រសិទ្ធភាពនិងបញ្ហាប្រឈមក្នុងការចុះបញ្ជីដីធ្លី

ការចុះបញ្ជីដីធ្លី គឺជាផ្នែកដ៏សំខាន់មួយដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ តាមការវិភាគទៅលើសំណាក នៃគ្រួសារប្រកបរបរកសិកម្មបានបង្ហាញថា ហានិភ័យនៃភាពក្រីក្ររបស់គ្រួសារនានានឹងអាចកាត់បន្ថយនៅពេលមានកំណើនលទ្ធភាពនៃការប្រើប្រាស់ដីធ្លី ជាពិសេសនៅពេលដែលមានការធានាកម្មសិទ្ធិតាមរយៈការចេញបណ្ណកម្មសិទ្ធិលើដីធ្លី។ ការវិភាគក៏បានរកឃើញផងដែរថា ក្រៅពីការកែលម្អដីធ្លី ការរៀបចំប្រព័ន្ធស្រោចស្រព និងការផ្តល់

ចំណេះដឹងអំពីការដាំដុះ នៅមានកត្តាអថេរមួយចំនួនទៀតដែលមានឥទ្ធិពលខ្លាំងក្លាដែរលើភាពក្រីក្រ នោះគឺកត្តាសមាសភាពនៃគ្រួសារ និងមុខជំនួញប្រចាំគ្រួសារ។ ដូច្នេះ កំណែទម្រង់ដីធ្លី គប្បីផ្សារភ្ជាប់ជាមួយនឹងកម្មវិធីកំណែទម្រង់ដទៃទៀត ជាពិសេស ខាងផ្នែកកសិកម្មនិងកម្មវិធីបង្កើតមុខរបរ ទើបការកាត់បន្ថយភាពក្រីក្រមានប្រសិទ្ធភាពខ្ពស់។

ក្នុងដំណើរការចុះបញ្ជីដីធ្លី ក្រុមការងារវាលដែលចុះធ្វើអត្តសញ្ញាណកម្មដីនិងម្ចាស់ដីនៅតាមតំបន់វិនិច្ឆ័យ តែងជួបនឹងបញ្ហាប្រឈមមួយចំនួន ជាអាទិ៍៖

- ប្រជាពលរដ្ឋជាម្ចាស់អចលនវត្ថុខ្លះ ខ្វះលិខិតនិង/ឬឯកសារណាមួយផ្សេងៗបញ្ជាក់ភាពជាម្ចាស់ស្របច្បាប់
- ការចូលរួមរបស់អ្នកកាន់កាប់ដីឬស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋនៅមានកម្រិត
- ការដោះស្រាយវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យមានភាពយឺតយ៉ាវ និងច្រើនតែកកស្ទះ
- តំបន់រងទឹកជំនន់នៅជុំវិញបឹងទន្លេសាបនារដូវវស្សាមានភាពមិនច្បាស់លាស់
- ដីចំណីទន្លេ ព្រែក ស្ទឹង បឹងបួរ នៅមិនទាន់បានកំណត់ជាក់លាក់តាមទីតាំងខ្លះ
- ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិជួបនឹងកង្វះសំណុំលិខិតពេញលេញជាមូលដ្ឋានពីសំណាក់ម្ចាស់ចំណែកឯកជន។ល។

## វិធានការពិសេសនៃការចុះបញ្ជីដីធ្លី

នៅខែឧសភាឆ្នាំ២០១២ ប្រឈមនឹងស្ថានភាពមិនច្បាស់លាស់នៃការកាន់កាប់ដីព្រៃនិងទំនាស់ដីធ្លីនៅតាមតំបន់មួយចំនួនរវាងប្រជាជននិងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលធ្វើឱ្យសម្បទានិកមិនអាចអនុវត្តគម្រោងអភិវឌ្ឍរបស់ខ្លួនបានតាមផែនការ ហើយប្រជាជនក៏មានភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់ដីឱ្យអស់ផលិតភាពនៃដី រាជរដ្ឋាភិបាលបានសម្រេចចាត់វិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដោយដាក់ចេញនូវបទបញ្ជាលេខ០១បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ក្នុងគោលដៅអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងរាល់លក្ខខណ្ឌនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច ដោយអនុវត្តតាមនយោបាយរូបមន្តស្បែកខ្លា មិនឱ្យប៉ះពាល់ដីធ្លីសហគមន៍និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី។ នេះជាការពង្រឹងការអនុវត្តគោលនយោបាយនិងបទដ្ឋានគតិយុត្តដែលមានជាធរមានដោយរៀបចំកម្មវិធីនិងសកម្មភាពជាក់ស្តែងសម្រាប់អនុវត្ត។ ក្នុងការអនុវត្តបទបញ្ជាលេខ០១នេះ រាជរដ្ឋាភិបាលបានបង្កើត**គណៈកម្មការត្រួតពិនិត្យការអនុវត្ត នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី** ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដើម្បីត្រួតពិនិត្យនិងផ្តល់មតិជូនប្រមុខរាជរដ្ឋាភិបាលសម្រេចលើសំណើសុំកាត់ដីដែលស្ថិតក្នុងតំបន់ដីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធរខេត្ត ដើម្បីចែកជូនប្រជាជនដែលបានកាន់កាប់ជាក់ស្តែង។ ការអនុវត្តបទបញ្ជាលេខ០១បប គឺជាកំណែទម្រង់ដីធ្លីក្នុងទ្រង់ទ្រាយធំមួយ ដែលត្រូវបានយកចិត្តទុកដាក់ជាពិសេសពីប្រមុខរាជរដ្ឋាភិបាលដោយប្រើប្រាស់គ្រប់មធ្យោបាយនិងលទ្ធភាពកម្លាំងមន្ត្រីជំនាញ ព្រមទាំងកម្លាំងវ័យក្មេងស្ម័គ្រចិត្តក្នុងការធ្វើអត្តសញ្ញាណកម្មដី អត្តសញ្ញាណកម្មអ្នកដែលបានកាន់កាប់និងប្រើប្រាស់

ដីជាក់ស្តែង ដើម្បីសម្រេចកាត់ចេញពីដីរដ្ឋ ធ្វើអនុបយោគតាមករណីនៃក្បាលដីរដ្ឋនីមួយៗ និងធ្វើប្រទានកម្មជូនដល់ប្រជាជនជាអ្នកផលិត។ យុទ្ធនាការកែទម្រង់ដីធ្លីនេះមានវិសាលភាពគ្របដណ្តប់២១ខេត្ត ក្នុងចំណោមរាជធានីខេត្តទាំង២៥។

ទន្ទឹមនឹងយុទ្ធនាការធ្វើប្រទានកម្មដីរដ្ឋដោយការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ដើម្បីផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជនដែលបានកាន់កាប់ ប្រើប្រាស់និងដាំដុះជាក់ស្តែងនារដូវសម្រក នៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើងនៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ រហូតដល់ព្រំប្រទល់ខេត្តកណ្តាល លើកលែងតំបន់លិចទឹកជុំវិញបឹងទន្លេសាប។ ដូច្នេះប្រជាជនដែលបានទទួលបណ្ណកម្មសិទ្ធិ ត្រូវប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីជាកម្មសិទ្ធិរបស់ខ្លួនឱ្យស្របតាមវិធានដីក្នុងទំហំដែលច្បាប់បានកម្រិត។

ក្នុងការអនុវត្តនយោបាយចាស់សកម្មភាពថ្មី ដីរដ្ឋដែលបានឆ្វៀលចេញពីតំបន់សម្បទានដីសេដ្ឋកិច្ច ពីដីសម្បទានព្រៃឈើ ឬពីដីព្រៃដែលមានដីកាដកហូត ដើម្បីធ្វើប្រទានកម្មជូនប្រជាជន ហើយនៅសល់ពីការធ្វើប្រទានកម្មនេះ នឹងត្រូវរក្សាទុកជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬទុកសម្រាប់សហគមន៍ប្រើប្រាស់នៅពេលមានកំណើនប្រជាជននាពេលខាងមុខ។

## ការចុះបញ្ជីក្បាលដីនិងអគារសហកម្មសិទ្ធិ

ដើម្បីគ្រប់គ្រងអគារសហកម្មសិទ្ធិនិងធានាសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់អ្នកកាន់កាប់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ រាល់ចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវធ្វើការចុះបញ្ជី ដោយអនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ។

## គោលការណ៍នៃការអនុវត្តសិទ្ធិរបស់សហកម្មសិទ្ធិករ

ការផ្តល់កម្មសិទ្ធិជូនសហកម្មសិទ្ធិករ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិប៉ុណ្ណោះ ឯចំណែករួមត្រូវរក្សាទុកសម្រាប់ប្រើប្រាស់ជារួមដោយសហកម្មសិទ្ធិករទាំងអស់។ ក្បាលដីដែលសំណង់អគារសហកម្មសិទ្ធិតាំងនៅ ត្រូវចុះបញ្ជីជាក្បាលដីតែមួយនៅរដ្ឋបាលសុរិយោដី។ នៅពេលដែលអ្នកវិនិយោគឬអ្នកអភិវឌ្ឍសំណង់អចលនវត្ថុធ្វើការផ្ទេរលើកដំបូងនៃចំណែកឯកជនណាមួយជូនទៅសហកម្មសិទ្ធិករណាម្នាក់ អ្នកវិនិយោគឬអ្នកអភិវឌ្ឍសំណង់អចលនវត្ថុត្រូវប្តូរប្រភេទក្បាលដីនោះឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ និងត្រូវមានបទបញ្ជាផ្ទៃក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងអគារសហកម្មសិទ្ធិភ្ជាប់ជាមួយ។ បន្ទាប់មក វិនិយោគិនឬអ្នកអភិវឌ្ឍសំណង់អគារសហកម្មសិទ្ធិត្រូវប្រគល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៃក្បាលដីឱ្យទៅរដ្ឋបាលសុរិយោដីធ្វើលេខាចារឹកនិងរក្សាទុក ហើយរដ្ឋបាលសុរិយោដីត្រូវចេញជូនជាជំនួសមកវិញនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិ។ ដូច្នេះមុននឹងប្រកាសលក់ឬជួលចំណែកឯកជននៃអគារសហកម្មសិទ្ធិ អ្នកសាងសង់អគារសហកម្មសិទ្ធិត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយដែលមានចែងអំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករលើចំណែកឯកជននិងលើចំណែករួម ការចាត់ចែងលើចំណែកឯកជន ការគ្រប់គ្រង

អគារសហកម្មសិទ្ធិ និងសមាមាត្រនៃការចំណាយលើការជួសជុល ការថែទាំនិងការចំណាយផ្សេងៗ។ ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុលឬសាងសង់ឡើងវិញ ហើយបន្ទុកនៃចំណាយត្រូវស្របតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ តាមបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ឬតាមការព្រមព្រៀងគ្នាកន្លងមក ជាកិច្ចសន្យាដោយឡែក។

ក្នុងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិក្នុងសៀវភៅគោលបញ្ជី ត្រូវកត់ត្រាទិន្នន័យលម្អិតអំពីចំណែកឯកជននៃអគារសហកម្មសិទ្ធិនិងម្ចាស់កម្មសិទ្ធិ ដែលតម្រូវឱ្យមានការរៀបចំកម្មវិធីកុំព្យូទ័រដោយឡែកសម្រាប់បញ្ចូលទិន្នន័យទាំងនេះ។

## ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ អាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិស្របតាមច្បាប់ជាធរមាន ជាសហកម្មសិទ្ធិពិសេស ចាប់ពីជាន់ទីមួយឡើងទៅ និងមិនឱ្យលើសពីចិតសិបភាគរយ(៧០%)នៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិនីមួយៗ។ សហកម្មសិទ្ធិករពិសេសទទួលបាននូវរាល់សិទ្ធិដូចសហកម្មសិទ្ធិករសញ្ជាតិខ្មែរដែរ លើកលែងតែសិទ្ធិលើដីធ្លីដែលអគារសហកម្មសិទ្ធិតាំងនៅ។ ប៉ុន្តែក្នុងករណីដែលអគារសហកម្មសិទ្ធិរងនូវមហន្តរាយណាមួយ សហកម្មសិទ្ធិករពិសេសក៏មានសិទ្ធិទទួលបាននូវផលប្រយោជន៍ពីសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួម ស្របតាមសមាមាត្រទៅនឹងផ្ទៃក្រឡានៃទំហំចំណែកឯកជនរបស់ខ្លួនឬតាមការព្រមព្រៀងគ្នាពីមុនឬតាមបទបញ្ជាផ្ទៃក្នុង។

## ការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច

ច្បាប់ភូមិបាលឆ្នាំ២០០១ទទួលស្គាល់ដីរបស់ជនជាតិដើមភាគតិចជាដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍។ លក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី ឬគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ឬយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍។ ដូច្នេះ របបកម្មសិទ្ធិសមូហភាពរបស់សហគមន៍មានលក្ខណៈប្លែកពីកម្មសិទ្ធិឯកជន ពីព្រោះក្បាលដីទាំងឡាយរបស់សហគមន៍ មានចំណែកខ្លះជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ។ ផ្អែកលើលក្ខណៈពិសេសនេះ អនុក្រឹត្យលេខ៨៣ អនក្រ បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ក្នុងការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពដែលមាន៖

**ដីឯកជនរបស់រដ្ឋ** ជាដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន(ដីលំនៅឋាន) និងដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី (ដីដាំដុះជាក់ស្តែងនិងដីស្រែចម្ការ)

**ដីសាធារណៈរបស់រដ្ឋ** ជាដីដែលមានការកំណត់ទីតាំង ទំហំ ព្រំប្រទល់ជាក់លាក់ និងសិទ្ធិប្រើប្រាស់ដូចដែលសហគមន៍ធ្លាប់បានអនុវត្តកន្លងមក ដូចជាដីបម្រុងចាំបាច់ក្នុងការដូរ...

វេនដំណាំ ដីព្រៃអារក្សដែលអាចមានមួយឬច្រើនកន្លែងនិងមានទំហំសរុបមិនលើសពី៧ហិកតា និងដីកប់ខ្មោច (ដីបញ្ចុះសព) ដែលមានទំហំសរុបមិនលើសពី៧ហិកតា។

ចំពោះដីរដ្ឋក្រៅពីការរៀបរាប់ខាងលើ ត្រូវចុះបញ្ជីជាដីរដ្ឋឱ្យទៅអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីនោះ ប៉ុន្តែសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិបន្តការប្រើប្រាស់និងអាស្រ័យផលតាមទំនៀមទម្លាប់ប្រពៃណី ដូចដែលពួកគាត់ធ្លាប់អនុវត្តកន្លងមក។ ដីទាំងនោះមានដូចជាដីព្រៃសម្រាប់ប្រមូលអនុផលព្រៃឈើ ដីប្រភពទឹក។ល។

## ៥.១.៣- ការចុះបញ្ជីបន្ត ការធ្វើលេខាចារឹក ការចុះបញ្ជីសិទ្ធិប្រត្យក្ស

ការចុះបញ្ជីបន្តត្រូវអនុវត្តលើរាល់ការផ្ទេរ ការបង្កើត និងការកែប្រែនូវសិទ្ធិប្រត្យក្សដែលហៅថាការធ្វើចរន្តការទិន្នន័យសុរិយោដី។

- ការចុះបញ្ជីផ្ទេរសិទ្ធិប្រត្យក្សអាចធ្វើឡើងដោយ (១) តាមពាក្យសុំរបស់គូភាគី រួមមានកិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាប្រទានកម្ម ការបែងចែកមរតក និង(២) តាមលិខិតផ្ទុកផ្តាក់របស់តុលាការ រួមមាន លិខិតផ្ទុកផ្តាក់ឱ្យផ្ទេរកម្មសិទ្ធិ ផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬផ្ទេរផលុបភោគតាមការលក់ដោយបង្ខំ លិខិតផ្ទុកផ្តាក់ឱ្យផ្ទេរហ៊ីប៉ូតែកឬសិទ្ធិប្រាតិភោគ
- ការកម្រិតចំពោះការចុះបញ្ជីកម្មសិទ្ធិ រួមមាន (១) ការដាក់បន្ទុក ដូចជា ផលុបភោគ សេវភាព សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ការជួលអចិន្ត្រៃយ៍ និងសម្បទានដីសេដ្ឋកិច្ច (២)ការធានាសងបំណុល ដូចជាការដាក់ប្រាតិភោគ ហ៊ីប៉ូតែក ឯកសិទ្ធិ និង(៣) ការផ្ទុកផ្តាក់(ការដាក់បន្ទុក) ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុឬការរឹបអូសជាបណ្តោះអាសន្ន
- ការកែប្រែសិទ្ធិ មានដូចជាការកែប្រែសិទ្ធិកាន់កាប់ឬសិទ្ធិភោគៈមកជាសិទ្ធិកម្មសិទ្ធិ ការកែប្រែពីទ្រព្យរួមឬពីសហកម្មសិទ្ធិឬពីកម្មសិទ្ធិអវិភាគ មកជាកម្មសិទ្ធិឯកត្តជន។

## ការចុះបញ្ជីបន្តលើសម្បទានដីសេដ្ឋកិច្ចឬលើដីជួលអចិន្ត្រៃយ៍

ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ឬការផ្ទេរសិទ្ធិលើសម្បទានដីសេដ្ឋកិច្ចមិនមែនជាការផ្ទេរដីដែលវិនិយោគិនបានទទួលសិទ្ធិជួលឬសិទ្ធិសម្បទានដីពីរដ្ឋនោះឡើយ។ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ចជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីកាន់កាប់និងប្រើប្រាស់ដីតាមលក្ខខណ្ឌជាក់លាក់ក្នុងរយៈពេលមួយជាកំណត់ តាមកិច្ចសន្យាដែលបានបង្កើតសម្បទាននោះ។ សិទ្ធិសម្បទានដីសេដ្ឋកិច្ចឬសិទ្ធិជួលអចិន្ត្រៃយ៍មិនអាចឈានដល់ការបង្កើតនូវសិទ្ធិកម្មសិទ្ធិ លើដីដែលបានផ្តល់ជាសម្បទានឬជួលនោះបានទេ ហើយមានតែអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចហើយ ទើបអាចជាកម្មវត្ថុនៃការធ្វើសម្បទានសេដ្ឋកិច្ចឬការជួលអចិន្ត្រៃយ៍បាន។

តាមមាត្រា៦នៃអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ស្តីពីការដាក់ប្រាតិភោគ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង(ការជួលអចិន្ត្រៃយ៍)ឬសិទ្ធិលើ

សម្បទានដីសេដ្ឋកិច្ច បានចែងកំណត់ថា ... *រាល់ការដាក់បញ្ចាំឬការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង(ការជួលអចិន្ត្រៃយ៍) ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ត្រូវធ្វើលេខាចារឹកនៅលើបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* ហើយមាត្រា៨បានបញ្ជាក់បន្ថែមថា *នៅពេលដែលភតិកៈឬសម្បទានិកស្លាប់ ទាយាទរបស់មតកជន អាចបន្តសិទ្ធិក្នុងកិច្ចសន្យាជួលឬសម្បទានដីបានត្រឹមតែក្នុងរយៈពេលនៃកិច្ចសន្យាជួលឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។ រូបវន្តបុគ្គលឬនីតិបុគ្គលឬក្រុមមនុស្សដែលទទួលការអនុញ្ញាតឱ្យជួលដីពីរដ្ឋ អាចជួលបន្តទៅឱ្យតតិយជនបាន បើមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុន។* ទោះជាយ៉ាងណាក៏សម្បទានិកឬភតិកៈ(អ្នកជួល) មិនអាចក្លាយជាកម្មសិទ្ធិករនិងគ្មានសិទ្ធិទាមទារសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យដែលជួលបន្តនោះបានឡើយ។ ប៉ុន្តែ ម្ចាស់បំណុលមានសិទ្ធិប្តឹងកូនបំណុលដែលបានដាក់ប្រាតិភោគសិទ្ធិសម្បទានបន្តឬសិទ្ធិជួលបន្តទៅតុលាការ ដើម្បីដោះស្រាយស្របតាមច្បាប់និងនីតិវិធីជាធរមាន យកមកសងបំណុលតាមបុព្វសិទ្ធិនិងសិទ្ធិបុរិមាដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ត្រឹមតែក្នុងអំឡុងពេលដែលមានចែងក្នុងកិច្ចសន្យាជួលឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។ ម្ចាស់បំណុលគ្មានសិទ្ធិទាមទារនូវសិទ្ធិចាត់ចែងលើអចលនទ្រព្យដែលកូនបំណុលរបស់ខ្លួនបានទទួលជួលឬសម្បទានពីតតិយជនបានឡើយ។

ការចុះបញ្ជីបន្តជានីតិវិធីចាំបាច់និងត្រូវបង់សេវាសុរិយោដីចូលថវិការដ្ឋ។ ដោយឡែកការចុះបញ្ជីបន្តក្នុងករណីផ្ទេរផ្ទួរ នោះត្រូវបង់សេវាសុរិយោដីនិងបង់ពន្ធប្រថាប់ត្រាថែមទៀត។ ការខកខានមិនបានធ្វើការចុះបញ្ជីបន្តតាមផ្លូវការ នាំឱ្យម្ចាស់សិទ្ធិដែលទទួលកាន់កាប់បន្តមិនអាចចាត់ចែងទ្រព្យនោះក្នុងការជួលឬការដាក់ប្រាតិភោគផ្សេងៗបានឡើយ ពីព្រោះឈ្មោះម្ចាស់ដើមនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី មានសិទ្ធិប្រឆាំងតវ៉ានឹងតតិយជនបាន។

## ការកំណត់ស្តង់ដាក្នុងការផ្តល់សេវាចុះបញ្ជីបន្ត

ការចុះបញ្ជីបន្តឬការធ្វើចរន្តការទិន្នន័យសុរិយោដី មានជាប់ពាក់ព័ន្ធនឹងការបង់ពន្ធផ្សេងៗ ជាពិសេស ពន្ធប្រថាប់ត្រា ការបញ្ជាក់លើលិខិតស្នាមផ្សេងៗដោយអាជ្ញាធរមូលដ្ឋាននិងនីតិវិធីនៃការធ្វើចរន្តការទិន្នន័យសុរិយោដី។ ដើម្បីផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព គណនេយ្យភាព និងនៅជិតប្រជាជន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានរៀបចំការិយាល័យច្រកចេញចូលតែមួយនៅទីស្តីការក្រសួងនិងនៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ដោយមានការបិទផ្សាយជាសាធារណៈនូវតារាងតម្លៃសេវានិងសោហ៊ុយចាំបាច់ផ្សេងៗ ដែលអតិថិជនត្រូវបង់និងរយៈពេលនៃការផ្តល់សេវាជូនអតិថិជន។ ទន្ទឹមនឹងនេះ នៅតាមការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលទ្ធភាពបង្កើតច្រកចេញចូលតែមួយបាន ក៏មានបិទផ្សាយនូវតារាងសេវាជូនសាធារណជនផងដែរ។ ដូច្នេះមន្ត្រីពាក់ព័ន្ធនឹងការងារទាំងនេះនឹងខិតខំអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព និងតាមគោលការណ៍ដែលបានកំណត់។

ចំពោះការធ្វើលេខាចារីកដែលមិនពាក់ព័ន្ធនឹងការបង់ពន្ធដារក៏ត្រូវអនុវត្តគោលការណ៍នៃការផ្តល់សេវាសាធារណៈដោយតម្លាភាពនិងនៅជិតប្រជាជន ដោយមានតារាងកំណត់តម្លៃសេវាទៅតាមទំហំការងារនិងរយៈពេលនៃការសម្រេចការងារ។

## ៥.១.៤- ការបង្កើតបញ្ជីសារពើភណ្ឌអចលនទ្រព្យរបស់រដ្ឋ

ដីរដ្ឋជាធនធានដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដែលរដ្ឋត្រូវមានផែនការគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះឱ្យមានប្រសិទ្ធភាព ផលិតភាព និងតម្លាភាព។ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ រដ្ឋត្រូវមានបញ្ជីសារពើភណ្ឌអចលនទ្រព្យនិងចលនទ្រព្យ។ ចំពោះបញ្ជីសារពើភណ្ឌអចលនទ្រព្យជាដីត្រូវមានផែនទី ប្រព័ន្ធទិន្នន័យដែលបញ្ជាក់ពីទីតាំងនិងព្រំប្រទល់ក្បាលដីនីមួយៗ ស្ថានភាពដី លក្ខណៈធម្មជាតិនៃដី ការប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី ចំណាត់ថ្នាក់ដី និងការកំណត់អាជ្ញាធរ ស្ថាប័នទទួលអាណត្តិគ្រប់គ្រងក្បាលដីរដ្ឋទាំងនោះ។ ព័ត៌មានអំពីទីតាំងដីរដ្ឋមាននៅក្នុងផែនទីនៃក្រសួង ស្ថាប័នជំនាញនានា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវមានព័ត៌មានអំពីអចលនទ្រព្យរបស់រដ្ឋ ដែលយោងទៅរកផែនទីភ្ជាប់នូវទីតាំងអចលនទ្រព្យទាំងនោះ។ ប្រការនេះទាមទារនូវកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីទីតាំងនៃអចលនទ្រព្យរដ្ឋ សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង ការគណនាពន្ធផ្សេងៗនិងការថែរក្សាការពារទ្រព្យសម្បត្តិរដ្ឋ។

ក្រសួងស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋត្រូវជំរុញការចុះបញ្ជីដីរដ្ឋ ដោយផ្តើមចេញពីទីតាំងដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ឬតំបន់ដែលមានផែនការអភិវឌ្ឍស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងតាមស្មារតីនៃអនុក្រឹត្យស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំឬការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។

ដំណើរការចុះបញ្ជីដីរដ្ឋ ដែលស្ថិតនៅក្រោមការណែនាំបច្ចេកទេសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវដឹកនាំប្រតិបត្តិដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ដែលត្រូវអនុវត្តដោយក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ជាដំណើរការមួយមានតម្លាភាព ដោយតម្រូវឱ្យមានការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ទីតាំងព្រំប្រទល់ដីរដ្ឋ និងកត់ត្រានូវរាល់ការតវ៉ាផ្សេងៗរបស់សាធារណជន និងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ទាំងនៅពេលកំពុងធ្វើអត្តសញ្ញាណកម្មដី ទាំងនៅពេលបិទផ្សាយផែនទីទីតាំងនិងព័ត៌មានអំពីដីរដ្ឋ។ ជាចុងក្រោយទិន្នន័យនៃទីតាំងក្បាលដីរដ្ឋដែលក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌបានឯកភាពគ្នា នឹងត្រូវលើកសំណើសុំការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត តាមនីតិវិធី។ នៅពេលនោះ ដីរដ្ឋភាគច្រើននឹងត្រូវបានបញ្ជាក់នូវចំណាត់ថ្នាក់ដំបូងទៅតាមសភាពនៃការប្រើប្រាស់ដីជាក់ស្តែង ដែលក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈក្រុមការងារវាលតាមឃុំ សង្កាត់ បានចុះពិនិត្យនិងស្នើឡើងពីឃុំសង្កាត់នីមួយៗ។ ផែនទីនិងទិន្នន័យដីរដ្ឋដែលប្រមូលបាននឹងផ្តល់ជាការសន្មតមួយអំពីកម្មសិទ្ធិរបស់រដ្ឋ។

កន្លងមក មានតែដីរដ្ឋជាកម្មវត្ថុនៃការធ្វើសម្បទានក្នុងគោលដៅសង្គមកិច្ចទេដែលត្រូវបានចុះបញ្ជីទាំងស្រុងមុននឹងធ្វើការបែងចែក។ ឯដីរដ្ឋដែលផ្តល់ជាសម្បទានសម្រាប់គោលដៅសេដ្ឋកិច្ចវិញ ការចុះបញ្ជីដីអនុវត្តបានតែមួយចំនួនប៉ុណ្ណោះ។ ការចុះបញ្ជីដីរដ្ឋមុននឹងផ្តល់ជាដីសម្បទាន ជាប្រការចាំបាច់ក្នុងការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យាសម្បទានតាមដំណាក់កាលនីមួយៗ និងជាពិសេស នៅពេលដែលទីតាំងដីសម្បទាននោះត្រូវផ្ទេរជូនរដ្ឋវិញនៅពេលចប់កិច្ចសន្យាសម្បទាន។

ក្នុងដំណើរការធ្វើអត្តសញ្ញាណកម្មនិងចុះបញ្ជីដីរដ្ឋ ក្រុមការងារអាចនឹងរកឃើញដីរដ្ឋដែលបាត់បង់ប្រយោជន៍សាធារណៈ ហើយដែលត្រូវធ្វើការចុះបញ្ជីនិងរក្សាទុកបម្រុងសម្រាប់គោលដៅផ្សេងៗនៃតម្រូវការអភិវឌ្ឍផ្នែកសាធារណៈឬសម្រាប់គោលដៅសង្គមកិច្ច។

## ៥.១.៥- ការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការកំណត់ព្រំប្រទល់រដ្ឋបាលជាបណ្តោះអាសន្ននៅឆ្នាំ១៩៧៩ ការធ្វើសមាហរណកម្មតំបន់នានាទូទាំងប្រទេសក្រោយពីការទទួលបានសន្តិភាពពេញលេញឆ្នាំ១៩៩៨ ដោយការអនុវត្តនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាល គួបផ្សំនឹងការអភិវឌ្ឍរីកចម្រើនថ្មីៗរបស់ប្រទេសជាតិ ការរៀបចំព្រំប្រទល់រដ្ឋបាលឡើងវិញតាមតំបន់មួយចំនួនជាការចាំបាច់។ ភាពមិនច្បាស់លាស់នៃដែនយុត្តាធិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើឱ្យការគ្រប់គ្រងមិនបានជិតដល់ល្អ។ ការវិវឌ្ឍឆាប់រហ័សនៃរាជធានី ទីក្រុង ទីប្រជុំជន និងការរីកចម្រើនថ្មីតាមតំបន់ផ្សេងៗនៅជិតទីប្រជុំជន បានធ្វើឱ្យប្រែប្រួលមុខងាររបស់តំបន់ខ្លះ ដែលតម្រូវឱ្យមានការរៀបចំឡើងវិញនូវព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីជាមូលដ្ឋានក្នុងការចុះបញ្ជីដីធ្លី និងការធ្វើផែនការអភិវឌ្ឍនានាឱ្យមានភាពរលូន។

ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចសិក្សាស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់លាស់នូវព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ក្នុងករណីចាំបាច់ ការសិក្សាស្រាវជ្រាវនេះ តម្រូវឱ្យមានការចុះពិនិត្យទីតាំងផ្ទាល់នៅលើដីជាក់ស្តែងនិងផ្ទៀងផ្ទាត់ចំណុចផ្សេងៗនៅលើផែនទី។ ទោះជាយ៉ាងណា ការពិចារណាលើផ្នែកសង្គមកិច្ច សេដ្ឋកិច្ច ប្រពៃណីវប្បធម៌និងសក្តានុពលនៃមូលដ្ឋានដើម្បីតម្រង់ទិសឈានទៅរកភាពម្ចាស់ការដោយខ្លួនឯងរបស់មូលដ្ឋានឃុំ សង្កាត់នីមួយៗ នៅមានកម្រិតនៅឡើយ។ ការកំណត់ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាស្ថាប័នជំនួយផ្នែកបច្ចេកទេស នឹងផលិតផែនទីអរតូហ្វូតូ ខ្នាត១/១០០០០ ជូនដល់ថ្នាក់ក្រោមជាតិដើម្បីជាជំនួយដល់ការពិនិត្យពិភាក្សានិងស្វែងរកការឯកភាពគ្នាលើការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ហើយក្នុងករណីចាំបាច់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវចុះពិនិត្យផ្ទៀងផ្ទាត់លើទីតាំងជាក់ស្តែងជាមួយគ្នា។ ចំពោះតំបន់ដែលនៅជាប់ខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ការកំណត់ព្រំប្រទល់រដ្ឋបាលត្រូវមានការចូលរួមពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

ផែនទីឃុំសង្កាត់ដែលបានឯកភាពគ្នានិងទទួលបានការសម្រេចពីរាជរដ្ឋាភិបាល ត្រូវធ្វើការដាំបង្គោលព្រំប្រទល់នៅលើដី ដើម្បីសម្គាល់ការខណ្ឌចែករដ្ឋបាលនិងចងក្រងជាផែនទីសម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងរដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន ផែនការវិនិយោគសាធារណៈ ផែនការប្រើប្រាស់ដីធ្លី និងការចុះបញ្ជីដីធ្លី។

## ៥.១.៦- ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

យន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការដែលបានបង្កើតឡើងតាមស្មារតីនៃអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ដោយផ្អែកលើមាត្រា៤៧នៃច្បាប់ភូមិបាលឆ្នាំ២០០១ មានបេសកកម្មដោះស្រាយវិវាទដីធ្លីទាក់ទងនឹងអចលនវត្ថុដែលមិនទាន់ចុះបញ្ជីសុរិយោដីនិងវិវាទដីធ្លីស្ថិតក្នុងតំបន់វិនិច្ឆ័យ ដែលគណៈកម្មការរដ្ឋបាលមិនអាចដោះស្រាយបាន។ ដើម្បីបែងចែកសមត្ថកិច្ចឱ្យកាន់តែច្បាស់លាស់ ក្រសួងយុត្តិធម៌និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញប្រកាសអន្តរក្រសួងលេខ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់សមត្ថកិច្ចរបស់តុលាការនិងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ដោយចែងកំណត់ថា វិវាទដីធ្លីដែលកើតមានលើដីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីដែលមានបណ្ណសម្គាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីនិងវិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជាវិវាទអំពីការបែងចែកមរតក អំពីកិច្ចសន្យាទិញលក់ ជួល ប្រាតិភោគជាដើម ជាសមត្ថកិច្ចរបស់ស្ថាប័នតុលាការ។ រីឯវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលមិនទាន់មានបណ្ណសម្គាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី។

### រចនាសម្ព័ន្ធគណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធ៣ថ្នាក់គឺ (១) គណៈកម្មកាសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌដែលដោះស្រាយវិវាទដោយការសម្រុះសម្រួល (២) គណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្តដែលដោះស្រាយវិវាទដោយការសម្រុះសម្រួលនិងធ្វើសេចក្តីសម្រេច និង (៣) គណៈកម្មការសុរិយោដីថ្នាក់ជាតិដែលដោះស្រាយវិវាទដោយធ្វើសេចក្តីសម្រេចនិង/ឬធ្វើការសម្រុះសម្រួលតាមការចាំបាច់។

បុគ្គលគ្រប់រូបដែលមានវិវាទពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី មានសិទ្ធិដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានទីតាំងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងស្រុកខណ្ឌ តាមទម្រង់បែបបទនៃពាក្យបណ្តឹងរបស់គណៈកម្មការសុរិយោដីឬតាមទម្រង់ប្រហាក់ប្រហែល។ គណៈកម្មការសុរិយោដី ក្រោយពីទទួលពាក្យបណ្តឹងនិងធ្វើការស៊ើបអង្កេត ជួបជាមួយភាគីវិវាទ សាក្សី អាជ្ញាធរមូលដ្ឋាននិងធ្វើការវាស់វែងកំណត់ទំហំដីនិងព្រំប្រទល់ដីវិវាទ ដើម្បីពិនិត្យថាតើករណីវិវាទនោះស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនឬយ៉ាងណា។ ករណីមិនស្ថិតក្រោមសមត្ថកិច្ចខ្លួន បណ្តឹងនោះត្រូវច្រានចោលដោយជូនដំណឹងដល់ភាគីវិវាទជាលាយលក្ខណ៍អក្សរ តែភាគីបណ្តឹងអាចប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់លើបាន។

## នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី ធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ ដោយយកការសម្រុះសម្រួលជាមូលដ្ឋាន យកឆន្ទៈរបស់គូភាគីវិវាទដែលសុខចិត្តចែករំលែកផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ដូច្នេះបើការដោះស្រាយទទួលបានជោគជ័យ ភាគីទាំងពីរត្រូវផ្តិតមេដៃលើទម្រង់បែបបទបញ្ចប់វិវាទតាមខ្លឹមសារដែលបានព្រមព្រៀង។ ប្រសិនបើមិនអាចធ្វើការដោះស្រាយបាន គណៈកម្មការសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌនឹងបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត ដែលនឹងធ្វើការសម្រុះសម្រួលបន្តនិងធ្វើសេចក្តីសម្រេច។ ក្នុងករណីដែលភាគីវិវាទមិនសុខចិត្តចំពោះការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ភាគីវិវាទមានសិទ្ធិដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលនឹងព្យាយាមធ្វើការសម្រុះសម្រួលបន្តទៀតតាមនីតិវិធីកំណត់។ ប៉ុន្តែបើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងបើកសវនាការសម្រេច ដោយបើកផ្លូវឱ្យគូភាគីអាចដាក់ពាក្យបណ្តឹងទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបានទទួលសេចក្តីសម្រេច។

ក្រោយពីវិវាទត្រូវបានដោះស្រាយបញ្ចប់នៅថ្នាក់ណាមួយ អ្នកដោះស្រាយនឹងចុះធ្វើការវាស់វែងកំណត់ទំហំដី និងព្រំប្រទល់តាមការព្រមព្រៀងគ្នា ឬតាមសេចក្តីសម្រេចស្ថាពររបស់គណៈកម្មការសុរិយោដី ហើយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌនឹងអនុវត្តនីតិវិធីចុះបញ្ជីក្បាលដី តាមការស្នើសុំរបស់ភាគីវិវាទ។

ក្នុងគោលដៅពន្លឿនការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋ តាំងពីឆ្នាំ២០០៧មក គណៈកម្មការសុរិយោដីថ្នាក់ជាតិបានបង្កើតក្រុមចល័តដោះស្រាយវិវាទដីធ្លីចុះជួយគណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្តមួយចំនួនដែលមានករណីវិវាទដីធ្លីកកស្ទះច្រើន។ ម្យ៉ាងទៀត ក្នុងការដោះស្រាយទំនាស់ជាលក្ខណៈពហុភាគីដែលជាទំនាស់មានភាពស្មុគ្រស្មាញ រាជរដ្ឋាភិបាលបានសម្រេចបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក្នុងបំណងពង្រឹងការងារដោះស្រាយទំនាស់ឱ្យកាន់តែមានប្រសិទ្ធភាព។

### ៥.១.៧- ប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដីនិងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ

សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល ឆ្នាំ២០០៩ បានចែងតម្រូវឱ្យមានការគ្រប់គ្រងការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាពនិងចីរភាព។ ការរៀបចំប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដីគឺជាមធ្យោបាយគន្លឹះនៃទិន្នន័យសុរិយោដីបម្រើពហុគោលបំណងដែលជាមូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ (NSDI)។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិនឹងធ្វើឱ្យព័ត៌មានអំពីដីធ្លីងាយស្រួលក្នុងការស្វែងរក មានតម្លៃទាប និងជាឧបករណ៍សម្រាប់ការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព។

#### ការរៀបចំប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដី(Parcel Based-LIS)

ប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដី ត្រូវចាប់ផ្តើមពីការធ្វើសមាហរណកម្មព័ត៌មានទាំងឡាយទាក់ទងនឹងដីធ្លីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដោយប្រើទិន្នន័យ

សុរិយោដីដែលមានស្រាប់ និងធ្វើសមាហរណកម្មព័ត៌មានផ្សេងៗទៀតអំពីដីធ្លីរបស់ក្រសួង។ ក្នុងដំណើរការធ្វើសមាហរណកម្មព័ត៌មាន ចាំបាច់ត្រូវមានការប្រើប្រាស់ដាទុម (Datum) មួយឯកភាពគ្នាក្នុងការកំណត់ទីតាំងនីមួយៗនិងរៀបចំឱ្យមានបទដ្ឋានគតិយុត្ត ស្តង់ដាបច្ចេកទេស ធនធានមនុស្ស និងសកម្មភាពចាំបាច់ផ្សេងទៀតក្នុងការប្រើប្រាស់ ការចែករំលែក ការថែទាំ និងការរក្សាទុកទិន្នន័យ។ ព័ត៌មានអំពីក្បាលដីដែលបានចុះបញ្ជីរួចហើយ ជាព័ត៌មានលម្អិត និងមានធ្វើចរន្តការជាប្រចាំ និងមានផែនទីបង្ហាញប្លង់សុរិយោដីក្នុងសៀវភៅគោលបញ្ជី។

ការអភិវឌ្ឍប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដី មិនប៉ះពាល់ដល់ការទទួលខុសត្រូវរបស់អាជ្ញាធរណាមួយក្នុងការប្រមូលឬផលិតទិន្នន័យអំពីដីធ្លីឡើយ។ អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ បានរៀបចំប្រព័ន្ធទិន្នន័យផ្អែកលើក្បាលដី សម្រាប់ជាគ្រឹះនៃទិន្នន័យសុរិយោដីបម្រើពហុគោលបំណង។ បញ្ហាចំពោះមុខគឺ ការជ្រើសសម្រាំងទិន្នន័យសុរិយោដីសម្រាប់ការដាក់បញ្ចូលគ្នាជាមួយទិន្នន័យផ្សេងៗទៀតដែលមានតម្លៃខាងផ្លូវច្បាប់មិនដូចគ្នា។ ទិន្នន័យសុរិយោដីជាព័ត៌មានផ្លូវការ បានមកពីការប្រមូលទិន្នន័យនៃការវាស់វែងក្បាលដីតាមបច្ចេកទេសទំនើប មាននិយាមកាភ្ជាប់ទៅនឹងដាទុម (Datum) តាមទិន្នន័យយោងឆ្នាំ២០០៣ ដែលផ្អែកលើដាទុមសកលឆ្នាំ១៩៨៤ (World Geodetic System 1984-WGS 84)។ ការងារនេះនឹងត្រូវបន្តអភិវឌ្ឍរហូតសម្រេចបានជាទិន្នន័យសុរិយោដីបម្រើពហុគោលបំណង។

### ការរៀបចំទិន្នន័យសុរិយោដីបម្រើពហុគោលបំណង

ការធ្វើសមាហរណកម្មទិន្នន័យសុរិយោដីជាមួយនឹងព័ត៌មានផ្សេងៗទៀតអំពីដីធ្លី ដូចជាទិន្នន័យនៃផែនការរៀបចំដែនដី ផែនការប្រើប្រាស់ដី ការវាយតម្លៃថ្លៃដី ផែនទីឋានលេខា ទិន្នន័យភូមិសាស្ត្រ ទិន្នន័យប្រជាសាស្ត្រ បណ្តាញគមនាគមន៍ ទីតាំងតំបន់ទេសចរណ៍ ព្រំប្រទល់រដ្ឋបាល បណ្តាញប្រថពីវិភាគ នោះប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដីនឹងក្លាយជាមូលដ្ឋានទិន្នន័យសុរិយោដីបម្រើពហុគោលបំណង។ ករណីនេះ ចាំបាច់ត្រូវជ្រើសសម្រាំងនិងផ្ទេរទិន្នន័យសុរិយោដីទៅក្នុងប្រព័ន្ធមួយទៀត ដើម្បីដាក់បញ្ចូលជាមួយទិន្នន័យផ្សេងៗជាមួយគ្នាឱ្យក្លាយជា "**ទិន្នន័យសុរិយោដីបម្រើពហុគោលបំណង**" សម្រាប់ចែករំលែកព័ត៌មានអំពីដីធ្លីនេះដល់អាជ្ញាធរ បុគ្គលឯកជន ក្រុមហ៊ុន និងស្ថាប័នផ្សេងៗ និងរៀបចំឱ្យមានមេតាទិន្នន័យ (Metadata) សម្រាប់ការប្រើប្រាស់ទិន្នន័យតាមផ្នែក។

ការបង្កើតប្រព័ន្ធព័ត៌មានដីធ្លីមិនត្រូវគិតគូរតែលើផ្នែកបច្ចេកវិទ្យាមួយមុខឡើយ គឺត្រូវផ្អែកលើសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ដែលអាចផ្តល់លទ្ធភាពក្នុងការរកចំណូលជាកម្រៃលើសេវាប្រើប្រាស់។ ចំណូលទាំងនេះ ត្រូវផ្តល់ជូនដល់អាជ្ញាធរដែលជាអ្នកផលិតទិន្នន័យ គឺមិនមែនជូនតែអ្នកទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធទិន្នន័យនោះទេ។ ដូច្នេះ ត្រូវមានការកំណត់ច្បាស់លាស់នូវបទដ្ឋានសម្រាប់ការចែករំលែកទិន្នន័យ តម្លៃសេវាមើលទិន្នន័យ ទាញយកទិន្នន័យ បំប្លែងទិន្នន័យ និងគោលការណ៍ស្តីពីការប្រមូលតម្លៃសេវាប្រើប្រាស់ទិន្នន័យ។ល។

### ៥.១.៨- ការធ្វើចំណាត់ថ្នាក់ប្រភេទដីតាមលក្ខណៈធម្មជាតិនៃដី

នៅប្រទេសកម្ពុជា ធនធានដីជាងពាក់កណ្តាលមានជីជាតិតិចនិងប្រែប្រួលខុសៗគ្នា។ ភាគច្រើននៃដីមានជីជាតិខ្ពស់និងមធ្យម ប្រមូលផ្តុំក្នុងតំបន់ទំនាបកណ្តាល។ ការសិក្សាស្រាវជ្រាវ

ស៊ីជម្រៅដើម្បីកំណត់ប្រភេទដីតាមលក្ខណៈធម្មជាតិនៃដី នៅពុំទាន់បានធ្វើនៅឡើយ ហើយដីដែលមានសក្តានុពលកសិកម្មមួយចំនួនកំពុងប្រឈមនឹងការផ្ទេរទៅប្រើប្រាស់ផ្សេង និងទទួលបានការការពារថែរក្សាតិចតួច។ ការប្រមូលទិន្នន័យកសិកម្មទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គមនិងបរិស្ថានដើម្បីកំណត់ផលិតភាពដី ការបង្កើតលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើចំណាត់ថ្នាក់ប្រភេទដី ការកំណត់ព្រំដែនតំបន់ដីកសិកម្មនិងការបង្កើតជាផែនទីប្រើប្រាស់ដីនិងអភិវឌ្ឍដីគឺជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើផែនការប្រើប្រាស់ដី។ ដូច្នេះ ត្រូវមានការសិក្សាផ្អែកធរណីសាស្ត្រពាក់ព័ន្ធនឹងការកកើត ការវិវឌ្ឍប្រែប្រួលផ្ទៃលើរបស់ដីនៅតាមតំបន់ផ្សេងៗនិងកម្រិតសារធាតុល្បាយរបស់ដី ដើម្បីកំណត់គុណភាពដីនិងប្រភេទដំណាំ រុក្ខជាតិឱ្យបានសមស្រប។ ការកំណត់គុណភាពដីត្រូវផ្អែកលើវាយនភាពដី ដីមានជាតិជូរ ដីប្រៃ ដីមានសមាសភាពកាបូន អាសូត ការបញ្ចេញហ្វូសហ្វាត ការផ្លាស់ប្តូរកាចុងនិងសមាសភាពមីក្រូធាតុផ្សេងៗទៀត។ ការធ្វើចំណាត់ថ្នាក់ប្រភេទដីមិនគ្រាន់តែជួយដល់ការប្រើប្រាស់ដីឱ្យបានស្របតាមសក្តានុពលរបស់ដីប៉ុណ្ណោះទេ តែវានឹងរួមចំណែកដល់ការលើកកម្ពស់ជីវភាពប្រជាជន ការកំណត់ពន្ធដារលើដីធ្លីប្រកបដោយសមធម៌ និងអាចជួយដល់ការអនុវត្តនយោបាយកំណត់ភូមិមួយ ផលិតផលមួយផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនឹងជំរុញការធ្វើចំណាត់ថ្នាក់ប្រភទដីតាមលក្ខណៈធម្មជាតិនៃដី ដោយមានការចូលរួមពីស្ថាប័ននិងអ្នកជំនាញពាក់ព័ន្ធក្នុងការរៀបចំបទដ្ឋានគតិយុត្តដែលផ្អែកលើការសិក្សាស្រាវជ្រាវនិងបទពិសោធនៃមន្ត្រីជំនាញ។

## ៥.២- អនុវិស័យរៀបចំដែនដី

បច្ចុប្បន្ន ចំនួនប្រជាជនមានការកើនឡើងជាលំដាប់ ទាំងនៅទីក្រុង ទាំងនៅទីជនបទដែលទាមទារឱ្យមានការរៀបចំតម្រង់ទិសការរៀបចំដែនដី ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍគ្រប់វិស័យលើផ្នែករូបវន្ត សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ កិច្ចការរៀបចំដែនដីគឺជាមូលដ្ឋានដ៏សំខាន់គាំទ្រដល់ការអភិវឌ្ឍ ដែលការងារនេះតម្រូវឱ្យមានការសម្របសម្រួលផែនការនៃវិស័យពាក់ព័ន្ធ ដើម្បីស្វែងរកការឯកភាពគ្នាក្នុងការគ្រប់គ្រង ការប្រើប្រាស់និងការអភិវឌ្ឍដី។

### គោលនយោបាយរៀបចំដែនដី

គោលដៅនៃការរៀបចំដែនដីគឺសំដៅធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដីនិងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាននិងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយសមធម៌និងបរិយាបន្ន នៅទីប្រជុំជននិងជនបទ ព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដីដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដី ឬការប្តូរប្រភេទនៃការប្រើប្រាស់ដី។

ការរៀបចំដែនដី គឺការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រនៃការរៀបចំដែនដីជាមួយនឹងវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យឱ្យមានភាពរលូននៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ចៀសវាងនូវការខ្វែងគំនិតយោបល់គ្នាក្នុងការប្រើប្រាស់ដីនិងធនធានធម្មជាតិ ក្នុងគោលដៅធានាដល់សន្តិសុខស្បៀង កិច្ចការពារជាតិនិងរក្សាលំនឹងបរិស្ថានធម្មជាតិ ព្រមទាំង

តម្រង់ទិសដល់ការអភិវឌ្ឍឱ្យមានតុល្យភាពលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមានភាពងាយស្រួលដល់ទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។ ក្នុងន័យនេះ ផែនការអភិវឌ្ឍដីគប្បីគិតគូរដល់ការផ្គត់ផ្គង់សេចក្តីត្រូវការដី ការកំណត់តំបន់ប្រើប្រាស់ដីសម្រាប់អភិវឌ្ឍទៅតាមអំណោយផលធម្មជាតិនៃដី ការធ្វើឱ្យប្រសើរឡើងនូវលក្ខណៈភូមិសាស្ត្រដោយឡែកៗ ការលើកកម្ពស់កម្រិតជីវភាពប្រជាជន ការកាត់បន្ថយនូវគម្លាតរវាងតំបន់ផ្សេងៗ និងបន្សុីផែនការប្រើប្រាស់ដីក្នុងតំបន់ឱ្យស្របទៅនឹងការរៀបចំដែនដីទូទាំងប្រទេស ដោយពិចារណាអំពីលក្ខខណ្ឌនិងកត្តាតម្រូវនៃតំបន់ជាក់លាក់នីមួយៗ។

ក្នុងការធ្វើផែនការរៀបចំទីប្រជុំជនឬតំបន់ជនបទ ចាំបាច់ត្រូវគិតគូរទុកជាមុននូវដីបម្រុងទុកសម្រាប់តម្រូវការនៃការអភិវឌ្ឍផ្នែកសាធារណៈ ឬការប្រើប្រាស់ផ្សេងទៀតនៃទីក្រុងឬឃុំសង្កាត់នៅពេលខាងមុខ ជាពិសេស សម្រាប់បណ្តាញគមនាគមន៍ និងតម្រូវការហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ឬដំណោះស្រាយបញ្ហាលំនៅឋាន។

## យុទ្ធសាស្ត្រនៃការរៀបចំដែនដី

ដើម្បីឱ្យផែនការរៀបចំដែនដីអាចអនុវត្តបានដោយរលូន និងអាចកាត់បន្ថយនូវរាល់ហានិភ័យដែលបណ្តាលមកពីគម្រោងផែនការអភិវឌ្ឍផ្សេងៗ ការធ្វើផែនការរៀបចំដែនដីនិងផែនការប្រើប្រាស់ដី ព្រមទាំងការអភិវឌ្ឍលំនៅឋានត្រូវផ្សារភ្ជាប់នឹងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចជាពិសេស តំបន់ឧស្សាហកម្ម ដើម្បីរួមចំណែកដល់ការធ្វើឱ្យមានតុល្យភាពនៃរបាយប្រជាជនទូទាំងប្រទេសនិងសមធម៌នៃការទទួលបានផលពីការអភិវឌ្ឍសេដ្ឋកិច្ច។ ជាមួយនេះ ក៏ត្រូវគិតគូរដល់រចនាសម្ព័ន្ធសេដ្ឋកិច្ចមួយប្រកបដោយតុល្យភាព ដែលអាចធានាដល់ការអភិវឌ្ឍរយៈពេលវែងក្នុងបរិបទនៃសកលភាវូបនីយកម្ម និងផ្តល់កាលានុវត្តភាពដល់ការបណ្តុះបណ្តាលនិងការងារធ្វើដល់ប្រជាពលរដ្ឋ ដើម្បីចៀសវាងចលនាបម្លាស់ទីរបស់ប្រជាពលរដ្ឋក្នុងការបំពេញការងារ ឬការស្វែងរកការងារដែលនៅឆ្ងាយពីលំនៅឋាន។ ដូច្នេះ ការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ចត្រូវគិតគូរដល់ពាក្យស្លោក"បញ្ជូនការងារទៅដល់ប្រជាជន" និងការផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍលំនៅឋានដើម្បីអាចកាត់បន្ថយការចំណាយលើការធ្វើដំណើរ ឬបង្កើតការងារធ្វើនៅនឹងមូលដ្ឋាន ដែលរួមចំណែកកាត់បន្ថយគម្លាតនៃបរិយាកាសរស់នៅពីតំបន់មួយទៅតំបន់មួយទៀត។

វិធានការសំខាន់ផ្នែកសេដ្ឋកិច្ច គឺការប្រើប្រាស់ឱ្យបានសមស្របនូវសក្តានុពលនៃប្រភេទធនធានធម្មជាតិ ដើម្បីបម្រើដល់ការអភិវឌ្ឍវិស័យកសិកម្ម រ៉ែ ឧស្សាហកម្ម ថាមពល ពាណិជ្ជកម្ម ធុរកិច្ច សេដ្ឋកិច្ចជាតិ និងទេសចរណ៍ស្របទៅនឹងទីតាំងនីមួយៗ។ លក្ខខណ្ឌសមស្របនិងការធ្វើអាជីវកម្មលើធនធានប្រេង ឧស្ម័នធម្មជាតិ និងធនធានរ៉ែផ្សេងទៀតត្រូវធានាឱ្យមានផលប៉ះពាល់បរិស្ថានតិចបំផុត និងគ្រប់គ្រងឱ្យមាននិរន្តរភាព។ ប្រឈមនឹងសភាពការណ៍ប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន ការរៀបចំដែនដីនិងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិជាបញ្ហាសំខាន់ចំពោះមុខក្នុងការអនុវត្តផែនការ ដែលស្ថាប័នពាក់ព័ន្ធបានសិក្សានិងមានយោបល់ស្របគ្នាលើផែនការយុទ្ធសាស្ត្រនៃការគ្រប់គ្រង និងការតម្រង់ទិសដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

### ៥.២.១- គោលការណ៍នៃការរៀបចំដែនដី

ការរៀបចំដែនដីជាការងារមានលក្ខណៈអន្តរវិស័យ មានអន្តរកម្មជាមួយគ្រប់ផ្នែក។ ដូច្នេះ ដំណើរការរៀបចំដែនដីតម្រូវឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនិងមូលដ្ឋាន តាំងពីការចាប់ផ្ដើមការងារ។ ទិន្នន័យដែលមានស្រាប់របស់មូលដ្ឋាន ត្រូវរៀបចំជារបាយការណ៍សង្ខេបនិងធ្វើជាផែនទីគោលបង្ហាញដល់អ្នកចូលរួម គួបផ្សំនឹងការវិភាគប្រកបដោយជវភាព (វិភាគឌីណាមិក)នៃបញ្ហាគ្រប់គ្រងដីធ្លី ដូចជាការវិភាគប្រជាសាស្ត្រ និន្នាការនៃកំណើនប្រជាជន និន្នាការនៃការប្រែប្រួលនៅតាមទីតាំងនានានិងទស្សនវិស័យសម្រាប់អនាគត លទ្ធភាពផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ការការពារវប្បធម៌ ការថែរក្សាធនធានធម្មជាតិ ដើម្បីជាមូលដ្ឋានពិចារណារបស់អ្នកពាក់ព័ន្ធក្នុងការកំណត់ជម្រើស (សេណារីយ៉ោ) និងទស្សនវិស័យសម្រាប់អនាគត ការបង្កើតយុទ្ធសាស្ត្រ និងការត្រួតពិនិត្យវាយតម្លៃ។

គោលការណ៍នៃការរៀបចំដែនដី គឺធ្វើឱ្យសម្រេចប្រកបដោយប្រសិទ្ធភាពនិងសមធម៌នូវការអភិវឌ្ឍនិងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃជីវភាពរស់នៅរបស់ប្រជាជន។ដូច្នេះ ដំណើរការរៀបចំដែនដីត្រូវគោរពនូវគោលការណ៍៖

- ការចូលរួមធ្វើផែនការពីគ្រប់អ្នកពាក់ព័ន្ធនិងការលើកកម្ពស់ការស្រុះស្រួលគ្នា
- ការអនុវត្តគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- ការឯកភាពគ្នាលើឋានានុក្រមនៃផែនការនិងវិធីសាស្ត្រធ្វើផែនការ
- ការគោរពលក្ខណៈទ្វេទិសពីក្រោមទៅលើនិងពីលើទៅក្រោមនូវរាល់ការសម្រេចចិត្ត
- ការធ្វើសមាហរណកម្មគ្រប់កម្រិតថ្នាក់ គ្រប់វិស័យនិងតំបន់ភូមិសាស្ត្រពាក់ព័ន្ធ
- ការរក្សាតុល្យភាពរវាងការអភិវឌ្ឍនិងការបែងចែកផលដែលទទួលបានដល់គ្រប់តំបន់
- ការផ្ដល់អាទិភាពដល់ផែនការអភិវឌ្ឍន៍តំបន់ងាយរងគ្រោះឬដែលអាចរងគ្រោះឱ្យបានទាន់ពេលវេលានិងដោយប្រុងប្រយ័ត្ន។

### ៥.២.២- ឧបករណ៍នៃការរៀបចំដែនដី

ផ្អែកលើរូបថតពីលើអាកាសនៃទីតាំងភូមិសាស្ត្រដែលជាកម្មវត្ថុនៃការធ្វើផែនការរៀបចំដែនដី និងសម្រង់ព័ត៌មានទាក់ទងនឹងស្ថានភាពនៃការកាន់កាប់និងការប្រើប្រាស់ដីជាក់ស្ដែង ការរៀបចំដែនដីគប្បីពិចារណាលើលក្ខណៈនៃអេកូឡូស៊ី សេចក្ដីត្រូវការផ្នែកសង្គមនិងសេដ្ឋកិច្ចរបស់មូលដ្ឋាន លើនិន្នាការនៃការអភិវឌ្ឍគ្រប់វិស័យក្នុងរយៈពេលមធ្យមនិងវែង និងផលចំណេញដែលមូលដ្ឋានអាចទទួលបានពីការអនុវត្តផែនការ។

ការរៀបចំដែនដីត្រូវធ្វើឡើងក្នុងក្របខណ្ឌទូទាំងប្រទេសដើម្បីធានានូវចីរភាព សមធម៌ តុល្យភាព និងការធ្វើសមាហរណកម្មទាំងក្នុងប្រទេស ក្នុងតំបន់ និងក្នុងក្របខ័ណ្ឌអន្តរជាតិ។ ដោយធនធានមានកំណត់ ការរៀបចំដែនដីត្រូវធ្វើទៅតាមលំដាប់អាទិភាព ជាពិសេសតំបន់ដែលមានកំណើនប្រជាជននិង/ឬកំណើនសេដ្ឋកិច្ចខ្ពស់។ ការងារនេះជាភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអ្វីដែលរដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចធ្វើបាន ត្រូវស្នើសុំការគាំទ្រពីថ្នាក់ជាតិ។

### ៥.២.៣- ឋានានុក្រមនៃផែនការរៀបចំដែនដី

ស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនិងផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ សមត្ថកិច្ចក្នុងការផ្តួចផ្តើមរៀបចំការសម្របសម្រួលនិងការសម្រេចលើផែនការរៀបចំដែនដី មាន៤កម្រិតថ្នាក់រដ្ឋបាលគឺះ

**ក- ផែនការរៀបចំដែនដីថ្នាក់ជាតិនិងតាមតំបន់** ផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដែលដឹកនាំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំ និងសម្រេចដោយព្រះរាជក្រឹត្យ ហើយអាចធ្វើការកែសម្រួលក្រោយរយៈពេល១០(ដប់)ឆ្នាំម្តងតាមសំណើរបស់រាជរដ្ឋាភិបាល លើកលែងតែមានការចាំបាច់ទើបអាចធ្វើការកែសម្រួលមុនរយៈពេលនេះ។

**ខ- នៅថ្នាក់រាជធានី ខេត្ត** មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីសម្រាប់រាជធានីហើយនៅថ្នាក់ខេត្តមានតែផែនការរៀបចំដែនដីថ្នាក់ខេត្ត។ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្តជាអ្នកផ្តួចផ្តើមរៀបចំការងារទាំងនេះដោយមានការឯកភាពពីក្រុមប្រឹក្សារាជធានី ខេត្ត។ ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីថ្នាក់រាជធានីនិងផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំ អាចធ្វើការកែសម្រួលក្នុងរយៈពេល៥ឆ្នាំម្តង និងត្រូវសម្រេចដោយអនុក្រឹត្យ បន្ទាប់ពីការយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**គ- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ** មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងហើយនៅថ្នាក់ស្រុកខណ្ឌមានតែប្លង់គោលប្រើប្រាស់ដីប៉ុណ្ណោះ។ ការផ្តួចផ្តើមការងារទាំងនេះត្រូវផ្តើមចេញពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌដែលមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥ឆ្នាំម្តង ដោយមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការយល់ព្រមពីក្រុមប្រឹក្សារាជធានីខេត្តតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានីខេត្ត និងត្រូវសម្រេចដោយគណៈកម្មាធិការរៀបចំទឹកដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

**ឃ- នៅថ្នាក់ឃុំ សង្កាត់** ផែនការប្រើប្រាស់ដីត្រូវផ្តួចផ្តើមរៀបចំដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការសម្របសម្រួលនិងគាំទ្របច្ចេកទេសពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានចក្ខុវិស័យសម្រាប់រយៈពេលពី១០ទៅ១៥ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥ឆ្នាំម្តងតាមការចាំបាច់។ ផែនការប្រើប្រាស់ដីឃុំ សង្កាត់ត្រូវមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការសម្រេចពីក្រុមប្រឹក្សារាជធានីខេត្តតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ស្របតាមស្មារតីនៃអនុក្រឹត្យលេខ៧២ស្តីពីផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់។

### ៥.២.៤- ការអភិវឌ្ឍបញ្ញត្តិនគរូបនីយកម្មនិងសំណង់នៅទីក្រុង

ដើម្បីរក្សាតុល្យភាពរវាងការពង្រីកក្រុងទៅលើតំបន់ជនបទ និន្នាការនៃការពង្រីកទីក្រុងដែលពុំមានផែនការច្បាស់លាស់ គួរតែបញ្ឈប់។ ការពង្រីកទីក្រុងត្រូវមានទស្សនាទាននៃការ

ធ្វើសមាហរណកម្មទីក្រុងជាមួយនឹងជនបទ ដើម្បីកាត់បន្ថយអតុល្យភាពនៃសក្តានុពលដែលមានរួចហើយ។ មុខងារសំខាន់របស់តំបន់ទីក្រុងគឺការរៀបចំជាមជ្ឈមណ្ឌលរដ្ឋបាល ការស្នាក់នៅ ការផលិត ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍។ល។ ដែលត្រូវគិតគូរដោះស្រាយជាចម្បងនូវទំនោរនៃភាពកកស្ទះ និងលទ្ធភាពនៃការអភិវឌ្ឍតាមរយៈការបង្កើតប្រព័ន្ធទីក្រុងផ្សារភ្ជាប់គ្នាដោយបណ្តាញគមនាគមន៍គ្រប់ប្រភេទ។ ក្នុងន័យនេះ ត្រូវរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងដើម្បីតម្រង់ទិសនៃការអភិវឌ្ឍឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើនប្រជាជន។ ការអភិវឌ្ឍទីក្រុងទាមទារឱ្យមានប្លង់គោលប្រើប្រាស់ដី ដែលជាផែនការរូបវន្តកំណត់នូវចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍ និងត្រូវមានផែនការប្រើប្រាស់ដីដែលកំណត់អំពីការបែងចែកតំបន់ប្រើប្រាស់ដីតាមទីតាំងនីមួយៗ ប្លង់លម្អិតតំបន់នៃការរៀបចំទៅតាមគោលបំណងរបស់សហគមន៍ និងបញ្ញត្តិនៃទម្រង់និងរូបរាងសំណង់ ផ្លូវលម្អ ផ្លូវបៃតង ការដាក់ស្លាកសញ្ញាផ្សេងៗ។

វិធានការនៃការរៀបចំដែនដីនៅទីក្រុងនិងទីប្រជុំជនក៏ត្រូវពិចារណាលើទិដ្ឋភាពនៃសមធម៌សង្គម ជាអាទិ៍ តម្រូវការខាងលំនៅឋានសមស្របនិងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រនិងអ្នកមានប្រាក់ចំណូលទាបអាចរកបាន និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋនិងផ្នែកឯកជន។ ផែនការអភិវឌ្ឍទីក្រុង ក្រៅពីផ្តល់ការងារធ្វើ ត្រូវគិតគូរជាអាទិភាពដល់ការរៀបចំកន្លែងសម្រាកលំហែសាធារណៈ ធានាបាននូវការរស់នៅប្រកបដោយគុណភាព សុវត្ថិភាព បរិស្ថានល្អនិងសោភ័ណភាព ព្រមទាំងកំណត់តំបន់គ្រប់គ្រងពិសេសសម្រាប់រៀបចំខ្សែក្រវាត់បៃតងក្រុង។ល។

ក្នុងផែនការនគរូបនីយកម្ម ត្រូវកំណត់ការប្រើប្រាស់ដីនិងការអភិវឌ្ឍដីឱ្យចំទិសដៅនិងមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បរិក្ខារសាធារណៈ លម្ហសាធារណៈគ្រប់គ្រាន់ស្របតាមបទដ្ឋានបច្ចេកទេស។ ការប្រើប្រាស់ដី ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃនគរូបនីយកម្ម ដែលបានបែងចែកជាតំបន់កម្រិតការសាងសង់ និងតំបន់អនុញ្ញាតការសាងសង់។ ឯសន្ទស្សន៍នៃការប្រើប្រាស់ដី (ផលធៀបរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបទៅនឹងផ្ទៃដី) ក៏ត្រូវគិតគូរទៅតាមតំបន់កំណត់ប្រភេទសំណង់ ដើម្បីធានានូវបរិយាកាសនៃតំបន់សម្រាប់សុខុមាលភាពសង្គម។

ជារួម ផែនការនគរូបនីយកម្មត្រូវឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់មនុស្សដោយត្រូវពិចារណាលើទិដ្ឋភាពទាំងឡាយ ជាអាទិ៍ កន្លែងលំហែកាយ កន្លែងកម្សាន្ត កន្លែងសម្រាប់លេងកីឡា ទីកន្លែងសារធារណៈ មជ្ឈមណ្ឌលវប្បធម៌និងសាសនា និងការផ្តល់សុខុមាលភាពដល់មនុស្សគ្រប់វ័យ(កុមារ យុវជន ស្ត្រី បុរស មនុស្សចាស់ ជនពិការ) រួមទាំងលទ្ធភាពទទួលបាននូវសេវាសុខភាព អប់រំ។ល។

## ៥.២.៥- ការអភិវឌ្ឍបញ្ញត្តិតំបន់ជនបទនិងការកែប្រែប្រភេទប្រើប្រាស់ដី

ការចិញ្ចឹមជីវិតរបស់ប្រជាជនភាគច្រើននៅជនបទ ជាពិសេស ប្រជាជនក្រីក្រពឹងអាស្រ័យលើសុវត្ថិភាពនិងសមធម៌នៃការទទួលបានដីធ្លី ដែលជាប្រភពនៃស្បៀងអាហារនិងការស្នាក់នៅ និងជាមូលដ្ឋាននៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌និងសាសនា។ ដូច្នេះការរៀបចំដែនដីគួរយកចិត្តទុកដាក់រក្សាលំនឹង និងអភិវឌ្ឍសក្តានុពលរបស់ជនបទ ដើម្បីពង្រឹង

ឱ្យមានភាពឯករាជ្យ ជាតំបន់ស្នាក់នៅ តំបន់សម្បទានដីសង្គមកិច្ចនិងសម្បទានដីសេដ្ឋកិច្ច។ ក្នុងន័យនេះ ត្រូវពង្រឹងការធ្វើវិមជ្ឈការផែនការរៀបចំដែនដី រួមទាំងសេវាកម្មដើម្បីកសាងសមត្ថភាពស្ថាប័នគ្រប់គ្រងក្នុងមូលដ្ឋាន និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវតំបន់ដែលបានអភិវឌ្ឍ។ ការការពារធនធានធម្មជាតិ ប្រព័ន្ធជីវៈចម្រុះ និងទេសភាពធម្មជាតិសំខាន់ៗដែលកំពុងប្រឈមនឹងហានិភ័យនិងការបាត់បង់ ជាប្រការចាំបាច់ដើម្បីបញ្ចៀសនូវផលវិបាកអវិជ្ជមានផ្សេងៗ ជាពិសេស ភាពក្រីក្រនិងចំណាកស្រុករបស់ប្រជាជនមូលដ្ឋាន។ ប្រសិនបើការគ្រប់គ្រងធនធានធម្មជាតិ ដីធ្លី ទឹក ពពួកសត្វនិងរុក្ខជាតិ និងធនធានព្រៃឈើបានត្រឹមត្រូវស្របតាមគោលការណ៍នៃកិច្ចការពារបរិស្ថាន ជនបទនឹងក្លាយជាតំបន់ទាក់ទាញប្រជាជនដោយសង្ឃឹមថានឹងមិនចាំបាច់មានវិធានការទប់ស្កាត់ចំណាកស្រុក។

ដើម្បីធានានូវការអភិវឌ្ឍប្រកបដោយសមធម៌និងបរិយាបន្ន និងមានចីរភាព ការអភិវឌ្ឍទីជនបទនិងការអភិវឌ្ឍទីក្រុងជាទំនាក់ទំនងមិនអាចកាត់ផ្តាច់ពីគ្នា សំដៅកាត់បន្ថយគម្លាតរវាងគ្នា និងកាត់បន្ថយចលនាចំណាកស្រុក។ ពាក់ព័ន្ធនឹងការផ្សារភ្ជាប់ជនបទនិងទីក្រុង កត្តាចម្បងគឺត្រូវមានវិធានការគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍជនបទ ដែលការអភិវឌ្ឍនេះមិនអាចទទួលបានជោគជ័យដោយពឹងផ្អែកតែលើវិស័យកសិកម្មមួយមុខឡើយ ពោលគឺត្រូវធ្វើវិចារណកម្មជាមួយវិស័យនានា រាប់ទាំងការបញ្ចូលបច្ចេកវិទ្យា ការធ្វើពិពិធកម្មមុខរបរផ្សារភ្ជាប់នឹងឧស្សាហកម្មតាមរយៈសហគ្រាសខ្នាតតូចនិងមធ្យម ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងផ្នែកសាធារណៈ ផ្នែកឯកជន និងសង្គមស៊ីវិល។

ដីកសិកម្ម ដីព្រៃឈើនិងដីជលផល ជាប្រភពចម្បងសម្រាប់ផលិតកម្មដំណាំស្បៀង ដំណាំកសិ-ឧស្សាហកម្មនិងសម្រាប់រក្សានូវបរិស្ថានធម្មជាតិ ដែលត្រូវកំណត់ការគ្រប់គ្រងនិងការប្រើប្រាស់ដោយប្រសិទ្ធភាពតាមរយៈការរៀបចំបទដ្ឋានគតិយុត្តលើការប្រើប្រាស់ ការអភិរក្សការការពារនិងការអភិវឌ្ឍ។ ដូច្នេះ ត្រូវធ្វើការពិនិត្យកែលម្អការប្រើប្រាស់ដីទាំងនោះឱ្យបានសមស្រប ក្នុងគោលដៅបង្កើនការវិនិយោគលើវិស័យកសិកម្ម និងរៀបចំឱ្យមានការអភិវឌ្ឍឧស្សាហកម្ម ដែលមិនប៉ះពាល់ឬអាចប៉ះពាល់តិចតួចដល់បរិស្ថាន ដែលអាចទូទាត់បាន។

ដើម្បីគ្រប់គ្រងការប្រើប្រាស់ដីកសិកម្មត្រូវធ្វើការសិក្សាស្រាវជ្រាវនូវលក្ខណៈអំណោយផលពីធម្មជាតិនៃដី ធ្វើចំណាត់ថ្នាក់ប្រភេទដីតាមទម្រង់សារធាតុផ្សំ និងបែងចែកតំបន់ដីកសិកម្មសម្រាប់តម្រង់ទិសការប្រើប្រាស់ដីនិងការកែលម្អដី។ ទិន្នន័យអំពីដីកសិកម្មតាមតំបន់មួយចំនួនដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រមូលបាន ជាជំនួយដ៏សំខាន់ក្នុងការធ្វើចំណាត់ថ្នាក់ប្រភេទដីកសិកម្មនិងការរៀបចំផែនទីប្រើប្រាស់ដីកសិកម្ម ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ជាមួយនេះក៏ត្រូវរៀបចំវិធានការគ្រប់គ្រងតំបន់អភិរក្សជីវៈចម្រុះ ដើម្បីធ្វើឱ្យមានសុវត្ថិភាពដល់ប្រភពដើមនៃធនធានសេណេទិកក្នុងតំបន់និងប្រព័ន្ធអេកូឡូស៊ី រួមទាំងដំណាំរុក្ខជាតិផ្សេងៗនិងប្រភេទសត្វ ដែលមានកំណើតឬមានវត្តមាននៅនឹងកន្លែង ដែលអាចរងគ្រោះដោយការប្រើគ្រាប់ពូជបង្កាត់ឬប្រើប្រាស់ថ្នាំកសិកម្ម។

ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ជីវិតសេដ្ឋកិច្ចនិងសង្គម និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនិងមុខងារនៃការរៀបចំដែនដី។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រព័ន្ធព័ត៌មានគមនាគមន៍និងការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាតនិង

ប្រព័ន្ធអនាម័យ សេវាសុខភាពសាធារណៈ សេវាអប់រំ និងទូរគមនាគមន៍ ត្រូវកែលម្អជាប្រចាំតាមរយៈការស្តារនីតិសម្បទានិង/ឬការសាងសង់ថ្មី ដើម្បីឱ្យប្រជាជននៅជនបទអាចទទួលបាននូវសេវាទាំងនេះ។

តាមករណីចាំបាច់ ការធ្វើសមាហរណកម្មកម្មវិធីអភិវឌ្ឍតំបន់ជនបទគួរពិចារណាបញ្ចូលនូវគម្រោងការកែលម្អភូមិឋាន កម្មវិធីការពារបរិស្ថាន ការការពារមរតកវប្បធម៌របស់ជនបទ ការរក្សាទេសភាពរបស់ជនបទ ការរៀបចំសំណង់និងហេដ្ឋារចនាសម្ព័ន្ធដោយផ្អែកលើមតិយោបល់នៃអ្នកចូលរួមធ្វើផែនការ និងគោលដៅនៃការអភិវឌ្ឍ។

ក្នុងគោលដៅអភិរក្សដីកសិកម្មសម្រាប់ការផលិតស្បៀងនិងទប់ស្កាត់ការបង្កកដីទុកសម្រាប់កេងយកចំណេញ ជាពិសេស ការប្តូរប្រភេទនៃការប្រើប្រាស់ដីដែលរដ្ឋមិនបានទទួលផលចំណូលអ្វីចូលថវិកាជាតិ ចាំបាច់ត្រូវមានការរៀបចំបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងដីដែលមានសក្តានុពលពីធម្មជាតិទុកសម្រាប់ផលិតកម្មកសិកម្ម។ វិធានការមួយចំនួនសម្រាប់ទប់ស្កាត់ការប្រមូលដីទុកមានជាអាទិ៍ ការរៀបចំផែនការប្រើប្រាស់ដី ការកសាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងនីតិវិធីនៃការប្តូរប្រភេទនៃការប្រើប្រាស់ដី ការអនុវត្តម៉ឺងម៉ាត់នូវការប្រមូលពន្ធលើដីមិនប្រើប្រាស់។ល។

### ៥.២.៦- ការកែសម្រួលក្បាលដី ការបង្រួមក្បាលដី/បំបែកក្បាលដី

ក្នុងលក្ខខណ្ឌដែលការគ្រប់គ្រងនិងប្រើប្រាស់ដីមិនសមហេតុផល ឬមិនទាន់ល្អប្រសើរ ដូចជាលក្ខណៈក្បាលដីនៃតំបន់មួយមានភាពខុសគ្នាខ្លាំងចំពោះទំហំ រូបរាង លទ្ធភាពទទួលបានសេវាសង្គមនិងហេដ្ឋារចនាសម្ព័ន្ធ ឬម្ចាស់ដីតែមួយមានក្បាលដីតូច/ធំជាច្រើនកន្លែងស្ថិតនៅទីតាំងផ្សេងដាច់ដោយឡែកៗពីគ្នា នោះការទទួលបានផលប្រយោជន៍ពីដី មិនអាចឈានដល់កម្រិតអតិបរមាឡើយ។ ដូច្នេះ គួរធ្វើការរៀបចំដីឱ្យសមស្របទៅនឹងសក្តានុពលនិងភាពចាំបាច់ផ្សេងៗ គួបផ្សំនឹងស្ថានភាពជាក់ស្តែងនានា តាមរយៈការកែសម្រួលក្បាលដី និងការបង្រួម/បំបែកក្បាលដី ទាំងនៅតាមទីក្រុង ទីប្រជុំជន ទាំងនៅទីជនបទ។

កន្លងមក ទីប្រជុំជនដែលទើបនឹងកើតថ្មីៗមួយចំនួនពុំបានរៀបចំផែនការអភិវឌ្ឍន៍ទៅតាមប្លង់គោលណាមួយឡើយ ទាំងការរៀបចំសេវាកម្មសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធនិងការរៀបរយសំណង់។ ប្រការទាំងនេះគួរតែធ្វើការកែលម្អឡើងវិញ ដោយផ្លាស់ប្តូរនូវរចនាសម្ព័ន្ធរបស់តំបន់នោះតាមរយៈផែនការអភិវឌ្ឍន៍មួយដ៏ត្រឹមត្រូវនិងឯកភាពគ្នា ដើម្បីធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។ ការកែសម្រួលក្បាលដី ការបង្រួមក្បាលដីឬបំបែកក្បាលដី ជាប្រតិបត្តិការមួយមានគោលដៅអភិវឌ្ឍមូលដ្ឋាន អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមបង្កើនផលិតភាពសេដ្ឋកិច្ច បញ្ចៀសទំនាស់នៃការប្រើប្រាស់ដីធ្លី និងជួយកែលម្អភូមិឋានឱ្យមានវឌ្ឍនភាពនិងភាពសុខដុម។

ការកែសម្រួលក្បាលដី ការបង្រួម/បំបែកក្បាលដី ជាឧបករណ៍ដ៏សំខាន់សម្រាប់ការរៀបចំដីនិងទីតាំងនោះឡើងវិញ ទាំងលក្ខខណ្ឌរូបវន្តនិងលក្ខខណ្ឌដទៃទៀត ទាំងការរក្សាឬ

ការផ្លាស់ប្តូរមុខងារដី ដើម្បីទទួលបាននូវលក្ខខណ្ឌប្រសើរជាងមុនលើផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ សោភ័ណភាពនិងចីរភាពបរិស្ថាន។ នេះជាវិធានការមួយធ្វើឱ្យមានផលចំណេញផ្នែកសេដ្ឋកិច្ច ដោយគោរពទៅតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

ការកែសម្រួលក្បាលដីនិងការបង្រួមឬបំបែកក្បាលដី ត្រូវបានប្រើជាឧបករណ៍សម្រាប់ដោះស្រាយការអនុវត្តគម្រោងការអភិវឌ្ឍធំៗនៅតាមតំបន់ទីក្រុងនិងទីប្រជុំជន និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ ផ្លូវដែក ស្ថានីយ ព្រលានយន្តហោះ តំបន់លំនៅឋាន សំណង់ផ្សេងៗ និងការអភិវឌ្ឍបៃតងដើម្បីធានាថាប្រជាជនគ្រប់រូបទទួលបាននូវសេវាកម្មសាធារណៈសម្រាប់សុខុមាលភាពក្នុងការរស់នៅ ការបំពេញការងារ និងការកម្សាន្ត។

នៅតាមទីជនបទ ការកែសម្រួលក្បាលដីនិងការបង្រួម/បំបែកក្បាលដី ត្រូវបានអនុវត្តលើក្បាលដីកសិកម្ម ដើម្បីទទួលបានផលិតភាពកសិកម្មខ្ពស់ ចំណេញពេលវេលានិងថវិកា ដោយការដោះដូរដីស្រែចម្ការតូចៗដែលស្ថិតនៅរាយប៉ាយឱ្យប្រមូលផ្តុំមកនៅជាប់ៗគ្នា និងជួយកែលម្អដល់ការកាន់កាប់ដីស្រែចម្ការ សម្រួលដល់ការអនុវត្តគម្រោងកែលម្អដីកសិកម្ម ដោះស្រាយនូវទំនាស់ដែលកើតឡើងពីការប្រើប្រាស់ធនធានទឹកឬការដឹកជញ្ជូនកសិផលនិងចំណេញពេលវេលាក្នុងការបង្កបង្កើនផល។ ចំពោះការកែលម្អភូមិឋានឬការរៀបចំតំបន់វប្បធម៌ តំបន់អភិរក្សទីជម្រាលឬតំបន់ការពារ គម្រោងប្រមូលផ្តុំលំនៅឋានរាយប៉ាយមកជាភូមិឋាននឹងនាំមកនូវផលចំណេញក្នុងការប្រើប្រាស់សេវាសាធារណៈ សម្រួលដល់ការដឹកជញ្ជូននិងដោះដូរកសិផល និងការធានាសន្តិសុខនិងសុវត្ថិភាព។

ក្នុងដំណើរការរៀបចំផែនការនិងការអនុវត្តគម្រោងកែសម្រួលក្បាលដី ចាំបាច់ត្រូវមានការចូលរួមពីម្ចាស់ដីនិងអ្នកពាក់ព័ន្ធដោយការស្រុះស្រួលគ្នា ផ្អែកលើការទទួលយករបស់មតិភាគច្រើនក្នុងគោលការណ៍ស្មើភាព សមធម៌ និងតម្លាភាពលើផលប្រយោជន៍។ លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំងដី ការផ្លាស់ប្តូររូបរាងដី ការចូលរួមវិភាគទានជាចំណែកដី ការដោះដូរជាដីឬជាសាច់ប្រាក់ ការចំណាយទឹកប្រាក់ទិញទំហំដីដែលលើសឬការទទួលយកសំណងលើដីដែលខ្វះ ចាំបាច់ត្រូវធ្វើការគណនាការទូទាត់សំណងដោយមានការយល់ព្រមពីម្ចាស់ដី។ ប្រការនេះទាមទារនូវប្រព័ន្ធវាយតម្លៃថ្លៃដីមួយមានប្រសិទ្ធភាពនិងតម្លាភាពសម្រាប់វាយតម្លៃថ្លៃទីតាំងដីដែលត្រូវធ្វើការដោះដូរ ឬការផ្តល់សំណងទូទាត់។

ការអនុវត្តគម្រោងកែសម្រួលក្បាលដី ការបង្រួមនិងការបំបែកក្បាលដីជាបន្ទុករបស់វិស័យសាធារណៈ តែចំពោះគម្រោងការធំៗ នោះការចូលរួមរបស់វិស័យឯកជនគឺជាកត្តាគន្លឹះដើម្បីរួមចំណែកក្នុងការគាំទ្រដល់ការវិនិយោគលើគម្រោងសម្រាប់រយៈពេលខ្លីឬវែង។ ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ នឹងធានានូវតម្លាភាពនិងអភិបាលកិច្ចល្អ និងជួយបំពេញគ្នាទៅវិញទៅមក។ រាល់គម្រោងការកែសម្រួលក្បាលដី ត្រូវកាត់បន្ថយជាអតិបរមានូវភាពស្មុគស្មាញនិងទំនាស់ដែលអាចកើតឡើងក្នុងការរៀបចំទំហំដី ទីតាំងដី មុខងារប្រើប្រាស់ដី ដើម្បីឱ្យម្ចាស់ដីអាចយល់ព្រមលើលក្ខខណ្ឌរូបវន្ត លក្ខខណ្ឌតម្លៃដីមុននិងក្រោយការរៀបចំ និង

លក្ខខណ្ឌច្បាប់ទាក់ទងនឹងសិទ្ធិទាំងឡាយរបស់ម្ចាស់ដីនិងការវិនិយោគ។ ដូច្នេះ ត្រូវរៀបចំយន្តការសម្របសម្រួលនិងដោះស្រាយកិច្ចការពាក់ព័ន្ធនានាមានជាអាទិ៍៖

- ការកំណត់សិទ្ធិផ្សេងៗលើក្បាលដី រួមទាំងសិទ្ធិបំបែកឬបង្រួមក្បាលដី
- ការកំណត់មុខងារនៃការប្រើប្រាស់ដីនិងការដោះដូរដី
- ការកំណត់ព្រំដីឯកជន ដីសាធារណៈ ដីសម្ភូហភាព ដីសម្រាប់ប្រើប្រាស់ផ្សេងៗ
- ការចុះបញ្ជីដីឬការចុះបញ្ជីដីឡើងវិញ
- ការវាយតម្លៃថ្លៃដីសម្រាប់ធ្វើការទូទាត់និងការចាត់ចែងហិរញ្ញវត្ថុសម្រាប់ទូទាត់
- ការរៀបចំដីនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា
- ការតាមដាននិងវាយតម្លៃគម្រោង
- ការសម្របសម្រួលនិងការចរចា
- ការសម្រុះសម្រួលនិងដោះស្រាយទំនាស់ឬបញ្ហាផ្សេងៗដែលអាចកើតមាន។ល។

ជាមួយគ្នានេះ ក៏ត្រូវការនូវច្បាប់អស្សាមិករណ៍និងច្បាប់ស្តីពីសិទ្ធិបុព្វក្រៃក្នុងករណីមានតម្រូវការដីយកទៅប្រើប្រាស់បម្រើផលប្រយោជន៍សាធារណៈ។ ក្នុងករណីដែលមានការប្រែប្រួលខ្លាំងនៃតម្លៃថ្លៃដី ចាំបាច់ត្រូវពិភាក្សាឡើងវិញជាមួយអាជ្ញាធរ មុននឹងអនុវត្តគម្រោង។

ក្នុងការចុះបញ្ជីដីធ្លីកន្លងមក មានការណែនាំរបៀបកត់ត្រាប្រភេទនៃការប្រើប្រាស់ដីជាដីស្រែ ដីចម្ការដំណាំ ដីធ្វើសិប្បកម្មឬរោងចក្រ ដីសង់អគារលំនៅឋានឬសំណង់សិល្បការ្យដោយផ្អែកលើការប្រកាសរបស់អ្នកកាន់កាប់ដីនិងការពិនិត្យជាក់ស្តែង។ ឯការកែសម្រួលក្បាលដី ការបំបែកឬបង្រួមក្បាលដី នឹងត្រូវអនុវត្តដោយផ្អែកលើតម្រូវការនៃផលប្រយោជន៍សាធារណៈឬលើសំណើរបស់អ្នកកាន់កាប់ដីដែលអាចនឹងត្រូវពិនិត្យសម្រេច ប្រសិនបើសំណើនោះមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់ឬផ្តល់ផលអវិជ្ជមានដល់ប្រយោជន៍សាធារណៈ។ ដូច្នេះ ក្នុងការប្តូរប្រភេទនៃការប្រើប្រាស់ដី ដែលករណីខ្លះធ្វើឱ្យមានការកែប្រែទាំងស្រុងនូវតម្លៃថ្លៃដី ចាំបាច់ត្រូវមានមតិយោបល់ពីស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងប្រភេទដីនោះ មុននឹងពិនិត្យសម្រេច។ យ៉ាងណាក៏ដោយគម្រោងការកែសម្រួលក្បាលដី ការបង្រួមឬបំបែកក្បាលដីត្រូវសម្របតាមលក្ខខណ្ឌនៃតំបន់ សំដៅបង្កើនតម្លៃសេដ្ឋកិច្ចលើការប្រើប្រាស់ដី ការបង្កើតការងារ សុខុមាលភាពនិងសុវត្ថិភាពនៃការរស់នៅ ភាពសុខដុមក្នុងទំនាក់ទំនងរវាងទីប្រជុំជននិងជនបទ ការអភិវឌ្ឍប្រកបដោយតុល្យភាព ការលើកកម្ពស់តម្លៃវប្បធម៌មូលដ្ឋាន សន្តិសុខនិងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាពសម្រាប់មនុស្សបច្ចុប្បន្ននិងអ្នកជំនាន់ក្រោយ។

### ៥.២.៧- ការអភិវឌ្ឍតំបន់អាទិភាព

ក្នុងគោលដៅទាញផលចំណេញសេដ្ឋកិច្ច សង្គម ការរៀបចំដែនដីត្រូវមានផែនការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចនិងឱកាសការងារ។ ប្រការសំខាន់គឺបញ្ចៀសចលនាបម្លាស់ទីស្វែងរកការងារធ្វើនៅតាមទីក្រុងឬនៅឆ្ងាយពីលំនៅឋាន ដោយការផ្តល់កាលានុវត្តភាពក្នុងការបណ្តុះបណ្តាលនិងការងារធ្វើនៅមូលដ្ឋាន។ ដូច្នេះការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ចត្រូវ

ផ្សារភ្ជាប់នឹងការអភិវឌ្ឍលំនៅឋាន ដើម្បីកាត់បន្ថយចំណាយលើការធ្វើដំណើរ និងរួមចំណែកកាត់បន្ថយគម្លាតរវាងតំបន់មួយនិងតំបន់មួយទៀត។

ស្ថាប័ននិងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីនិងធនធានធម្មជាតិ បានខិតខំជំរុញការកសាងផែនការការពារនិងអភិវឌ្ឍដីធ្លីនិងធនធានធម្មជាតិ ក្នុងក្របខណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គម។ ប៉ុន្តែ ការរៀបចំផែនការអភិវឌ្ឍនៅតាមតំបន់អាទិភាពមួយចំនួននៅពុំទាន់បានប្រទាក់ក្រឡាគ្នាល្អនិងមានប្រសិទ្ធភាពនៅឡើយ ហើយច្រើននាំមុខដោយវិស័យឯកជនដែលស្វែងរកការវិនិយោគ តាមគោលដៅនៃធុរកិច្ចរបស់គេ ដែលជួនកាលមិនឆ្លើយតបនឹងគោលបំណងរបស់រដ្ឋ ឬអាចប៉ះពាល់ដល់បរិស្ថាននិងសង្គមទៀតផង។

ការរៀបចំដែនដីត្រូវផ្តល់អាទិភាពលើតំបន់មួយចំនួន ដោយរៀបចំផែនការលម្អិតនៃការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព និងសិក្សាវាយតម្លៃច្បាស់លាស់នូវផលប៉ះពាល់បរិស្ថាននិងសង្គមនៃគម្រោងការអភិវឌ្ឍដូចជា៖

- តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម ច្រករបៀងសេដ្ឋកិច្ច
- តំបន់ការពារ តំបន់បេតិកភណ្ឌវប្បធម៌ តំបន់ឆ្នេរ តំបន់ដីសើម តំបន់ជីវៈចម្រុះ
- តំបន់អាងទន្លេសាប អាងទន្លេមេគង្គ អាងស្តុកទឹកធម្មជាតិ
- តំបន់ឥសាននិងតំបន់ខ្ពង់រាប
- តំបន់ងាយរងគ្រោះ តំបន់ទេសចរណ៍។ល។

## ៥.៣- អនុវិស័យបែងចែកដីធ្លី

តាំងពីក្រោយឆ្នាំ១៩៧៩ កម្ពុជាបានអនុវត្តការបែងចែកដីធ្លីដល់ប្រជាកសិករនិងអ្នកកាន់កាប់ប្រើប្រាស់ដីតាមរូបភាពផ្សេងៗចំនួន៥ដំណាក់គឺ (១) ការបែងចែកដីធ្លីនិងលំនៅឋានលើកដំបូងនៅឆ្នាំ១៩៨៩ ដល់គ្រប់គ្រួសារប្រជាជនដែលកំពុងកាន់កាប់និងប្រើប្រាស់នៅពេលនោះដោយទទួលស្គាល់ជាសិទ្ធិភោគៈ (២) ការបែងចែកដីធ្លីដល់ប្រជាជនធ្វើមាតុភូមិនិវត្តន៍ពីជាយដែនកម្ពុជាថៃពីឆ្នាំ១៩៩១ដល់១៩៩៣ (៣) ការផ្តល់ដីជូនដល់អតីតកងកម្លាំងខ្មែរក្រហមដែលធ្វើសមាហរណកម្មក្នុងមហាគ្រួសារខ្មែរនៅឆ្នាំ១៩៩៨ (៤) ការអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចដែលចាប់ដំណើរការតាំងពីឆ្នាំ២០០៣មក និង(៥) យុទ្ធនាការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីឬហៅថា ការអនុវត្តបទបញ្ជាលេខ០១ នៅឆ្នាំ២០១២។

ច្បាប់ភូមិបាលឆ្នាំ២០០១ ក្នុងជំពូកស្តីពីសម្បទាន ពីមាត្រា៤៨ដល់មាត្រា៦២ មានចែងពីសម្បទានដីដោយអាជ្ញាធរមានសមត្ថកិច្ចតាមអំណាចឆន្ទានុសិទ្ធិ ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់និងប្រើប្រាស់ដីនោះតាមការកំណត់នៃច្បាប់។ សម្បទានដីអាចធ្វើឡើងដើម្បីឆ្លើយតបទៅនឹងប្រយោជន៍សង្គម ហៅថាសម្បទានដីសង្គមកិច្ច ឬធ្វើឡើងដើម្បីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច ហៅថាសម្បទានដីសេដ្ឋកិច្ច។

### ៥.៣.១- គោលនយោបាយសម្បទានដីសង្គមកិច្ច

តាមស្មារតីនៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ចគឺជាការផ្តល់ដីឯកជនរបស់រដ្ឋ ដែលបានចុះបញ្ជីរួចហើយដល់ជនក្រីក្រដែលគ្មានដី

ឬខ្វះដីសម្រាប់សាងសង់លំនៅឋាននិង/ឬធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចបង្កើតឱកាសការងារនិងទទួលបានប្រាក់ចំណូល។ ដូច្នេះ មុខសញ្ញាសមស្របក្នុងការទទួលដីសម្បទានគឺ៖

- គ្រួសារក្រីក្រដែលគ្មានដីសម្រាប់សង់លំនៅឋាន
- គ្រួសារក្រីក្រដែលគ្មានឬខ្វះខាតដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅដែលបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានជាថ្មី
- គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រួសារធ្វើមាតុភូមិនិវត្តន៍
- យោធិនរំសាយ គ្រួសារយុទ្ធជនពលី ពិការ និងអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារដែលបានធ្វើសមាហរណកម្មមកជាប្រជាជនស៊ីវិល និង
- មុខសញ្ញាជាគោលដៅនៃការអភិវឌ្ឍតំបន់ដែលពុំទាន់បានអភិវឌ្ឍសមស្រប។

## កម្មវិធីសម្បទានដីសង្គមកិច្ច

កម្មវិធីសម្បទានដីសង្គមកិច្ចគឺមាននៅថ្នាក់មូលដ្ឋាននិងនៅថ្នាក់ជាតិ ឯយន្តការនៃការអនុវត្តមាននៅគ្រប់កម្រិតថ្នាក់រដ្ឋបាល គឺនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។

**នៅថ្នាក់ជាតិ** កម្មវិធីសម្បទានដីសង្គមកិច្ចដែលផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នណាមួយ ត្រូវបញ្ជូនទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យនិងពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានឬថ្នាក់ជាតិដែលទទួលបានការសម្រេចយល់ព្រមហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំសង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់រាជធានី ខេត្តនិងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិក្នុងអំឡុងពេលម៉ោងធ្វើការ។

**នៅថ្នាក់ក្រោមជាតិ** ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចនិងរៀបចំផែនការតាមការចាំបាច់ ដោយផ្អែកលើការផ្តួចផ្តើមរបស់ប្រជាជន ឬអង្គការសង្គមស៊ីវិល ឬមូលនិធិណាមួយ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវធ្វើប្រចាំឆ្នាំ ទៅតាមផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើអត្តសញ្ញាណកម្មដី ធ្វើចំណាត់ថ្នាក់ដី ធ្វើផែនការប្រើប្រាស់ដីនិងការកំណត់លក្ខណវិនិច្ឆ័យជ្រើសរើសមុខសញ្ញាអ្នកទទួលដី។ ផែនការនេះត្រូវបញ្ជូនតាមឋានានុក្រមទៅសុំការយល់ព្រមពីគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់រាជធានី ខេត្ត និងត្រូវជូនដំណឹងទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិឱ្យជួយពិនិត្យនិងសម្រេចជាផ្លូវការ។

## ចំណុចគន្លឹះនៃសម្បទានដីសង្គមកិច្ច

ចំណុចគន្លឹះនៃការអនុវត្តសម្បទានដីសង្គមកិច្ចស្ថិតនៅលើចំណុចសំខាន់បីគឺ៖

**ទី១ ការជ្រើសរើសដី :** ដីដែលជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច ជាដីឯកជនរបស់រដ្ឋឬរបស់ឯកជនដែលបានចុះបញ្ជីរួចហើយ។ ការស្វែងរកដីសម្រាប់បម្រើគោលដៅសម្បទានសង្គមកិច្ចជាចំណុចគន្លឹះបំផុត និងជាចំណុចផ្តើមដែលស្ថាប័ន អាជ្ញាធរមានអាណត្តិកាន់កាប់ដី

រដ្ឋគ្រប់លំដាប់ថ្នាក់ត្រូវខិតខំដោះស្រាយ សំដៅធានានូវសុវត្ថិភាពនិងសមធមិសង្គម។ កន្លងមក រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យយកដីរដ្ឋដែលត្រូវបានដកហូតពីការកាន់កាប់ដោយខុសច្បាប់ តាមបទបញ្ជាលេខ០១ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០០៦ និងតាមស្មារតីនៃសារាចរលេខ០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ មកប្រើប្រាស់ក្នុងគោលដៅនេះ។ ប៉ុន្តែការអនុវត្តត្រូវប្រឈម នឹងបញ្ហាជាច្រើន មានជាអាទិ៍ ស្ថានភាពមិនច្បាស់លាស់លើទិដ្ឋភាពគតិយុត្តនៃការកាន់កាប់ ដី ទីតាំងដីដែលបានដកហូតជាទូទៅមានតែលើលិខិតផ្លូវការ តែពុំមានដីជាក់ស្តែង ឬអ្នកកាន់ កាប់ដីដែលត្រូវបានដកហូតនៅតែបន្តកាន់កាប់ដោយស្ងៀមស្ងាត់។

**ទី២ ការជ្រើសរើសមុខសញ្ញាទទួលដី :** ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវផ្សព្វផ្សាយនូវគម្រោង សម្បទានដីសង្គមកិច្ចនិងកំណត់ពេលវេលានៃការដាក់ពាក្យសុំដីសម្បទាន។ ជាគោលការណ៍ គ្រួសារក្រីក្រដែលគ្មានដីឬខ្វះដី រស់នៅក្នុងតំបន់ដែលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនឹង មានសមាជិកចាប់ពីពីរនាក់ឡើងទៅ អាចបំពេញបែបបទដាក់ពាក្យស្នើសុំដីសម្បទាននៅ សាលាឃុំសង្កាត់។ ដើម្បីធានាតម្លាភាព បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំទាំងអស់ត្រូវបិទផ្សាយជា សាធារណៈ ហើយបន្ទាប់ពីការជ្រើសរើសមុខសញ្ញាតាមរយៈការវាយតម្លៃនិងដាក់ពិន្ទុ បញ្ជី ឈ្មោះអ្នកជាប់ត្រូវបានដី អ្នកជាប់បម្រុងដែលអាចនឹងទទួលបានដី និងអ្នកធ្លាក់ត្រូវបិទផ្សាយ ឡើងវិញក្នុងរយៈពេល២០ថ្ងៃ សម្រាប់ការប្តឹងតវ៉ាពីអ្នកមិនពេញចិត្តនឹងលទ្ធផល។

**ទី៣ ការអភិវឌ្ឍដី :** ក្នុងផែនការសម្បទានដីសង្គមកិច្ច ត្រូវពិចារណាឱ្យបានហ្មត់ចត់អំពី ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដូចជាការតភ្ជាប់ផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូ ប្រព័ន្ធ អគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធសង្គម មានជាអាទិ៍ សាលារៀន មណ្ឌលសុខភាព ទីតាំង ផ្សារ សេវារដ្ឋបាលនិងការរក្សាសន្តិសុខ និងឧបករណ៍សម្ភារៈសម្រាប់អភិវឌ្ឍដី ដើម្បីការរស់ នៅក្នុងជំហានដំបូង។ល។ អ្នកទទួលដីមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីនោះបានទេក្នុង រយៈពេល៥(ប្រាំ)ឆ្នាំដំបូង ដោយត្រូវអនុវត្តនូវលក្ខខណ្ឌសម្បទាននិងកិច្ចសន្យាឱ្យបានត្រឹម ត្រូវទើបអាចមានសិទ្ធិជាកម្មសិទ្ធិករ។

រាល់ផែនការបែងចែកដីសម្បទានសង្គមកិច្ចត្រូវបញ្ជាក់អំពីទីតាំង ទំហំ និងចំនួនក្បាលដី ដែលត្រូវបែងចែក និងបញ្ជីឈ្មោះមុខសញ្ញាអ្នកទទួលដីតាមអាទិភាព។

## ៥.៣.២- គោលនយោបាយសម្បទានដីសេដ្ឋកិច្ច

ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងការបែងចែកទូលំទូលាយនូវផ្លែផ្កានៃកំណើន សេដ្ឋកិច្ច រាជរដ្ឋាភិបាលបានជំរុញវិស័យកសិកម្មនិងកសិ-ឧស្សាហកម្មឱ្យដើរតួសំខាន់ ដើម្បី ធ្វើឱ្យមធ្យោបាយនៃការចិញ្ចឹមជិវិតមានលក្ខណៈសម្បូរបែប និងនាំមុខដោយអ្នកកាន់កាប់ដី ខ្នាតតូច។ ទស្សនៈនេះ សង្កត់ធ្ងន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវទិន្នផលស្រូវនិងទីផ្សារស្រូវ ការពង្រីកកសិ-ឧស្សាហកម្ម ពាណិជ្ជកម្មកសិផលនិងការបង្កើនចំណូលក្រៅពីកសិកម្ម។

ការធ្វើសម្បទានដីសេដ្ឋកិច្ច គឺរដ្ឋប្រគល់សិទ្ធិឱ្យវិនិយោគិនប្រើប្រាស់ដីឯកជនរបស់រដ្ឋ ដើម្បីអភិវឌ្ឍ បង្កើតសកម្មភាពកសិកម្មបែបប្រពលវប្បកម្ម បង្កើនផលិតផលកសិកម្ម បង្កើត ការងារធ្វើនៅជនបទដែលនឹងផ្តល់កាលានុវត្តភាពនៃការចិញ្ចឹមជីវិតឱ្យកាន់តែប្រសើរឡើងនិង គ្រប់គ្រងបានល្អនូវប្រព័ន្ធអេកូឡូស៊ី។ គោលដៅទាំងអស់នេះគឺជាលក្ខណវិនិច្ឆ័យសម្រាប់ការ

ពិចារណានិងវាយតម្លៃលើសំណើគម្រោងសម្បទានដីសេដ្ឋកិច្ច។ ជាការរំពឹងទុករបស់រដ្ឋ គឺការប្រមូលពន្ធដារផ្សេងៗលើកសិផលនិងការនាំចេញ។

សម្បទានដីសេដ្ឋកិច្ចមានភាពខុសប្លែកគ្នាពីទម្រង់ផ្សេងទៀតនៃការបែងចែកដីធ្លីរបស់រដ្ឋគឺកាតព្វកិច្ចរបស់សម្បទានិកក្នុងការប្រើប្រាស់ដីសម្រាប់គោលដៅជាក់លាក់ ដោយតម្រូវឱ្យមានការវិនិយោគផ្នែកមូលធន និងមានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើការប្រតិបត្តិ។ ដូច្នេះ មុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ច រដ្ឋត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់នូវលក្ខណៈបច្ចេកទេស និងធ្វើផែនការល្អិតល្អន់រួមគ្នាជាមួយនឹងវិនិយោគិន ដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងជាក់លាក់មួយរបស់រដ្ឋ ក្នុងការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សិប្បកម្មឬឧស្សាហកម្មកែច្នៃក្នុងស្រុកនិងការនាំចេញ ការចិញ្ចឹមសត្វផ្សារភ្ជាប់នឹងការកែច្នៃឬការនាំចេញទៅតាមផែនការវិនិយោគដែលមានក្នុងកិច្ចសន្យា ហើយរដ្ឋត្រូវតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។ រាល់ការផ្តល់សម្បទានដីសេដ្ឋកិច្ច ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់លេខាធិការដ្ឋានបច្ចេកទេសដែលជាអង្គភាពអន្តរស្ថាប័ន មានភារកិច្ចរៀបចំគម្រោងសម្បទាន ផ្តល់អនុសាសន៍លើសំណើសម្បទាននិងការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់។

តាមស្មារតីអនុក្រឹត្យលេខ១៤៦ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ដីរដ្ឋដែលអាចជាកម្មវត្ថុនៃការធ្វើសម្បទាន គឺជាដីដែលបានធ្វើអត្តសញ្ញាណកម្មនិងបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ មានការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន មានផែនការអភិវឌ្ឍន៍និងផែនការប្រើប្រាស់ដីដែលបានស្នើឡើង បានធ្វើការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន និងមានការឯកភាពលើផែនការដោះស្រាយការតាំងទីលំនៅរួចស្រេចហើយ។

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចអាចមានពីររូបភាពគឺ (១) គម្រោងសម្បទានដោយមានការអំពាវនាវ ដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីជាអ្នកលើកគម្រោងហើយអំពាវនាវរកអ្នកវិនិយោគ និង(២) គម្រោងសម្បទានមិនមានការអំពាវនាវ ដែលវិនិយោគិនជាអ្នករកទីតាំងដីដោយខ្លួនឯង និងលើកគម្រោងស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន។

## គម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវ

គម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវ គឺផ្តួចផ្តើមឡើងដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងការសិក្សាទីតាំងដី ការចុះបញ្ជីនិងការធ្វើផែនការប្រើប្រាស់ដី រួចផ្តល់ព័ត៌មានអំពីទីតាំង ទំហំ ប្រភេទ ផែនការទូទៅនៃការប្រើប្រាស់និងការអភិវឌ្ឍដី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ដោយរៀបចំជាឯកសារមូលដ្ឋាននិងលក្ខខណ្ឌសម្រាប់ការដាក់សំណើសុំគម្រោងសម្បទាន។ លេខាធិការដ្ឋានបច្ចេកទេសត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសេចក្តីជូនដំណឹងឱ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនេះទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីស្វះស្វែងរកវិនិយោគិន។

សំណើសុំវិនិយោគដោយមានការអំពាវនាវ ត្រូវដាក់នៅលេខាធិការដ្ឋានបច្ចេកទេស ដោយត្រូវភ្ជាប់ព័ត៌មានអំពីផែនការអាជីវកម្មលើការប្រើប្រាស់ដី ផែនការវិនិយោគសម្រាប់ការអភិវឌ្ឍដី ប្រភពដើមទុន សេចក្តីត្រូវការកម្លាំងពលកម្មនិងប្រភពផ្គត់ផ្គង់កម្លាំងពលកម្ម

បច្ចេកវិទ្យា ឧបករណ៍ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាពដែលគ្រោងនឹងប្រើប្រាស់ វិធានការទប់ស្កាត់ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន ការផ្សារភ្ជាប់ និងការគាំទ្រដល់សម្បទានដីសង្គមកិច្ចនិងការកែច្នៃវត្ថុធាតុដើមដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន។ ព័ត៌មានទាំងនេះជាមូលដ្ឋានសម្រាប់វាយតម្លៃ និងធ្វើចំណាត់ថ្នាក់សំណើនានាដោយលេខាធិការដ្ឋានបច្ចេកទេសដើម្បីពិនិត្យនិងលើកអនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេមកធ្វើការចរចាកិច្ចសន្យាសម្បទាន ហើយបើមិនអាចឈានដល់ការសម្រេចផ្តល់សម្បទានទេ ត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់ថ្នាក់បន្ទាប់មកធ្វើការចរចារហូតឈានដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទាន។

## គម្រោងសម្បទានដីសេដ្ឋកិច្ចដោយមិនមានការអំពាវនាវ

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវក្នុងករណីដែលម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ពិសេសដូចជាការនាំមកនូវបច្ចេកវិទ្យាថ្មី ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃឬទីផ្សារនាំចេញ។ ក្នុងករណីនេះ លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំសេចក្តីពណ៌នាសង្ខេបអំពីសាវតារផ្នែកអាជីវកម្មនិងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិតស្តីពីការវិនិយោគដែលស្នើឡើង ព័ត៌មានទាក់ទងទៅនឹងទំហំដីនិងទីតាំងដី។

ម្ចាស់សំណើដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគរាជធានីខេត្ត ដែលត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដើម្បីពិនិត្យនិងសម្រេចធ្វើការពិចារណាឬមិនពិចារណា។ ការចរចាចុះកិច្ចសន្យាលើគម្រោងសម្បទានមិនមានការអំពាវនាវត្រូវធ្វើតែក្នុងរយៈពេល២៨ថ្ងៃនៃថ្ងៃធ្វើការ ហើយបើមិនអាចសម្រេចបានត្រូវបញ្ឈប់ការពិចារណាលើសំណើនោះ។

ដើម្បីធានានូវប្រសិទ្ធភាពនៃគម្រោងសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានត្រូវតាមដានការអនុវត្តផែនការវិនិយោគ ផែនការដាំដុះ លក្ខណៈបច្ចេកទេសនៃអាជីវកម្មកសិ-ឧស្សាហកម្ម ឬឧស្សាហកម្មកែច្នៃកសិផល ការចិញ្ចឹមសត្វផ្សារភ្ជាប់នឹងការកែច្នៃ តាមដំណាក់ៗដូចមានចែងក្នុងកិច្ចសន្យាសម្បទាន។

## ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាមានភារៈទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាសម្បទានដែលបានអនុវត្តកន្លងមក ដោយបង្កើតយន្តការនិងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទាន សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធលើការអនុវត្តកិច្ចសន្យាសម្បទាន និងធ្វើរបាយការណ៍អំពីការគ្រប់គ្រងកិច្ចសន្យាសម្បទានទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្តល់ជាព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេសឬដល់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

មាត្រា៥៩នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់ថា សម្បទានដីសេដ្ឋកិច្ចអាចមានទំហំធំបំផុតត្រឹមតែ១០ ០០០ហិកតា។ សម្បទានដែលបានសម្រេចហើយនិងមានទំហំលើសពីការកំណត់នេះ ជាកម្មវត្ថុនៃការកាត់បន្ថយ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេសក្នុងការត្រួតពិនិត្យឡើងវិញ។ លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ចដែលក្រសួងស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយបានអនុវត្តកន្លងមកដើម្បីពិនិត្យលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន លើការអនុវត្តរបស់សម្បទានិក ដោយពិចារណាលើកម្រិតនៃការវិនិយោគដែលបានធ្វើរួចហើយ និងដែលគ្រោងធ្វើបន្ត លើថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន។ល។ ប្រសិនបើរកឃើញថាសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពីមួយម៉ឺនហិកតា ក្រសួងស្ថាប័នឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដីត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសនូវចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ឬស្នើឱ្យមានការធ្វើនិយ័តកម្មដីនោះនិងព្យាយាមចរចាលើការកាត់បន្ថយ។ ក្រោយពីបញ្ចប់ការត្រួតពិនិត្យឡើងវិញ អាជ្ញាធរដែលបានចុះកិច្ចសន្យាសម្បទានត្រូវធ្វើរបាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដោយភ្ជាប់អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលនៃការត្រួតពិនិត្យឡើងវិញទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាមួយនេះ ក៏ត្រូវស្នើសុំធ្វើនិយ័តកម្មដីក្នុងតំបន់ដីសម្បទានដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ ឬធ្វើការកែតម្រូវក្បាលដី និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។

### ៥.៣.៣- ការអភិវឌ្ឍក្របខណ្ឌនៃភាពជាដៃគូរវាងកសិដ្ឋានខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ និងការចូលរួមពីវិស័យឯកជន

កន្លងមក រាជរដ្ឋាភិបាលបានរៀបចំអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។ តែដំណើរការអនុវត្តនូវបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យទាំងនោះ នៅមិនទាន់បានរលូននិងស៊ីជម្រៅនៅឡើយ ជាពិសេស ការកសាងភាពជាដៃគូរវាងកសិដ្ឋានខ្នាតធំ សហគ្រាសកសិកម្ម និងកសិករកាន់កាប់ដីខ្នាតតូចនិងមធ្យម ឬរវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច។ ក្នុងការបែងចែកដីធ្លីសម្រាប់គោលដៅសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានបញ្ចូលចំណុចមួយជាលក្ខណវិនិច្ឆ័យនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺការផ្សារភ្ជាប់និងការគាំទ្រគ្នាទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ចប្រសិនបើមាន ព្រមទាំងកំណត់ឱ្យអនុវត្តជារបៀបស្បែកខ្លា គឺត្រូវឆ្វៀលកាត់ចេញនូវភូមិឋាន ស្រែចម្ការរបស់ប្រជាពលរដ្ឋដែលមាននៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច។ ម្យ៉ាងទៀតមុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ច ចាំបាច់ត្រូវចុះពិនិត្យជាក់ស្តែង ហើយប្រសិនបើមានការប៉ះពាល់ដល់ប្រជាជនដែលកំពុងរស់នៅ គឺត្រូវកាត់ដីជូនពួកគាត់ជាសម្បទានដីសង្គមកិច្ច និងត្រូវត្រៀមបម្រុងផ្ទៃដី១០%ថែមទៀតសម្រាប់សេចក្តីត្រូវការនៅពេលអនាគត។

ការកសាងភាពជាដៃគូជាមួយប្រជាជនក្នុងមូលដ្ឋាននឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សម្បទានិក ជាអាទិ៍ ភាពសុខដុមក្នុងដំណើរការវិនិយោគ ការផ្តល់កម្លាំងពលកម្មដល់កសិដ្ឋាន។ ឯប្រជាពលរដ្ឋវិញក៏អាចទទួលបាននូវបច្ចេកទេសថ្មីនៃការដាំដុះ ការលើកកម្ពស់គុណភាពនិងបរិមាណនៃផលិតកម្មកសិកម្ម ការបំពេញឱ្យគ្នាក្នុងការកែច្នៃផលិតផលកសិកម្ម និងការលើកកម្ពស់ជីវភាពរបស់ប្រជាកសិករ។ ដូច្នេះ ត្រូវមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីគោលនយោបាយនិងផលប្រយោជន៍ដែលប្រជាជនអាចទទួលបានពីសម្បទានដីសេដ្ឋកិច្ច ដើម្បីបំបាត់ទស្សនៈប្រឆាំងនឹងសម្បទានដីសេដ្ឋកិច្ច។ ជាមួយនេះ ត្រូវចៀសវាងការរំលោភបំពានពីសំណាក់សម្បទានិក ដោយធ្វើការឈូសឆាយដីមុនការកំណត់ព្រំប្រទល់ជាក់លាក់ ឬឈូសឆាយលើដីដែលប្រជាពលរដ្ឋបានកាន់កាប់ និងប្រើប្រាស់តាំងពីយូរលង់មកហើយ។ ការអនុវត្តផែនការវិនិយោគដោយតម្លាភាពនិងការចូលរួមតាមដានការអនុវត្តសម្បទានពីសំណាក់អាជ្ញាធរដែនដី ជាកត្តាគន្លឹះដែលត្រូវអនុវត្តទន្ទឹមនឹងការទប់ស្កាត់នូវសកម្មភាពចូលកាន់កាប់ដីតំបន់សម្បទានដោយពួកឱកាសនិយម ឬការបង្កភាពអសកម្មដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការវិនិយោគរបស់សម្បទានិក។

ដំណើរការកសាងភាពជាដៃគូរវាងប្រជាកសិករខ្នាតតូច មធ្យម និងកសិដ្ឋានខ្នាតធំ ឬសហគ្រាសកសិកម្ម ចាំបាច់ត្រូវមានការសម្របសម្រួលប្រកបដោយតម្លាភាពពីស្ថាប័នរដ្ឋក្នុងការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន(Public Private Partnership-PPP)។ ដូច្នេះក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច គួរពិចារណានូវទីតាំងបម្រុងសម្រាប់គម្រោងសម្បទានដីសង្គមកិច្ច និងអនុវត្តការចុះកិច្ចសន្យាផលិតកម្មកសិកម្មជាមួយកសិករដែលរស់នៅជាប់ឬនៅក្បែរកសិដ្ឋានខ្នាតធំ ការបង្កើតកម្មវិធីអភិវឌ្ឍតំបន់ថ្មីសម្រាប់វិស័យកសិឧស្សាហកម្មផ្សារភ្ជាប់នឹងការផ្តល់ដីដល់គ្រួសារដែលគ្មានដីឬខ្វះដី។

ការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មនឹងរួមចំណែកផ្តល់នូវបច្ចេកទេសនៃការដាំដុះនិងពង្រឹងជំនាញរបស់កសិករលើការផលិតនិងការគ្រប់គ្រងផលិតផល។ កិច្ចសន្យាផលិតកម្មកសិកម្មគឺជាទម្រង់មួយនៃការធ្វើពាណិជ្ជកម្ម ដោយដាក់បញ្ចូលកសិករខ្នាតតូចទៅក្នុងខ្សែចង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនឬកសិដ្ឋានខ្នាតធំ។ ដោយការយល់ដឹងអំពីតម្រូវការទីផ្សាររបស់ប្រជាកសិករនៅមានកម្រិត ចាំបាច់ត្រូវលើកទឹកចិត្តឱ្យចងក្រងជាសមាគមកសិករ ឬជាសហគមន៍កសិកម្ម ដើម្បីទទួលព័ត៌មានអំពីលក្ខខណ្ឌនៃកិច្ចសន្យាផលិតកម្មកសិកម្ម អំពីបច្ចេកទេសនិងវិធីសាស្ត្រថ្មីនៃការដាំដុះ ការចិញ្ចឹមសត្វ ឬការទទួលនិងការបែងចែកគ្រាប់ពូជដំណាំ ពូជសត្វ ពូជវារីជាតិ ព្រមទាំងការគ្រប់គ្រងនិងសម្របសម្រួលការផលិត ធានានូវបរិមាណនិងគុណភាពកសិផល ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារក្នុងស្រុកនិងការនាំចេញ។

### ៥.៣.៤- គោលនយោបាយចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមជនបទនិងនៅតាមទីក្រុង ទីប្រជុំជន

ច្បាប់ភូមិបាល បានបញ្ចប់ការចូលកាន់កាប់ដីតាមរូបភាពជាភោគៈ ចាប់ពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១។ មាត្រា១៨នៃច្បាប់នេះក៏បានបញ្ជាក់ថា *"ត្រូវទុកជាមោឃៈនិងគ្មានអានុភាពហើយមិនអាចត្រូវបានធ្វើនិយ័តកម្មទោះតាមរូបភាពណាក៏ដោយ ចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់"*។ ប៉ុន្តែក្នុងគោលដៅកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម រាជរដ្ឋាភិបាលខិតខំដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាជន ដោយដាក់ចេញនូវសារាចរចំនួន២គឺ សារាចរលេខ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ និងសារាចរលេខ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុងនិងទីប្រជុំជន ដោយផ្តល់នីតិវិធីសម្រាប់ដោះស្រាយតាមករណីនីមួយៗ។

#### សារាចរលេខ០២ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

សារាចរលេខ០២ មានគោលដៅដោះស្រាយការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅលើទីតាំងដីព្រៃនិងដីនៅតំបន់ជនបទដោយបុគ្គលឯកជន ដែលទន្ទឹមនឹងការអនុវត្តច្បាប់ក៏ទាមទារនូវការពិនិត្យករណីរំលោភជាក់ស្តែងនីមួយៗ និងដោះស្រាយដោយមានការអនុគ្រោះ ជាពិសេសចំពោះគ្រួសារក្រីក្រ និងចំពោះដីធ្លីដែលបានធ្វើអាជីវកម្មពិតប្រាកដ។ សារាចរនេះបង្ហាញនូវគំនិត២ គឺ(១) ការអនុវត្តគោលការណ៍ដែលមានចែងក្នុងមាត្រា១៨នៃច្បាប់ភូមិបាល និង(២) គោលនយោបាយដែលផ្អែកលើស្ថានភាពនៃសង្គមជាតិដោយអនុញ្ញាតឱ្យគ្រួសារក្រីក្រនិងអ្នកគ្មានដីបន្តប្រើប្រាស់ដីដែលបានកាន់កាប់បណ្តោះអាសន្ន។

ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់គឺសំដៅដល់៖

- ការចូលកាន់កាប់ដីរដ្ឋក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន
- ការចូលកាន់កាប់ដីរដ្ឋដែលត្រូវបានកំណត់ថាជាដីសាធារណៈរបស់រដ្ឋ
- ការបន្តកាន់កាប់ដីរដ្ឋក្រោយពេលលិខិតអនុញ្ញាតឬកិច្ចសន្យាអស់សុពលភាព
- ការកាន់កាប់ដីរដ្ឋលើសពីទំហំឬខុសទីតាំងកំណត់ក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យា
- ការផ្ទេរសិទ្ធិប្រើប្រាស់ដីរដ្ឋដោយបំពានលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យា
- ការបំប្លែងការកាន់កាប់ដីរដ្ឋទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់។

#### វិធានការចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

ចំពោះដីរដ្ឋដែលបានកាន់កាប់ដោយខុសច្បាប់ អាជ្ញាធរកាន់កាប់ដីរដ្ឋឬអភិបាលរាជធានី ខេត្ត ត្រូវចេញលិខិតទាមទារដីរដ្ឋមកវិញ ដោយទុករយៈពេល៣០ថ្ងៃ ឱ្យអ្នកកាន់កាប់ដីឆ្លើយតបនិងធ្វើការពិភាក្សាសម្របសម្រួល ដោយមានការចូលរួមពីអាជ្ញាធរដែនដីថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក ខណ្ឌ។ ប្រសិនបើនៅតែមិនអាចដោះស្រាយបាន ត្រូវរាយការណ៍និងលើកយោបល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីចាត់តាំងឱ្យមន្ត្រីចុះពិនិត្យឬពិភាក្សាបន្ថែមទៀត ដោយផ្អែកលើលក្ខណៈនៃការកាន់កាប់និងស្ថានភាពនៃអ្នក

កាន់កាប់។ បន្ទាប់មក ត្រូវធ្វើរបាយការណ៍ពីករណីនីមួយៗនិងលើកយោបល់សុំការសម្រេចពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ អភិបាលរាជធានី ខេត្តត្រូវចេញដីកាសម្រេចតាមករណីនីមួយៗ ដោយទុករយៈពេលសម្រាប់ការប្តឹងតវ៉ា។ បើអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់មិនព្រមចាកចេញតាមកាលកំណត់ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវរៀបចំពាក្យប្តឹងទៅតុលាការ។

ចំពោះដីព្រៃឈើដែលបានចេញដីកាដកហូតតាមបទបញ្ជាលេខ០១ប.ប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិអាជ្ញាធររាជធានី ខេត្តត្រូវធ្វើការសម្របសម្រួលជាមួយអ្នកប្តឹងតវ៉ាដើម្បីរកដំណោះស្រាយផ្អែកលើលក្ខណៈនៃការកាន់កាប់និងស្ថានភាពនៃអ្នកកាន់កាប់តាមករណីជាក់ស្តែង។

### គោលនយោបាយចំពោះអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់

ចំពោះគ្រួសារក្រីក្រដែលគ្មានដីឬខ្វះដីឬជាជនងាយរងគ្រោះ ហើយបានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ រាជរដ្ឋាភិបាលអាចអនុគ្រោះដោយផ្តល់ដីក្នុងទំហំមួយសមស្របដើម្បីប្រកបរបរចិញ្ចឹមជីវិតនិង/ឬស្នាក់នៅតាមករណីជាក់ស្តែង។ ឯជនជាតិដើមភាគតិចដែលអាជ្ញាធរប្រពៃណីរបស់គេបានអះអាងថាដីដែលរដ្ឋទាមទារនោះ ស្ថិតក្រោមការប្រើប្រាស់ជាសមូហភាពរបស់ពួកគេ នោះការទាមទារត្រូវផ្អាកសិនរហូតដល់ដីនោះត្រូវបានចុះបញ្ជីជាដីរដ្ឋ។

### គោលនយោបាយចំពោះដីរដ្ឋដែលបានកាន់កាប់ដោយខុសច្បាប់

ចំពោះដីដែលដកហូតមកវិញ បើដីនោះជាផ្នែកនៃដីឯកជនរបស់រដ្ឋ រដ្ឋអាចចាត់ចែងទៅតាមនីតិវិធីជាធរមានដូចជាលក់ ជួល ធ្វើប្រទានកម្ម ផ្តល់សិទ្ធិផលុបភោគ ផ្តល់ជាសម្បទានដីសង្គមកិច្ចឬសេដ្ឋកិច្ច។ ប៉ុន្តែបើដីដែលដកហូតមកវិញជាផ្នែកនៃដីសាធារណៈរបស់រដ្ឋ រដ្ឋអាចប្រើដីនោះទៅតាមរបបគតិយុត្ត ដូចជាជួលរយៈពេលខ្លី ផ្តល់សិទ្ធិផលុបភោគ អនុញ្ញាតឱ្យកាន់កាប់ឬប្រើប្រាស់ជាណ្តោះអាសន្នតាមរយៈការចុះកិច្ចព្រមព្រៀងផ្សេងៗ។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនអាចរកភស្តុតាងបញ្ជាក់អំពីពេលវេលានៃការចូលកាន់កាប់ដីរដ្ឋឬមិនអាចរកភស្តុតាងបញ្ជាក់ពីការបោះបង់ចោលភោគៈ ការទាមទាររបស់អ្នកកាន់កាប់ដីនោះអាចផ្តល់ជូនប្រសិនបើ៖

- ដីនោះមិនជាប់ប្រយោជន៍សាធារណៈឬមិនមានចរិតបម្រើប្រយោជន៍សាធារណៈ
- ដីនោះមិនទាន់បានចុះបញ្ជីជាដីរដ្ឋ
- អ្នកកាន់កាប់បានធ្វើអាជីវកម្មពិតប្រាកដលើដីនោះ និង
- បានបំពេញលក្ខខណ្ឌតម្រូវផ្សេងទៀតនៃភោគៈស្របច្បាប់។

### សារាចរលេខ០៣ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

សារាចរលេខ០៣មានគោលដៅដោះស្រាយការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមទីក្រុង ទីប្រជុំជន។ រាជរដ្ឋាភិបាលបានណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងស្ថាប័នពាក់ព័ន្ធនូវនីតិវិធីដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋដោយខុសច្បាប់ដោយប្រើប្រាស់យន្តការគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងការចូលរួមជាសមាជិកចំពោះកិច្ចពីតំណាងសហគមន៍និងសង្គមស៊ីវិល ក្នុងការ៖

- ស្រង់ទិន្នន័យជាក់លាក់អំពីចំនួនទីតាំងសំណង់បណ្ដោះអាសន្នតាមឃុំ សង្កាត់
- ប្រជុំពិនិត្យលើភាពត្រឹមត្រូវនៃទីតាំងសំណង់បណ្ដោះអាសន្នទីមួយៗនិងបញ្ចូលទិន្នន័យទៅក្នុងផែនទីឃុំសង្កាត់
- ជំរឿនចំនួនគ្រួសារ ចំនួនប្រជាជនតាមផ្ទះដែលរស់នៅក្នុងទីតាំងសំណង់បណ្ដោះអាសន្នដោយមានការចូលរួមពីតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន។

### ការស្វែងរកដំណោះស្រាយសម្រាប់អនុវត្ត

ផ្អែកលើព័ត៌មានដែលប្រមូលបាន ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ តំណាងសហគមន៍ក្នុងមូលដ្ឋាននិងសង្គមស៊ីវិលជាសមាជិកចំពោះកិច្ច ត្រូវប្រជុំពិភាក្សាស្វែងរកដំណោះស្រាយចំពោះករណីជាក់ស្តែងរបស់ទីតាំងសំណង់បណ្ដោះអាសន្នទីមួយៗ ដោយត្រូវចាត់ទុកផលប្រយោជន៍សាធារណៈជាអាទិភាពនិងផ្អែកលើផលប្រយោជន៍របស់ប្រជាពលរដ្ឋភាគច្រើនក្នុងសហគមន៍ ព្រមទាំងភាពចាំបាច់នៃការអភិវឌ្ឍរបស់មូលដ្ឋាន។ ក្នុងការសម្រេចជ្រើសរើសយកដំណោះស្រាយណាមួយ ដូចជាការប្តូរទៅកាន់ទីតាំងថ្មីឬការអភិវឌ្ឍនៅនឹងកន្លែង ឬជាគោលនយោបាយផ្សេងៗ ក្រុមការងារនេះត្រូវរៀបចំផែនការនិងកំណត់ពេលវេលាសម្រាប់អនុវត្តជាក់ស្តែង ហើយត្រូវស្នើសុំសេចក្តីសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

### ការពិភាក្សាសម្របសម្រួលចំពោះទីតាំងសំណង់បណ្ដោះអាសន្ន

ការសម្របសម្រួលត្រូវផ្អែកលើដំណោះស្រាយដែលបានឯកភាពគ្នា។ ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការកំណត់វិធីដែលត្រូវចាប់ដំណើរការដើម្បីជួយសម្រួលដល់ការអភិវឌ្ឍជីវភាពរស់នៅ ត្រូវពិភាក្សាជាមួយភាគីពាក់ព័ន្ធ។ ចំពោះទីតាំងដែលមិនអាចអភិវឌ្ឍនៅនឹងកន្លែងបានហើយត្រូវរុះរើទៅទីតាំងថ្មី ត្រូវរៀបចំផែនការច្បាស់លាស់មុននឹងអនុវត្តដំណោះស្រាយ ដើម្បីជួយសម្រួលដល់ការតាំងទីលំនៅថ្មីរបស់ប្រជាជន។ ក្នុងករណីណាក៏ដោយ ក៏អ្នកទទួលផលពីដំណោះស្រាយនៃការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមទីក្រុងទីប្រជុំជន អាចទទួលបានសិទ្ធិផលុបភោគតាមការព្រមព្រៀង ឬសិទ្ធិកម្មសិទ្ធិបន្ទាប់ពីបានកាន់កាប់ផ្ទាល់និងរស់នៅលើទីតាំងនោះយ៉ាងតិច១០ឆ្នាំជាប់គ្នា ឬសិទ្ធិជួលមានរយៈពេលកំណត់ដោយប្រាក់ឈ្នួលអនុគ្រោះ។ មានតែករណីប្រទានកម្មជាពិសេសពីរាជរដ្ឋាភិបាលទេ ទើបសិទ្ធិកម្មសិទ្ធិអាចទទួលបានដោយគ្មានលក្ខខណ្ឌ។

ជារួម រាល់ដំណោះស្រាយណាមួយដែលបានទទួលការព្រមព្រៀងពីភាគីពាក់ព័ន្ធ ត្រូវរៀបចំផែនការអនុវត្តជាជំហានៗតាមលទ្ធភាពជាក់ស្តែង។

## ៥.៤- គោលនយោបាយដីធ្លីនិងបញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

### ៥.៤.១-សភាពការណ៍បញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជា

សន្តិសុខនិងសុវត្ថិភាពក្នុងការប្រើប្រាស់ដីធ្លី ត្រូវបានគំរាមកំហែងដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលគ្របដណ្តប់លើផ្ទៃដីមួយភាគនៃព្រះរាជាណាចក្រកម្ពុជា។ បញ្ហាមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅកម្ពុជាគឺជាកេរដំណែលដែលបានបន្សល់ទុកពីជម្លោះ

និងសង្គ្រាមតំបន់ និងផ្ទៃក្នុង ចាប់តាំងពីពាក់កណ្តាលទសវត្សទី៧នៃសតវត្សទី២០ រហូតដល់ចុងឆ្នាំ១៩៩៨។ ការគំរាមដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនេះ មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ទៅតាមការផ្លាស់ប្តូរនៃចរិតសង្គ្រាម និងជម្លោះជាបន្តបន្ទាប់។ តំបន់នានានៅជាប់ព្រំដែនប្រទេសថៃរងផលប៉ះពាល់ខ្លាំងក្លាដោយសារមីន មានមីនប្រឆាំងមនុស្សនិងមីនប្រឆាំងរថក្រោះ ឯតំបន់ភាគខាងកើតនៃប្រទេសរងផលប៉ះពាល់ច្រើនដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម មានគ្រាប់ទំលាក់ពីលើអាកាស និងគ្រាប់សំណល់ពីសមរភូមិ។

មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម បានបង្កគ្រោះថ្នាក់ជាច្រើន ធ្វើឱ្យមនុស្សក្មេង ចាស់ ប្រុស ស្រី យោធា ស៊ីវិល រាប់ម៉ឺននាក់បានបាត់បង់ជីវិត របួស ពិការ និងបាត់បង់សមត្ថភាពពលកម្ម ក្លាយជាបន្ទុកដល់គ្រួសារនិងសហគមន៍ ព្រមទាំងបង្កជាឧបសគ្គដល់ការបង្កបង្កើនផល និងការអភិវឌ្ឍប្រទេសជាតិទៀតផង។

នៅចំពោះមុខគ្រោះដ៏ធំនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវស្ថាប័នជំនាញជាតិសំដៅដោះស្រាយបញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដឹកនាំការបោសសម្អាតដោយចាប់ផ្តើមពីដំណាក់កាលសង្គ្រោះបន្ទាន់ ឈានទៅដំណាក់កាលបោសសម្អាតជាលក្ខណៈមនុស្សធម៌ រហូតមកដល់ដំណាក់កាលគ្រប់គ្រងវិស័យសកម្មភាពមីនផ្អែកលើអភិក្រមគ្រប់ជ្រុងជ្រោយ។ ចាប់តាំងពីឆ្នាំ១៩៩២ រហូតមកទល់ដំណាច់ឆ្នាំ២០១៤ ជាមួយនឹងធនធានផ្ទាល់របស់កម្ពុជា និងជំនួយពីបរទេស បណ្តាប្រតិបត្តិករនៅកម្ពុជាបានបោសសម្អាតផ្ទៃដីជាង ១,៣៨៣ គីឡូម៉ែត្រក្រឡា រកឃើញនិងបំផ្លាញមីនប្រឆាំងមនុស្សចំនួនជាង១លានគ្រាប់ មីនប្រឆាំងរថក្រោះជាង២ម៉ឺនគ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាង២លានគ្រាប់។ ចំនួនជនរងគ្រោះប្រចាំឆ្នាំ បានធ្លាក់ចុះពី ៤.៣២០នាក់ ក្នុងឆ្នាំ១៩៩៦ មកនៅក្រោម ២០០នាក់ ក្នុងមួយឆ្នាំនៅឆ្នាំ២០១៣ឆ្នាំ២០១៤។ទោះជាយ៉ាងនេះក្តី ក៏បញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតែបន្តគំរាមកំហែងដល់អាយុជីវិតនិងសុខសុវត្ថិភាពរបស់ប្រជាជនកម្ពុជានៅឡើយ ដោយសារតម្រូវការចាំបាច់ក្នុងការប្រើប្រាស់ដីធ្លីនៅក្នុងវិស័យកសិកម្ម ការតាំងទីលំនៅ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។

### ៥.៤.២-គោលការណ៍ទូទៅនិងដំណោះស្រាយ

គោលនយោបាយប្រើប្រាស់ដីធ្លី និងការងារបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយបានដាក់ជាគោលដៅទី៩ នៃ "គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា" ហើយក៏ត្រូវបានបញ្ចូលជាគោលដៅទី១៨ នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិ។ ការងារនេះក៏ត្រូវបានកំណត់នៅក្នុង "យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី៣ និងត្រូវបានចាត់ទុកជាសមាសធាតុមួយនៃ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ"។ ទន្ទឹមនឹងនេះ កម្ពុជាក៏ទទួលបានការគាំទ្រពីរដ្ឋភាគីនៃអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ឱ្យបន្តបោសសម្អាតមីនដប់ឆ្នាំ ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៩។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រឹងយន្តការនិងគោលនយោបាយ

ដឹកនាំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងវិស័យសកម្មភាពមីនឱ្យកាន់តែរឹងមាំនិងមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការប្រើប្រាស់ដីធ្លី។

### ៥.៤.៣-យន្តការនៃការអនុវត្តការប្រើប្រាស់ដីធ្លីប្រកបដោយសុវត្ថិភាពចំពោះដីធ្លីរងផលប៉ះពាល់ដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

ដើម្បីធានាបាននូវសន្តិសុខ និងសុវត្ថិភាពដល់ប្រជាជនក្នុងការប្រើប្រាស់ដីធ្លី រាជរដ្ឋាភិបាលបានកំណត់ចេញនូវគោលការណ៍បោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដូចមានបញ្ជាក់នៅក្នុងគោលដៅទី១ពាក់ព័ន្ធនិងការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងផលប៉ះពាល់អវិជ្ជមានដទៃទៀត និងក្នុងគោលដៅទី២ ដែលរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១០-២០១៩។ យោងតាមទិន្នន័យស្រាវជ្រាវមូលដ្ឋានរបស់អាជ្ញាធរមីនផ្ទៃដីដែលនៅសង្ស័យថាមានផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម មានប្រមាណជិត២០០០(ពីរពាន់)គីឡូម៉ែត្រក្រឡាទៀត។ ដូច្នេះ យើងនឹងត្រូវការថវិកាសម្រាប់ការបោសសម្អាតប្រមាណជាង៤៥០លានដុល្លារអាមេរិក បើយោងតាមវិធីសាស្ត្រកាត់បន្ថយផ្ទៃដីដែលយើងបាននិងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

ជាគោលការណ៍ ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមដើម្បីមនុស្សធម៌នៅកម្ពុជាពុំតម្រូវឱ្យមានបង់ថ្លៃសេវាឡើង ដោយត្រូវប្រើប្រាស់ប្រភពធនធានពីរាជរដ្ឋាភិបាលពីភ្នាក់ងារអភិវឌ្ឍន៍ និងពីសប្បុរសជននានា។ ចំពោះគោលការណ៍បោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមដើម្បីសុវត្ថិភាពទូទៅ ដែលសំដៅលើការបោសសម្អាតដើម្បីធ្វើការប្រើប្រាស់ដីធ្លីក្នុងតំបន់មានវត្តមានគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងទីតាំងកាន់កាប់ដោយម្ចាស់កម្មសិទ្ធិ អ្នកវិនិយោគ គឺតម្រូវឱ្យប្រើប្រាស់សេវាកម្មបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៃអង្គភាពជំនាញដែលមានបញ្ជាក់ការទទួលស្គាល់ដោយអាជ្ញាធរមីនមុននឹងធ្វើការប្រើប្រាស់ដី។

## ៥.៥- គោលនយោបាយជាតិស្តីពីលំនៅឋាននិងការតាំងទីលំនៅបណ្តោះអាសន្ន

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស ដែលចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាពនិងសុខុមាលភាពរបស់ខ្លួននិងគ្រួសាររួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅឋាន..."*។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តអនុវត្តគោលការណ៍នៃសិទ្ធិមនុស្ស រួមទាំងសិទ្ធិទទួលបានលំនៅឋានសមរម្យសម្រាប់ស្នាក់នៅ ដោយដាក់ចេញនូវផែនការនិងយុទ្ធសាស្ត្រនានាដូចជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងយុទ្ធសាស្ត្រចតុកោណជាដើម។

គោលនយោបាយលំនៅឋានផ្តោតជាសំខាន់ទៅលើគ្រួសារដែលមានប្រាក់ចំណូលទាប មធ្យម និងក្រុមជនងាយរងគ្រោះ ក្នុងការទទួលបានលំនៅឋានសមរម្យ និងការដោះស្រាយជូនប្រជាជនដែលរស់នៅបណ្តោះអាសន្នលើទីតាំងមិនរៀបរយ ឱ្យទទួលបានលំនៅឋានសមស្រប មានសុវត្ថិភាពនិងផាសុកភាព និងយុទ្ធសាស្ត្រគាំទ្រដល់គ្រួសារសហគមន៍ក្នុងការស្វែងរកហិរញ្ញប្បទានសម្រាប់សាងសង់ឬជួសជុលកែលម្អលំនៅឋាន។

វិធីសាស្ត្រនៃការដោះស្រាយការកាន់កាប់ដីរដ្ឋដោយខុសច្បាប់និងដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្រ្ទានកាន់កាប់ដោយខុសច្បាប់ ត្រូវអនុវត្តតាមសារាចរលេខ០២ និងសារាចរលេខ០៣ របស់រាជរដ្ឋាភិបាល (សូមអានចំណុច ៥-៣-៤)។

## ៥.៥.១- ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការងារលំនៅឋាន

ជាទូទៅ ការងារលំនៅឋាននិងការតាំងទីលំនៅថ្មីជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុង ការងារនគរូបនីយកម្ម ការធ្វើផែនការប្រើប្រាស់ដី និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ។ ដូច្នេះ ត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់ផ្នែក គ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំគោលនយោបាយ បទដ្ឋានគតិយុត្ត ការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការស្វែងរកប្រភពធនធាន ហិរញ្ញប្បទាន ការជំរុញកិច្ចសហការជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិលនិងសហគមន៍ផ្ទាល់។

**ស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ** មានភារកិច្ចក្នុងការធ្វើអត្តសញ្ញាណកម្មទីតាំងដីសមស្របសម្រាប់លំនៅឋាន និងធ្វើសមាហរណកម្មទីតាំងនោះទៅក្នុងផែនការប្រើប្រាស់ដីដោយពិចារណាជាអាទិភាពលើលំនៅឋានសម្រាប់គ្រួសារក្រីក្រ និងជួយផ្តួចផ្តើមគំនិតរបស់សហគមន៍ក្នុងការជួយខ្លួនឯង ការសន្សំប្រាក់ សម្របសម្រួលជាមួយវិស័យឯកជនលើការងារលំនៅឋាន និងការគាំទ្រនូវសេវាចាំបាច់ជាមូលដ្ឋាន។

**សង្គមស៊ីវិល** ត្រូវរួមចំណែកជួយសហគមន៍ឱ្យចេះអភិវឌ្ឍខ្លួនក្នុងការចូលរួមធ្វើសេចក្តីសម្រេចផ្សេងៗការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ការដោះស្រាយទីតាំងលំនៅឋានបណ្តោះអាសន្ន ការរៀបចំគម្រោងសន្សំប្រាក់សម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មនានាជាចាំបាច់របស់សហគមន៍។

**ដៃគូអភិវឌ្ឍនិងវិស័យឯកជន** ជាដៃគូសំខាន់ក្នុងការរួមចំណែកជួយអភិវឌ្ឍសហគមន៍តាមរូបភាពផ្សេងៗ តាមរយៈកិច្ចសហការជាមួយរដ្ឋនិង/ឬជាមួយសហគមន៍ផ្ទាល់ ដូចជាការរៀបចំគម្រោងហិរញ្ញប្បទានសម្រាប់ជួសជុលនិងសាងសង់លំនៅឋាន គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មជាមូលដ្ឋានក្នុងតំបន់ក្រីក្រមិនរៀបរយ គម្រោងអភិវឌ្ឍន៍នៅនឹងកន្លែងនៃតំបន់មិនរៀបរយដែលមានភាពអនុគ្រោះ ការចូលរួមដោះស្រាយលំនៅឋាននៅលើទីតាំងដែលរដ្ឋមានគម្រោងសាងសង់សម្រាប់អ្នកមានប្រាក់ចំណូលមធ្យមនិងទាបតាមរយៈកិច្ចសន្យាផ្សេងៗ។ល។

## ៥.៥.២- ការរៀបចំយន្តការ

ការងារលំនៅឋានត្រូវមានយន្តការអនុវត្តជាអចិន្ត្រៃយ៍ និងមានប្រភពហិរញ្ញប្បទានសម្រាប់ដំណើរការ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលដឹកនាំយន្តការនេះ

ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិល ក្នុងការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ បទដ្ឋានគតិយុត្តសំដៅធានាសិទ្ធិទទួលបានលំនៅឋាន។

ការងារចម្បងរបស់ស្ថាប័ននេះគឺត្រូវសិក្សាពីស្ថានភាពនៃតម្រូវការ និងលទ្ធភាពនៃការផ្គត់ផ្គង់លំនៅឋាន ការរៀបចំដីធ្លីសម្រាប់អភិវឌ្ឍលំនៅឋានចំពោះមុខនិងនៅអនាគត ការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ បទដ្ឋានគតិយុត្តនិងការកៀរគរហិរញ្ញប្បទានជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន។ ស្ថាប័នទទួលបន្ទុកការងារលំនៅឋាន ត្រូវរៀបចំវេទិកាស្តីពីលំនៅឋានយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដើម្បីរៀបចំកម្មវិធីគម្រោងនានា និងតាមដានការវិវឌ្ឍប្រែប្រួលដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

## ៥.៥.៣- ការរៀបចំផ្នែកហិរញ្ញវត្ថុសម្រាប់លំនៅឋាន

ការផ្គត់ផ្គង់លំនៅឋានជាការវិនិយោគដ៏ធំធេងទៅលើដីធ្លី ទៅលើសំណង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននិងសេវាផ្សេងៗ។ ការអនុវត្តគោលនយោបាយលំនៅឋាន អាចផ្តើមពីវិធីដែលអាចធ្វើបានដូចជា កម្មវិធីកែលម្អបទប្បញ្ញត្តិផ្នែកហិរញ្ញវត្ថុ ការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ការបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល ការរៀបចំអភិវឌ្ឍសហគមន៍សន្សំប្រាក់ ការបង្កើតឱកាសការងារផ្សេងៗ។ល។

លើផ្នែកហិរញ្ញប្បទាន គ្រួសារក្រីក្រអាចចងក្រងជាសហគមន៍ បង្កើតជាក្រុមសន្សំប្រាក់ជាសមូហភាពសម្រាប់ផ្តល់ជាប្រាក់កម្ចីក្នុងការកែលម្អលំនៅឋាន កែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ កែលម្អជីវភាពរស់នៅនៃគ្រួសារ ឬអភិវឌ្ឍទីតាំងលំនៅឋានថ្មី។

គ្រួសារនីមួយៗឬសហគមន៍ក៏អាចធ្វើការសន្សំប្រាក់តាមកិច្ចសន្យារហូតដល់កម្រិតណាមួយទើបអាចសុំខ្ចីបំពេញបន្ថែមសម្រាប់ទិញសម្ភារៈពីសហគ្រាសសំណង់ដែលគាំទ្រពីភ្នាក់ងារមីក្រូហិរញ្ញវត្ថុដោយការបង់រំលស់ក្នុងអត្រាការប្រាក់ទាប។ ករណីនេះតម្រូវឱ្យគ្រួសារទទួលផលចូលរួមជាកម្លាំងពលកម្មក្នុងការសាងសង់លំនៅឋាន។

រដ្ឋ ដៃគូអភិវឌ្ឍ ផ្នែកឯកជន ឬសង្គមស៊ីវិលអាចបង្កើតមូលនិធិពិសេសសម្រាប់ការងារលំនៅឋាន ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភឬប្រាក់កម្ចីសម្រាប់កែលម្អលំនៅឋានឬទិញដីសម្រាប់សាងសង់លំនៅឋាន ដែលអ្នកទទួលផលត្រូវដាក់អ្វីជាប្រាតិភោគក្នុងការទទួលបានប្រាក់កម្ចី។ រដ្ឋក៏អាចរៀបចំគោលការណ៍ពិសេសចំពោះធនាគារដែលផ្តល់ប្រាក់កម្ចីសម្រាប់ទិញផ្ទះនិងសងរំលស់តាមកាលកំណត់ ដោយអនុគ្រោះមិនយកពន្ធលើប្រាក់ចំណេញពីការប្រាក់ដែលធនាគារឱ្យខ្ចី ដើម្បីឱ្យប្រាក់កម្ចីមានការប្រាក់ទាបជាងទីផ្សារ។ ម្យ៉ាងទៀតធនាគាររដ្ឋក៏អាចផ្តល់ប្រាក់កម្ចីសម្រាប់កែលម្អ ឬសាងសង់លំនៅឋានដោយដើរតួជាអ្នកអភិវឌ្ឍអចលនវត្ថុ ឬធ្វើតាមរយៈក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុដោយតម្រូវឱ្យមានការដាក់ប្រាតិភោគ។

ចំពោះនិយោជិតដែលមានប្រាក់ខែទៀងទាត់អាចសន្សំប្រាក់ក្នុងគណនីពិសេសរបស់ធនាគារ ដែលគណនីបែបនេះនឹងផ្តល់អត្រាការប្រាក់ថេរនិងផលប្រយោជន៍បង្កើនទ្រព្យ។ តាមធម្មតា គណនីបែបនេះច្រើនកំណត់រយៈពេល៧ឆ្នាំទើបម្ចាស់គណនីអាចដកប្រាក់សន្សំមកសាងសង់លំនៅឋានបាន។

ក្រៅពីនេះ ការសន្សំប្រាក់អាចធ្វើបានតាមវិធីលក់កាតសន្សំប្រាក់សម្រាប់លំនៅឋានដែលគ្រួសារក្រីក្រអាចទិញកាតនេះតាមលទ្ធភាពទឹកប្រាក់ដែលរកបានប្រចាំថ្ងៃឬនៅពេល

ណាមួយ រួចកោសលេខសម្ងាត់របស់កាតបញ្ចូនទៅធនាគារដែលគេបានបើកគណនី ដើម្បីបញ្ចូលទឹកប្រាក់នោះទៅក្នុងគណនីរបស់គេ ហើយរដ្ឋអាចផ្តល់ប្រាក់បន្ថែមក្នុងកម្រិតណាមួយជាការលើកទឹកចិត្តដល់ការសន្សំប្រាក់សម្រាប់លំនៅឋាន។

### ៥.៥.៤- ការរៀបចំកម្មវិធីលំនៅឋានសម្រាប់គ្រួសារមានចំណូលមធ្យមនិងទាប

កម្មវិធីលំនៅឋានត្រូវគិតគូរនូវជម្រើសសម្រាប់ការពិចារណាទៅតាមលទ្ធភាព ដូចជា៖

- ការសង់លំនៅឋានមានតម្លៃទាបសម្រាប់លក់ដោយបង់រំលស់ក្នុងរយៈពេលវែងឬជួលរយៈពេលវែងដល់គ្រួសារមានប្រាក់ចំណូលមធ្យមនិងទាប
- កិច្ចសហការគាំទ្រផ្តល់លំនៅឋានដោយដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិលដោយការបង់រំលស់ក្នុងរយៈពេលវែង
- ការផ្តល់ដីរដ្ឋឱ្យក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលក្រោយពីសង់រួចត្រូវផ្តល់លំនៅឋានមួយចំនួនជូនរដ្ឋតាមកិច្ចសន្យា ដើម្បីលក់ក្នុងតម្លៃទាបដល់គ្រួសារក្រីក្រ
- ការលើកទឹកចិត្តដោយបន្ធូរបន្ថយពន្ធផ្សេងៗដល់វិស័យឯកជន ឱ្យសង់លំនៅឋានសម្រាប់លក់ឬជួលឱ្យមន្ត្រីរាជការ កម្មករ ពលករ។
- ការជួលដីរដ្ឋរយៈពេលវែងឱ្យអ្នកក្រីក្រសង់លំនៅឋាន ប្រសិនបើរដ្ឋមិនទាន់ត្រូវការប្រើដីនោះក្នុងគោលដៅណាមួយ
- ការធ្វើប្រទានកម្មដីរដ្ឋសម្រាប់សាងសង់លំនៅឋានដល់អ្នកក្រីក្រ
- ការអភិវឌ្ឍនៅនឹងកន្លែងដល់សហគមន៍ដែលរស់នៅបណ្តោះអាសន្នលើដីរដ្ឋ
- ការអនុវត្តគោលនយោបាយព្រៃឈើដល់ជនក្រីក្រសម្រាប់គោលដៅសង់លំនៅឋាន
- ការជំរុញឱ្យនិយោជកសង់កន្លែងស្នាក់នៅសម្រាប់កម្មករ និយោជិត។ល។

## ៥.៦- គោលនយោបាយដីធ្លីនិងជនជាតិដើមភាគតិច

តាមទិន្នន័យនៃការស្រាវជ្រាវបានសន្និដ្ឋានថានៅក្នុងព្រះរាជាណាចក្រកម្ពុជាមានក្រុមជនជាតិដើមភាគតិចប្រមាណ២៤ជនជាតិ ដែលរស់នៅតាំងពីយូរលង់មកហើយតាមតំបន់ខ្ពង់រាបនិងតំបន់ព្រៃភ្នំនៃខេត្តមួយចំនួន ជាពិសេស នៅតំបន់ឦសាននៃប្រទេសកម្ពុជា។ មួយចំនួននៃក្រុមជនជាតិទាំងនេះបានកែប្រែជីវភាពរស់នៅរបស់ខ្លួន ជាលក្ខណៈឯកជនបន្ទាប់ពីការវិវឌ្ឍប្រែប្រួលផ្នែកសេដ្ឋកិច្ចនិងគមនាគមន៍។ ប៉ុន្តែ ក្រុមជនជាតិដើមមួយភាគធំទៀតបន្តរស់នៅតាមប្រពៃណី ប្រកាន់យកវប្បធម៌ ទំនៀមទម្លាប់ ជំនឿនិងភាសាផ្សេងៗគ្នាទៅតាមកុលសម្ព័ន្ធរបស់ខ្លួន និងប្រកបរបរចិញ្ចឹមជីវិតដោយការកាប់ឆ្ការព្រៃ ដើម្បីយកដីធ្វើស្រែចម្ការជាលក្ខណៈកសិកម្មពនេចរ ការប្រមូលអនុផលព្រៃឈើនិងការបរបាញ់។

ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនិងរក្សាទំនៀមទម្លាប់ វប្បធម៌ប្រពៃណីល្អ ជំនឿផ្សេងៗតាមកុលសម្ព័ន្ធ រាជរដ្ឋាភិបាលបានជំរុញគោលដៅអភិវឌ្ឍន៍សហស្សវត្សពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរនិងភាពអត់ឃ្លាន និងខិតខំធ្វើឱ្យសម្រេចនូវការអប់រំមូលដ្ឋាន៩ឆ្នាំដោយឥតគិតថ្លៃ។ ជាមួយនេះ គោលនយោបាយសម្រាប់ជនជាតិដើមភាគតិចត្រូវបានរៀបចំដោយយកចិត្តទុកដាក់លើការងារដីធ្លីនិងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ដែលជាមូលដ្ឋានក្នុងការលើកកម្ពស់ជីវភាពរស់នៅនិង

គុណភាពនៃជីវិត តាមរយៈកម្មវិធីនិងគម្រោងអភិវឌ្ឍន៍នានា ដោយសហការជាមួយដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល។ ទន្ទឹមនឹងការក្សាវប្បធម៌ទំនៀមទម្លាប់ប្រពៃណីល្អ និងជំនឿរបស់ជនជាតិដើមភាគតិច រាជរដ្ឋាភិបាលក៏បានជំរុញការថែទាំសុខុមាលភាពនិងអនាម័យដោយផ្តល់សេវាសុខាភិបាលសាធារណៈដល់មូលដ្ឋាន និងផ្តល់អាទិភាពដល់ការបន្តការសិក្សាដល់ថ្នាក់ឧត្តមសិក្សា និងការចងក្រងជាសហគមន៍ ដើម្បីទទួលបានសិទ្ធិកាន់កាប់និងប្រើប្រាស់ដីធ្លីជាកម្មសិទ្ធិសមូហភាព។

ការចងក្រងជាសហគមន៍និងការរៀបចំលក្ខន្តិកៈ ដើម្បីឱ្យមានការទទួលស្គាល់តាមផ្លូវច្បាប់ គឺជាសិទ្ធិស្វ័យសម្រេចឈរលើគោលការណ៍ស្ម័គ្រចិត្តពីសំណាក់គ្រួសារជនជាតិដើមភាគតិចផ្ទាល់។ ចំពោះជនជាតិដើមភាគតិចដែលមិនមានបំណងចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាលក្ខណៈឯកជន ក៏នឹងទទួលបាននូវរាល់សិទ្ធិលើអចលនវត្ថុនិងសិទ្ធិផ្សេងទៀតដូចប្រជាជនកម្ពុជាទូទៅដែរ។ ក្នុងករណីនេះ ការចុះបញ្ជីដីធ្លីជាលក្ខណៈបុគ្គលក៏ត្រូវអនុវត្តតាមនីតិវិធីនៃការចុះបញ្ជីដីរបស់បុគ្គលឯកជនដែរ។

### ៥.៦.១- សិទ្ធិកាន់កាប់និងប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច

កម្ពុជាជាប្រទេសឈានមុខមួយក្នុងការទទួលស្គាល់សិទ្ធិកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ហើយការផ្តល់កម្មសិទ្ធិជាសមូហភាពលើដីធ្លីត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់ភូមិបាលឆ្នាំ២០០១។ តាមមាត្រា២៥នៃច្បាប់ភូមិបាល *ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេប៉ុន្តែមានដីបម្រុងចាំបាច់ក្នុងការផ្លាស់វេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែង ដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង។* ដូច្នេះអាជ្ញាធររដ្ឋបាលពាក់ព័ន្ធនឹងដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលជាតំណាងស្ថាប័នរដ្ឋនៅក្នុងមូលដ្ឋាន ត្រូវចូលរួមក្នុងដំណើរការកំណត់ព្រំប្រទល់ក្បាលដីទាំងអស់ដែលសហគមន៍អះអាងថាជារបស់ខ្លួន។ ផ្អែកលើមូលដ្ឋាននៃច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងបង្កើតអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ដូច្នេះជនជាតិដើមភាគតិចដែលបានចងក្រងជាសហគមន៍មានការទទួលស្គាល់ជានីតិបុគ្គលតាមផ្លូវច្បាប់ មានបទបញ្ជាផ្ទៃក្នុងសហគមន៍ដែលចែងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ដីជាសមូហភាពតាមប្រពៃណីរបស់ខ្លួនរួចហើយ អាចស្នើសុំចុះបញ្ជីក្បាលដីទាំងអស់របស់ខ្លួននៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលសហគមន៍នោះតាំងនៅ។ ទីតាំងក្បាលដីទាំងឡាយរបស់សហគមន៍ដែលមានការទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាលនិងអ្នកជិតខាង ត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពជូនសហគមន៍លើកលែងតែក្បាលដីដែលមានការតវ៉ាពីតតិយជន។

កម្មសិទ្ធិសមូហភាពមានរាល់សិទ្ធិនិងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ ដូចជាសិទ្ធិបន្តមរតក សិទ្ធិប្រើប្រាស់និងអាស្រ័យផល ប៉ុន្តែសហគមន៍គ្មានសិទ្ធិចាត់ចែងលើចំណែកដីជាកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គលឬក្រុមណាមួយបានឡើយ។ ក្នុងករណីដែលសមាជិកណាមួយនៃសហគមន៍ចាកចេញពីសហគមន៍ ចំណែកសមស្របនៃដីប្រើប្រាស់ដោយសហគមន៍ស្ថិតក្នុងចំណែកដីឯកជនរបស់រដ្ឋ នឹងត្រូវផ្ទេរជាពិសេសជូនសមាជិកនោះ។ ឯចំណែកដីដែលជាដីសាធារណៈរបស់រដ្ឋ សហគមន៍មានសិទ្ធិប្រើប្រាស់និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួន។

## ៥.៦.២- បទបញ្ជាផ្ទៃក្នុងសហគមន៍

ដើម្បីធានានូវការអនុវត្តសិទ្ធិនិងការគ្រប់គ្រងដីធ្លីរបស់សហគមន៍ទៅតាមច្បាប់កំណត់ សហគមន៍ត្រូវមានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនស្តីពីការប្រើប្រាស់ដីធ្លី។ បទបញ្ជាផ្ទៃក្នុងនេះត្រូវចែងលម្អិតអំពីសិទ្ធិលើចំណែកនៃប្រភេទដីនីមួយៗ និងវិធីចាត់ចែងទ្រព្យសម្បត្តិសហគមន៍នៅពេលសហគមន៍ត្រូវរំសាយ។ បទបញ្ជាផ្ទៃក្នុងសហគមន៍ត្រូវតម្កល់ទុកនៅសាលាឃុំ សង្កាត់ និងចម្លងជូនអង្គភាពឬស្ថាប័នពាក់ព័ន្ធ ដែលមានចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ទាក់ទងនឹងការប្រើប្រាស់ដីព្រៃឈើ ដីតំបន់ការពារធម្មជាតិ ដីតំបន់រ៉ែនិងការអភិវឌ្ឍផ្សេងៗ ដើម្បីតាមដានត្រួតពិនិត្យលើការគ្រប់គ្រងនិងប្រើប្រាស់ដីសហគមន៍និងធនធានធម្មជាតិឱ្យមានផលិតភាព និរន្តរភាព ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។

ការចូលជាសមាជិកសហគមន៍ជាសិទ្ធិស្វ័យសម្រេចរបស់ប្រជាជនជាជនជាតិដើមភាគតិច។ ក្នុងករណីដែលជនជាតិដើមភាគតិចមានដីជាកម្មសិទ្ធិឯកជនឬបានកាន់កាប់ចំណែកដីជាឯកជនស្របច្បាប់ ហើយមានបំណងចង់ចូលជាសមាជិកសហគមន៍ ត្រូវលះបង់ចំណែកដីឯកជនរបស់ខ្លួនមកដាក់បញ្ចូលជាដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ និងត្រូវចាត់ដីនោះចូលក្នុងចំណែកដីឯកជនរបស់រដ្ឋ។

## ៥.៦.៣- ការកសាងផែនការប្រើប្រាស់ដីសហគមន៍

ការធ្វើផែនការប្រើប្រាស់ដីដោយការចូលរួមពីសហគមន៍ ត្រូវផ្សព្វផ្សាយជាសាធារណៈដើម្បីធានានូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ដី។ សហគមន៍ជនជាតិដើមភាគតិចមិនអាចប្តូរឬបង្ខំឱ្យប្តូរចេញពីដីដែលសហគមន៍បាននិងកំពុងកាន់កាប់ប្រើប្រាស់ជាកម្មសិទ្ធិសមូហភាពឡើយ លើកលែងតែតម្រូវការចាំបាច់នៃផលប្រយោជន៍ជាតិឬតម្រូវការជាបន្ទាន់របស់ជាតិ។ ការផ្លាស់ប្តូរនេះអាចធ្វើទៅបានដោយអនុវត្តតាមបទដ្ឋានស្តីពីការតាំងទីលំនៅជាថ្មី។ ជនជាតិដើមភាគតិចទាំងអស់ ទោះជាសមាជិកឬមិនមែនជាសមាជិកនៃសហគមន៍ក៏ត្រូវទទួលបានការការពារទល់នឹងការរំលោភលើទំនៀមទម្លាប់ឬការយកប្រៀបលើភាពខ្វះការយល់ដឹងក្នុងការធានាសិទ្ធិកាន់កាប់និងប្រើប្រាស់ដីធ្លី។

ជារួម រាជរដ្ឋាភិបាលកម្ពុជានឹងបន្តការពារនិងចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព ស្របតាមនីតិវិធីជាធរមាននិងយកចិត្តទុកដាក់លើៈ

- ការពង្រីកការយល់ដឹងនិងការគោរពពហុវប្បធម៌របស់ជនជាតិដើមភាគតិច ការចូលរួមជួយរៀបចំចងក្រងជាសហគមន៍តាមសំណូមពរ ការផ្តល់ចំណេះដឹងក្នុងការថែរក្សាវប្បធម៌ប្រពៃណីល្អនិងការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ឱ្យមាននិរន្តរភាព
- ការលើកកម្ពស់ជីវភាពរស់នៅនិងការចិញ្ចឹមជីវិត ដោយពង្រឹងការអប់រំផ្នែកកសិកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធស្របទៅនឹងតម្រូវការជាអាទិភាព ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ការអប់រំចំណេះដឹងទូទៅនិងមុខជំនាញផ្សារភ្ជាប់ទៅនឹងវប្បធម៌ប្រពៃណីល្អនិងការប្រើប្រាស់ភាសាតាមតំបន់របស់ជនជាតិដើមភាគតិចនៅក្នុងកម្មវិធីសិក្សា កម្មវិធីព័ត៌មានតាមវិទ្យុនិងទូរទស្សន៍ ជាពិសេស ព័ត៌មានដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌
- ការរៀបចំវិធានការដើម្បីរក្សាសិទ្ធិក្នុងការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ ទៅតាមប្រពៃណីរបស់ជនជាតិដើមភាគតិច និងស្របទៅតាមបទដ្ឋាននៃការគ្រប់គ្រងព្រៃឈើ ដើម្បីធានានូវផលប្រយោជន៍សេដ្ឋកិច្ចនិងការអភិវឌ្ឍសហគមន៍ ដោយការពិគ្រោះយោបល់និងការយកចិត្តទុកដាក់ពិនិត្យលើយោបល់របស់ជនជាតិដើមភាគតិច
- ការសិក្សាស្រាវជ្រាវនិងចងក្រងនូវវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ដើម្បីរៀបចំជាមជ្ឈមណ្ឌលវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច សំដៅការពារវប្បធម៌ទំនៀមទម្លាប់ប្រពៃណីល្អ ភាសា ចំណេះដឹង ប្រព័ន្ធជំនឿ សិប្បកម្មតម្បាញ ស្ថាបត្យកម្ម វាយនភណ្ឌ និងសិល្បៈផ្សេងៗរបស់ជនជាតិដើមតាមកុលសម្ព័ន្ធ។

## ៥.៧- គោលនយោបាយដីធ្លីនិងយេនឌ័រ

សមភាពយេនឌ័រក្នុងវិស័យដីធ្លី គឺផ្តល់ការគាំទ្រឱ្យមានការចូលរួមរបស់ប្រជាជនទាំងពីរភេទនៅក្នុងការអនុវត្តសិទ្ធិលើការកាន់កាប់និងប្រើប្រាស់ដីធ្លីឱ្យកាន់តែប្រសើរឡើង។ សមភាពយេនឌ័រលើការងារដីធ្លីជាប្រការចាំបាច់និងមិនអាចខ្វះបានក្នុងសង្គមជាតិមួយ។

គោលនយោបាយសមភាពយេនឌ័ររបស់រាជរដ្ឋាភិបាល បានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃខឿនសេដ្ឋកិច្ចនិងសង្គម ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ។ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មនៃព្រះរាជាណាចក្រកម្ពុជា ការកាត់បន្ថយភាពក្រីក្រគឺត្រូវបាននិងកំពុងជំរុញដោយក្រសួងស្ថាប័ននានា សំដៅធ្វើឱ្យប្រជាជនកម្ពុជាទាំងស្ត្រីនិងបុរសទទួលបាននូវផលពីការរីកចម្រើនសេដ្ឋកិច្ចនិងសង្គមបានសមរម្យ មានតម្លាភាពនិងប្រកបដោយសមធម៌។ កន្លងមក ការចូលរួមរបស់ស្ត្រីក្នុងវិស័យដីធ្លីនៅពុំទាន់មានការយកចិត្តទុកដាក់ឱ្យបានស៊ីជម្រៅអំពីសមភាពរវាងស្ត្រីនិងបុរសនៅឡើយ។ ដូច្នេះនៅពេលដែលមានលេចចេញជាបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិរវាងស្ត្រីនិងបុរសលើដីធ្លី ស្ត្រីភាគច្រើនជាអ្នករងគ្រោះពីការបាត់បង់សិទ្ធិកាន់កាប់និងប្រើប្រាស់ដីធ្លីជាងបុរស។ សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ការរងគ្រោះពីការបាត់បង់សិទ្ធិកាន់កាប់ អាចកាន់តែខ្ពស់ថែមទៀត ប្រសិនបើខ្វះការចូលរួមរបស់ស្ត្រីក្នុងវិស័យដីធ្លី ហើយវានឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញល្បឿននៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរឡើង។

ដើម្បីសម្រេចបានសមភាពយេនឌ័រក្នុងវិស័យដីធ្លីនិងការទទួលបាននូវអត្ថប្រយោជន៍ដោយសមធម៌រវាងស្ត្រីនិងបុរសក្នុងដំណើរការចុះបញ្ជីដីធ្លី ក្នុងការទទួលបានព័ត៌មានពីការងារដីធ្លី ក្នុងភាពជាម្ចាស់កម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីធ្លី និងដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ការតាមដាន ការអនុវត្តគោលនយោបាយ ការអនុវត្តផែនការនិងការផ្តួចផ្តើមគំនិតនានាក្នុងវិស័យដីធ្លី គោលការណ៍និងសកម្មភាពទាំងឡាយដែលត្រូវប្រកាន់យកគឺៈ

១- រាល់សកម្មភាពឬកម្មវិធីក្នុងវិស័យដីធ្លីត្រូវធានាថាស្ត្រីនឹងទទួលបាននូវអត្ថប្រយោជន៍ដែលកើតចេញពីកម្មវិធីឬសកម្មភាពទាំងនោះដោយស្មើភាព។

២- ស្ត្រីនិងបុរសត្រូវទទួលបាននូវព័ត៌មានដូចគ្នាអំពីគោលនយោបាយដីធ្លីនិងច្បាប់ដែលពាក់ព័ន្ធនឹងរដ្ឋបាលដីធ្លី(ការចុះបញ្ជីដីធ្លី ការដោះស្រាយវិវាទដីធ្លី ទីផ្សារដី។ល។) ការរៀបចំដែនដីគ្រប់កម្រិត ការបែងចែកដីធ្លី និងការតាំងទីលំនៅថ្មី។

៣- ការចុះបញ្ជីកម្មសិទ្ធិដីធ្លីឬការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យ ត្រូវកំណត់ឱ្យច្បាស់ថាជាទ្រព្យរួមរបស់ប្តីប្រពន្ធឬជាទ្រព្យដោយឡែករបស់ប្តីឬរបស់ប្រពន្ធ និងត្រូវធ្វើឡើងដោយមានការចូលរួមពីស្ត្រី ដោយផ្អែកលើទិដ្ឋភាពច្បាប់និងសង្គម ដើម្បីធានានូវសិទ្ធិរបស់ស្ត្រីនិងបុរសលើអចលនទ្រព្យ ព្រមទាំងការពារផលប្រយោជន៍របស់ប្តីនិងប្រពន្ធ និងដើម្បីផ្តល់ការការពារបន្ថែមទៅលើសិទ្ធិរបស់សហព័ទ្ធនីមួយៗនៅលើបណ្ណកម្មសិទ្ធិ។

៤- ស្ត្រីជាមេគ្រួសារដែលមានបណ្ណកម្មសិទ្ធិដីធ្លីនឹងបង្កើននូវឋានៈរបស់ស្ត្រីក្នុងសង្គម ព្រមទាំងផ្តល់លទ្ធភាពឱ្យស្ត្រីអាចយកកម្មសិទ្ធិដីធ្លីទៅដាក់ប្រាតិភោគ ឈានទៅរកឥណទានដើម្បីប្រកបរបរបង្កើនចំណូលបន្ថែមពីលើការងារស្រែចម្ការ។

៥- ស្ត្រីនិងបុរសត្រូវទទួលបាននូវកាលានុវត្តភាពដូចគ្នាក្នុងការចូលរួមផ្តល់យោបល់ក្នុងការអនុវត្ត ការអភិវឌ្ឍ ការទទួលផលដោយសមធម៌និងបរិយាបន្ន និងតម្លាភាពលើវិស័យដីធ្លី។

៦- ការលើកទឹកចិត្តឱ្យមានតំណាងជាស្ត្រីនៅគ្រប់គណៈកម្មការ គណៈកម្មាធិការផ្សេងៗក្នុងវិស័យដីធ្លី និងក្នុងតួនាទីជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់ ត្រូវជំរុញជាជំហានៗ។

៧- ការពង្រឹងសមត្ថភាពអាជ្ញាធរគ្រប់លំដាប់ថ្នាក់និងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាទូទៅ ពិសេស សម្រាប់ស្ត្រី រួមមានទាំងក្រុមជនងាយរងគ្រោះ ដូចជាកសិករក្រីក្រ ជនជាតិដើមភាគតិច និងគ្រួសារយុទ្ធជនពលីពិការ អំពីសិទ្ធិលើដីធ្លី(សិទ្ធិកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀត) ប្រភេទកម្មសិទ្ធិដីនិងការប្រើប្រាស់ដីធ្លី និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី។

៨- ការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដីធ្លី ផែនការប្រើប្រាស់ដី ផែនការអភិវឌ្ឍន៍នានា ត្រូវមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ជាពិសេស ប្រជាជនទាំងពីរភេទនៅនឹងកន្លែង ដោយធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដីនិងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

៩- ក្នុងដំណើរការបែងចែកដីធ្លី តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ឬការបែងចែកដីក្នុងគោលដៅការកាត់បន្ថយភាពក្រីក្រជារូបភាពប្រទានកម្ម និងការតាំងទីលំនៅថ្មីត្រូវធ្វើឡើងដោយសមធម៌និងការលើកកម្ពស់សមភាពរវាងស្ត្រីនិងបុរស។

១០- ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យដីធ្លីសម្រាប់រយៈពេលខ្លី មធ្យម និងវែងត្រូវរួមបញ្ចូលនូវយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព ដើម្បីអាចផ្តល់ចំណេះដឹងពីការងារដីធ្លីដល់គ្រប់សមាសភាគនៃសង្គម ពិសេស ស្ត្រីជាមេគ្រួសារ និងជនជាតិដើមភាគតិច។ ផែនការនេះត្រូវមានការតាមដានត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តពីសំណាក់ក្រសួងស្ថាប័នពាក់ព័ន្ធ។

ចំពោះសង្គមកម្ពុជាដែលមានគ្រួសារក្រីក្រភាគច្រើនរស់នៅតាមទីជនបទ ប្រជាជនច្រើនតែមិនបានយកចិត្តទុកដាក់លើការចុះបញ្ជីអត្រានុកូលដ្ឋាន ដូចជាសំបុត្រអាពាហ៍ពិពាហ៍ឬការបញ្ជាក់ពីការចុះចោលឬការបាត់ខ្លួនរបស់សហព័ទ្ធណាមួយជាដើម។ ឯកសារអត្រានុកូលដ្ឋានទាំងនេះជាសក្ខីកម្មចាំបាច់ក្នុងការកំណត់អត្តសញ្ញាណកម្មម្ចាស់ទ្រព្យ។ ដូចនេះ ទាមទារនូវការសិក្សារួមគ្នាមួយរវាងស្ថាប័នពាក់ព័ន្ធ ជាអាទិ៍ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លើទិដ្ឋភាពច្បាប់ដែលអាចសម្រួលឱ្យគ្រួសារទាំងនោះ អាចមានលិខិតូបករណ៍គ្រប់គ្រាន់សម្រាប់ការបំពេញបែបបទក្នុងការចុះបញ្ជីដីធ្លី និង/ឬការចុះបញ្ជីបន្តឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា ស្របតាមនីតិវិធីជាធរមាន។

## ៥.៨- គោលនយោបាយដីធ្លីនិងការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ

ក្នុងគោលដៅរួមចំណែកដល់ការអនុវត្តតាមសៀវភៅសការពារជាតិឆ្នាំ២០០៦ ការរួមចំណែកក្នុងការពង្រឹងសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងពង្រឹងនីតិរដ្ឋដើម្បីបុព្វហេតុអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានគិតគូរនូវតម្រូវការដីតាមតំបន់ផ្សេងៗសម្រាប់ប្រើប្រាស់និង/ឬបម្រុងទុក សម្រាប់ជាតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ រួមទាំងការតាំងទីលំនៅជាថ្មីរបស់កងកម្លាំងប្រដាប់អាវុធរំសាយនិង/ឬបាត់បង់សមត្ថភាពពលកម្ម និងគ្រួសារយុទ្ធជនពលី។ គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺទីតាំងនិងលម្ហនៃតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ ត្រូវរៀបចំជាផែនការគ្រប់គ្រងដោយមានការចូលរួមពីកងកម្លាំងប្រដាប់អាវុធក្នុងក្របខណ្ឌទូទៅនៃការធ្វើផែនការប្រើប្រាស់ដីនិងការគ្រប់គ្រងដីរបស់រដ្ឋ។ ជាទូទៅ តំបន់ព្រំដែនគឺជាតំបន់សមស្របសម្រាប់ប្រើប្រាស់ជាតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ។

### ៥.៨.១- គោលការណ៍និងសកម្មភាពនៃការអភិវឌ្ឍតំបន់កងកម្លាំងប្រដាប់អាវុធ

ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ គោលការណ៍និងសកម្មភាពទាំងឡាយដែលត្រូវប្រកាន់យកគឺៈ

១- ដីក្នុងតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធត្រូវប្រើប្រាស់សម្រាប់ (ក) គោលដៅកសាងជំរុំបន្ទាយ (ខ) ទីតាំងគ្រួសារកងកម្លាំងប្រដាប់អាវុធ (គ) តំបន់អភិវឌ្ឍយុទ្ធជនពិការ កងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍និង/ឬបាត់បង់សមត្ថភាព គ្រួសារកងកម្លាំងប្រដាប់អាវុធពលី (ដើម្បីអភិវឌ្ឍកសិកម្ម កសិឧស្សាហកម្ម) និង(ឃ) តំបន់បម្រើឱ្យសកម្មភាពប្រតិបត្តិការសឹកក្នុងបុព្វហេតុសន្តិសុខជាតិ។

២- ដីក្នុងតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធត្រូវគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តាមរយៈការចុះបញ្ជីសារពើភណ្ឌអចលនទ្រព្យរដ្ឋ(លើកលែងតែដីដែលបានផ្តល់ជាលក្ខណៈឯកជន និងតំបន់បម្រើឱ្យសកម្មភាពប្រតិបត្តិការសឹកក្នុងបុព្វហេតុសន្តិសុខជាតិ) ដោយមានកិច្ចសហការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីការដោះស្រាយរាល់ទំនាស់ដែលកើតមានក្នុងតំបន់អភិវឌ្ឍនោះ។

៣- ក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ ក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃត្រូវសហការជាមួយគ្រប់សមត្ថកិច្ចជំនាញពាក់ព័ន្ធ ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ល។ និងអាជ្ញាធរដែនដី ដូចមានចែងក្នុងសៀវភៅសការពារជាតិ ដើម្បីរួមចំណែកទប់ស្កាត់បទល្មើសផ្សេងៗដូចជាការនេសាទខុសច្បាប់ ការកាប់បំផ្លាញព្រៃលិចទឹក ព្រៃឈើ ការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់ ការបំផ្លាញបរិស្ថាន និងដើម្បីចូលរួមដាំនិងថែរក្សាការពារព្រៃឈើ ព្រមទាំងសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិ។

៤- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការកសាងតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ ក្នុងនោះមាន (ក) ការកសាងភូមិគ្រួសារកងកម្លាំងប្រដាប់អាវុធតាមបណ្តោយព្រំដែន (ខ) ការកសាងភូមិអភិវឌ្ឍយុទ្ធជនពិការ (គ) ការកសាងតំបន់គ្រួសារកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ បាត់បង់សមត្ថភាព និងពលី និងដែលបានផ្ទេរក្របខណ្ឌពីក្រសួងការពារជាតិនិងពីក្រសួងមហាផ្ទៃ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ៥.៨.២- ទិសដៅបន្ត

យោធិនវ័សាយក៏ជាមុខសញ្ញាទទួលដីក្នុងចំណោមប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសសម្រាប់ការទទួលដីសម្បទានសង្គមកិច្ច។

ផែនការកំណែទម្រង់កងយោធពលខេមរភូមិន្ទបានលើកពីគោលនយោបាយក្នុងការថែរក្សាកម្លាំងទ័ព(ទ័ពត្រៀមបម្រុង)។ ក្នុងគោលដៅនេះ គួរបង្កើតឱ្យមានតំបន់អភិវឌ្ឍដំណាំកសិកម្ម កសិឧស្សាហកម្មសម្រាប់កងយោធពលខេមរភូមិន្ទ។ ក្នុងពេលប្រទេសមានសន្តិភាព ក្រសួងការពារជាតិត្រូវ (ក) ទាក់ទងជាមួយក្រសួងស្ថាប័ននិងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរិះរកដីនិងប្រគល់ឱ្យអង្គភាពទ័ពធ្វើការផលិតដំណាំចិញ្ចឹមខ្លួនឯង និងលើកកម្ពស់ជីវភាពរស់នៅ (ខ) សហការជាមួយក្រុមហ៊ុនឯកជន ដើម្បីវិនិយោគដីសម្រាប់ដំណាំកសិ-ឧស្សាហកម្មក្នុងន័យរក្សាកម្លាំងទ័ពនិងរួមចំណែកអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

ក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃ បាននិងកំពុងគិតគូរនូវគោលនយោបាយដីធ្លីពាក់ព័ន្ធនឹងតំបន់អភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ សម្រាប់ធានាកម្រិតជីវភាពរស់នៅរបស់កងកម្លាំងប្រដាប់អាវុធនិងថែរក្សាកម្លាំងទ័ពត្រៀមបម្រុង តាមគោលដៅនៃការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់។

## ៥.៩- ការរៀបចំប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ

រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើតប្រព័ន្ធវាយតម្លៃថ្លៃដីនិងតម្លៃនៃសិទ្ធិកាន់កាប់អចលនទ្រព្យមួយមានលក្ខណៈសមស្រប មានភាពយុត្តិធម៌ មិនលំអៀង សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការនៃទីផ្សារ ការដាក់ធានាផ្សេងៗ ការផ្ទេរផ្ទេរសិទ្ធិ ការបង់ពន្ធ និងការដកហូត។ ដូច្នេះ ចាំបាច់ត្រូវរៀបចំនូវបទដ្ឋានបច្ចេកទេស នីតិវិធី យន្តការ និងដំណើរការប្រតិបត្តិលម្អិតនៃការវាយតម្លៃថ្លៃអចលនទ្រព្យស្របទៅតាមនិយាមអន្តរជាតិសម្រាប់អនុវត្ត។ ម្យ៉ាងទៀត ក្នុងការប្រតិបត្តិការវាយតម្លៃថ្លៃអចលនទ្រព្យក៏ត្រូវពិចារណានូវតម្លៃក្រៅពីតម្លៃតាមទីផ្សាររបស់អចលនទ្រព្យ មានជាអាទិ៍ តម្លៃសង្គម វប្បធម៌ សាសនា បញ្ញា និងបរិស្ថាន។ ប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យដែលមានតម្លាភាពនិងមានការយល់ដឹងជាសាធារណៈ នឹងជួយទប់ស្កាត់នូវការវាយតម្លៃមិនសមហេតុផល ធ្វើឱ្យការគ្រប់គ្រងធនធានសាធារណៈបានគត់មត់ល្អ ទាំងការទូទាត់ផ្សេងៗ ទាំងការជួលទ្រព្យសម្បត្តិរបស់រដ្ឋ។

ការវាយតម្លៃថ្លៃដីនិងតម្លៃថ្លៃអចលនទ្រព្យផ្សេងទៀតនៅជាប់នឹងដីគឺជាជំនាញអាជីពមួយដែលទាមទារនូវការអប់រំបណ្តុះបណ្តាល ការចងក្រងទិន្នន័យព័ត៌មានសំខាន់ៗជាច្រើនស្តីពីតម្លៃប្រាក់ចំណូលដែលទទួលបានពីទ្រព្យនោះនិងលក្ខខណ្ឌផ្សេងៗដែលមានឥទ្ធិពលលើក្បាលដី។ នៅខែកក្កដា ឆ្នាំ២០០៩ សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លីបានចែងតម្រូវឱ្យរៀបចំប្រព័ន្ធវាយតម្លៃថ្លៃដី ដែលមានលក្ខណៈចូលរួម មានតម្លាភាព និងមានការទទួលស្គាល់ជាផ្លូវការ។ ច្បាប់និងបទដ្ឋានគតិយុត្តជាច្រើនទៀតដូចជាក្រមនីតិវិធីរដ្ឋប្បវេណីនិងក្រមរដ្ឋប្បវេណី ច្បាប់ហិរញ្ញវត្ថុ ច្បាប់ស្តីពីអស្សាមិករណ៍ ក៏បង្ហាញនូវភាពចាំបាច់ក្នុងការរៀបចំប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យជាផ្លូវការ ដើម្បីឱ្យការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាមានតម្លាភាពនិងយុត្តិធម៌។

### ៥.៩.១- គោលនយោបាយនៃការវាយតម្លៃថ្លៃអចលនទ្រព្យ

គោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យមានសារៈសំខាន់ណាស់ក្នុងការផ្តល់ទិសដៅដែលត្រូវអនុវត្ត ដើម្បីឈានទៅបង្កើតជាប្រព័ន្ធមួយសម្រាប់បម្រើសេចក្តីត្រូវការរបស់វិស័យសាធារណៈនិងវិស័យឯកជន។ គោលដៅចុងក្រោយនៃគោលនយោបាយនេះគឺរៀបចំនូវបទដ្ឋានបច្ចេកទេសនៃការវាយតម្លៃថ្លៃដីនិងការវាយតម្លៃថ្លៃសំណង់នៅជាប់នឹងដី កសាងផែនទីវាយតម្លៃថ្លៃដីនិងបញ្ជីវាយតម្លៃថ្លៃសំណង់នៅជាប់នឹងក្បាលដី ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលនៃការវាយតម្លៃទាំងនោះ និងរៀបចំយន្តការអនុវត្តនិងការតាមដានត្រួតពិនិត្យការអនុវត្ត។

### ៥.៩.២- វិធីសាស្ត្រអនុវត្តការវាយតម្លៃថ្លៃអចលនទ្រព្យ

ជាធម្មតាវិស័យសាធារណៈត្រូវការជាចាំបាច់នូវប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យមួយសម្រាប់ប្រើប្រាស់ក្នុងការប្រមូលពន្ធផ្សេងៗទាក់ទងនឹងតម្លៃអចលនវត្ថុ និងការទូទាត់សំណងដោយប្រើវិធីវាយតម្លៃបែបជារួម ដែលជាការវាយតម្លៃអចលនទ្រព្យទាំងឡាយស្ថិតក្នុងតំបន់យុត្តាធិការណាមួយរងឥទ្ធិពលទីផ្សារដូចគ្នានៅពេលវេលាមួយជាកំណត់។ ចំពោះវិស័យឯកជនគេច្រើនប្រើវិធីវាយតម្លៃបែបជាក់លាក់ដែលជាការប៉ាន់ស្មានតម្លៃអចលនទ្រព្យមួយៗរបស់

អតិថិជនក្នុងការលក់ ទិញ ជួលនិងផ្លាស់ប្តូរអចលនទ្រព្យ ការផ្តល់ឥណទាន ការដាក់ហ៊ីប៉ូតែក ការវិនិយោគ ការទូទាត់សំណង ការអនុវត្តសាលក្រមសាលដីការបស់តុលាការ។ល។ ដោយវិធីសាស្ត្រនិងបច្ចេកទេសនៃការវាយតម្លៃថ្លៃអចលនទ្រព្យមានភាពសាំញ៉ាំ ការអនុវត្តត្រូវរៀបចំជា២ជំហានគឺៈ

**ក្នុងជំហានដំបូង** ត្រូវកំណត់នីតិវិធីនៃការវាយតម្លៃដែលមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយអនុវត្ត ដោយជ្រើសរើសយកបច្ចេកទេសនិងស្តង់ដាអប្បបរមានៃការវាយតម្លៃមកប្រើប្រាស់ ដើម្បីបង្កើតជាមូលដ្ឋានទិន្នន័យដោយប្រើប្រព័ន្ធកុំព្យូទ័រជាជំនួយ។ ទន្ទឹមនឹងនេះត្រូវពង្រឹងនិងពង្រីកសមត្ថភាពវិជ្ជាជីវៈមន្ត្រីអ្នកអនុវត្ត បង្កើតក្រមសីលធម៌នៃការវាយតម្លៃដើម្បីជ្រើសរើសយកស្តង់ដាអប្បបរមានៃការវាយតម្លៃជាអន្តរជាតិមកអនុវត្តជាជំហានៗនិងធ្វើសមាហរណកម្មជាមួយប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដី។

**ក្នុងជំហានបន្ត** គឺត្រូវអនុវត្តវិធីសាស្ត្រនៃការវាយតម្លៃថ្លៃអចលនទ្រព្យជាលក្ខណៈវិទ្យាសាស្ត្រ តាមបច្ចេកទេសនិងនិយាមនៃប្រទេសក្នុងតំបន់ ដើម្បីបំពេញការអនុវត្តពីមួយឆ្នាំទៅមួយឆ្នាំរហូតដល់ការទទួលស្គាល់ជាអន្តរជាតិ។

### ៥.៩.៣- ភាពចាំបាច់និងប្រសិទ្ធភាពនៃការវាយតម្លៃថ្លៃអចលនទ្រព្យ

គោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យដែលមានការចូលរួមនឹងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគលើវិស័យអចលនទ្រព្យ ធ្វើឱ្យវិនិយោគសាធារណៈនិងឯកជនកាន់តែមានតម្លាភាពនិងប្រសិទ្ធភាព បង្កើនទំនុកចិត្តពីអតិថិជន ទាក់ទាញប្រជាជនឱ្យចូលរួមបង់ពន្ធផ្សេងៗលើអចលនទ្រព្យ កាត់បន្ថយនូវប្រតិបត្តិការផ្ទេរផ្ទួរ អចលនទ្រព្យក្រៅផ្លូវការឬគេចវេះការបង់ពន្ធ បង្កើនការប្រមូលពន្ធលើអចលនទ្រព្យ និងរួមចំណែកទប់ស្កាត់ការបង្កកដីទុកដើម្បីកេងយកចំណេញ ក៏ដូចជាជំរុញឱ្យការប្រើប្រាស់ដីអស់សក្តានុពល និងធានានូវសមធម៌ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

## ៥.១០- គោលនយោបាយដីធ្លីនិងការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុ ជាពិសេស ការកើនកម្តៅនៃភពផែនដីដែលបណ្តាលមកពីការប្រើប្រាស់សក្តានុពលនៃធនធានធម្មជាតិហួសកម្រិត កំណើនប្រជាជន និងកំណើនផ្នែកឧស្សាហកម្ម បានបង្កឱ្យមានកំណើនសីតុណ្ហភាព រលកកម្តៅ ដីខ្សោះជីជាតិ ការរលាយផ្ទាំងទឹកកក ការឡើងកម្ពស់ទឹកសមុទ្រ ការជ្រាបចូលទឹកសមុទ្រ ទឹកជំនន់ ការធ្លាក់ភ្លៀងជាគំហុកដែលបណ្តាលឱ្យមានការហូរច្រោះដី ការរអិលបាក់ដី ការរាំងស្ងួតរយៈពេលយូរ ការស្រុតចុះទាបនូវកម្រិតនីវ៉ូទឹកក្នុងដី ខ្យល់ព្យុះ ភ្លើងឆេះព្រៃ។ល។ នឹងបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី ការប្រែប្រួលសក្តានុពលដី ការចុះថយផលិតភាពដី ការបាត់បង់ដីកសិកម្ម។ បាតុភូតទាំងនេះនឹងជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងសង្គម នឹងអាចបណ្តាលឱ្យមានការផ្លាស់ប្តូរទីតាំងភូមិឋាន លំនៅឋាន។ល។ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ខ្ពស់ដល់វិធានការត្រៀមបម្រុងនិងសម្របសម្រួលការតាំងទីលំនៅជាថ្មីរបស់ប្រជាជននៃតំបន់ងាយរងគ្រោះបំផុត។ ការប្រែប្រួលអាកាសធាតុ ជាកង្វល់ដ៏ធំមួយរបស់ពិភពលោកនិងចោទជាបញ្ហាប្រឈមដល់និរន្តរ

ភាពនៃការចិញ្ចឹមជីវិតនិងការអភិវឌ្ឍសេដ្ឋកិច្ច។ កម្ពុជាក៏នឹងរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ឬគ្រោះរាំងស្ងួត ដែលគំរាមកំហែងដល់ការផលិតស្បៀង ដល់សន្តិសុខស្បៀងនិងដល់វិស័យកសិកម្មទាំងមូល។ ដូច្នេះមានតែការបន្សាំខ្លួនទៅនឹងការកើនកម្តៅនៃភពផែនដីនិងការខិតខំបន្ធូរបន្ថយនូវផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយការកាត់បន្ថយនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានប៉ុណ្ណោះ ដែលជាវិធីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ។

កម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាក្របខណ្ឌ សហប្រជាជាតិឆ្នាំ១៩៩៥ ស្តីពីការប្រែប្រួលអាកាសធាតុនិងពិធីសារក្រុងក្យូតូឆ្នាំ២០០២។ កម្ពុជាបានដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង។ គោលការណ៍នេះផ្អែកជាសំខាន់លើសសរស្តម្ភ៤គឺ (១) ការលើកកម្ពស់ *ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង* ដែលត្រូវប្រើប្រាស់ប្រសិទ្ធភាពនៃធនធានធម្មជាតិឱ្យមានចីរភាពបរិស្ថាន និងការគិតគូរដល់ការប្រើប្រាស់បច្ចេកវិទ្យាដែលមិនបង្កឱ្យមានការខូចខាតដល់បរិស្ថាន (២) ការរក្សា*លំនឹងបរិស្ថានដោយការអភិវឌ្ឍស្អាត* មិនបំពុលបរិស្ថាន ការថែរក្សាគុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ សុវត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ី ការធានាសុវត្ថិភាពចំណីអាហារ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព (៣) ការជំរុញ*សុវត្ថិភាពសង្គម* ដោយការលើកកម្ពស់សុខភាពសាធារណៈ គុណភាពបរិស្ថាននិងជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយចីរភាព និង(៤) ការថែ*រក្សាវប្បធម៌ជាតិ* ដោយរក្សា ការពារ អភិរក្ស ទំនើបកម្មនិងសមាហរណកម្មនូវវប្បធម៌បេតិកភណ្ឌ តាមរយៈពិពិធភាវូបនីយកម្មវប្បធម៌ និងការវិវឌ្ឍវប្បធម៌ប្រពៃណី ទំនៀមទម្លាប់រស់នៅ ដែលរក្សានិងលើកតម្កើងកិត្យានុភាពជាតិនិងអត្តសញ្ញាណជាតិ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ដែលមានគោលដៅកាត់បន្ថយនិងទប់ស្កាត់ការបំពុលបរិស្ថាននិងរក្សាសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី នឹងរួមចំណែកកាត់បន្ថយភាពក្រីក្រ បង្កើនសេវាសុខភាពសាធារណៈ ធានាសុវត្ថិភាពចំណីអាហារ និងលើកកម្ពស់វប្បធម៌ជាតិ ព្រមទាំងរួមចំណែកដល់ការការពារ ថែរក្សាភពផែនដីឱ្យមាននិរន្តរភាព។ ក្នុងបរិបទនេះ គោលនយោបាយដីធ្លីត្រូវផ្តោតជាសំខាន់ដល់ការកាត់បន្ថយហានិភ័យនៃគ្រោះធម្មជាតិនិងហានិភ័យនៃការផ្គត់ផ្គង់ស្បៀង។

រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ខ្ពស់លើសិទ្ធិកាន់កាប់ដីរបស់ប្រជាជនគ្រប់រូប របស់សហគមន៍ឬជនដែលរងផលប៉ះពាល់ផ្សេងៗ ស្របតាមលក្ខខណ្ឌនៃច្បាប់ ជាពិសេសប្រជាកសិករ អ្នកផលិតស្បៀងខ្នាតតូច និងក្រុមជនងាយរងគ្រោះ។ ពួកគេទាំងនោះត្រូវបានការពារដោយគោលនយោបាយ ច្បាប់ យុទ្ធសាស្ត្រ និងសកម្មភាពនានា សំដៅទប់ស្កាត់និងឆ្លើយតបទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ស្របទៅនឹងកាតព្វកិច្ចនិងការអនុវត្តជាអន្តរជាតិ នៅពេលដែលពួកគេត្រូវទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រនិងសកម្មភាពជួយដោះស្រាយ ដែលធ្វើឡើងដោយការពិគ្រោះយោបល់និងការចូលរួមពីអ្នករងគ្រោះ គឺផ្តល់ការគាំទ្រដល់ប្រជាជនឬសហគមន៍ដែលមានសិទ្ធិកាន់កាប់ដី

ស្របតាមលក្ខខណ្ឌនៃច្បាប់ និងសម្របសម្រួលនូវការអនុវត្តកម្មវិធីផ្លាស់ប្តូរលំនៅឋាន ភូមិឋាន ទៅទីតាំងថ្មី ដោយមិនបង្កឬធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃផ្សេងណាឡើយ។

ទន្ទឹមនឹងការដោះស្រាយអ្នករងគ្រោះដោយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់ដល់អ្នកដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិដូចគ្នាដែរ ដោយផ្តល់ការគាំទ្រតាមគ្រប់រូបភាព។ ដូច្នេះ កិច្ចការទាំងនេះត្រូវបានរៀបចំជាក្របខណ្ឌនៃបទដ្ឋានមួយ ដោយរួមបញ្ចូលទាំងការរៀបចំដែនដីជាមួយផង ដើម្បីកាត់បន្ថយផលប៉ះទង្គិចនៃគ្រោះមហន្តរាយធម្មជាតិ។ ក្នុងបរិបទនេះ ទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាព និងកិច្ចសហការអន្តរស្ថាប័ន។

## ៥.១១- គោលនយោបាយដីធ្លីក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ

កម្ពុជាជាសមាជិកមួយនៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ដែលជាតំបន់ដ៏មានសក្តានុពលមួយនៃពិភពលោក។ ក្នុងឋានៈជារដ្ឋហត្ថលេខីនៃសេចក្តីប្រកាសជាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អលើវិស័យបរិស្ថាន ដីធ្លី ធនធានទឹក។ល។ កម្ពុជានឹងរៀបចំគោលការណ៍ ច្បាប់ និងបទដ្ឋានគតិយុត្តផ្ទៃក្នុងរបស់ខ្លួនឱ្យស្របទៅនឹងគោលការណ៍នៃប្រទេសក្នុងតំបន់និងអន្តរជាតិ លើការគ្រប់គ្រងធនធានឆ្លងកាត់ព្រំដែន ការគ្រប់គ្រងចលនាបម្លាស់ទីរបស់ប្រជាជន ការសម្របសម្រួល និងយុទ្ធសាស្ត្រទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។ល។ ករណីនេះតម្រូវឱ្យមានការចូលរួមគាំទ្រពីអន្តរជាតិលើផ្នែកបទដ្ឋានសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាព ដោយរក្សានូវមូលដ្ឋានច្បាប់និងមតិកវប្បធម៌របស់ខ្លួន។

ការអនុលោមតាមគោលការណ៍និងច្បាប់នានានៃប្រទេសក្នុងតំបន់និងអន្តរជាតិ គឺជាកាតព្វកិច្ចរបស់រដ្ឋមួយដែលភារកិច្ចនេះមិនមែនជាការបង្ខិតបង្ខំឬការដាក់បន្ទុកនោះឡើយ តែវាជាផលចំណេញក្នុងការវិនិយោគទៅលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ គោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ គឺការខិតខំធ្វើឱ្យសម្រេចគោលដៅជាយុទ្ធសាស្ត្រ ជាពិសេស ការទទួលបានដីធ្លីសម្រាប់ជីវភាពរស់នៅ ការធានានូវសុខភាពនិងសុខុមាលភាពរបស់ប្រជាជន ដោយមិនទាក់ទងទៅនឹងបូរណភាពដែនដី តែក្នុងឋានៈជារដ្ឋឯករាជ្យដែលត្រូវខិតខំ៖

- អនុវត្តរាល់កាតព្វកិច្ចជាគោលការណ៍របស់រដ្ឋក្នុងតំបន់និងអន្តរជាតិ ដោយការកាត់បន្ថយនូវគម្លាតលើការអនុវត្តគោលនយោបាយដីធ្លី
- សម្របសម្រួលគោលនយោបាយ ច្បាប់និងបទដ្ឋានពាក់ព័ន្ធដីធ្លីនិងធនធានធម្មជាតិ ដើម្បីរក្សាភាពសុខដុមនៃគោលនយោបាយ ច្បាប់និងបទដ្ឋានក្នុងតំបន់អាស៊ីអាគ្នេយ៍
- កសាងផែនការអភិវឌ្ឍរួមគ្នា ជាពិសេស នៅតំបន់ព្រំដែនជាមួយប្រទេសជាដៃគូ ដើម្បីរៀបចំពិធីសារសម្រាប់គ្រប់គ្រងលំហូរឆ្លងកាត់ផ្សេងៗ ការចែករំលែកព័ត៌មាន និងអំពីការគ្រប់គ្រងធនធានធម្មជាតិ
- ជំរុញការវាស់វែងនិងការកំណត់ព្រំដែននៅតាមបណ្តោយព្រំប្រទល់ជាមួយប្រទេសជិតខាងរបស់កម្ពុជា ធ្វើឱ្យតំបន់ព្រំដែនក្លាយជាព្រំដែនមិត្តភាពនិងសហប្រតិបត្តិការ និង

- ជំរុញការកសាងបទដ្ឋានពាក់ព័ន្ធនឹងកាត់បន្ថយរនាំងឆ្លងកាត់ព្រំដែនរបស់ប្រជាជននិងពលករក្នុងក្របខណ្ឌសហគមន៍អាស៊ីអាគ្នេយ៍ ជោគវាសនាតែមួយ។

## ៦- ការតាមដានត្រួតពិនិត្យ

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយដីធ្លី ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរៀបចំផែនការសកម្មភាពការងារ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រតាមវិស័យ ក្នុងការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិឱ្យមានផលិតភាពនិងនិរន្តរភាព។ ការងារនេះទាមទារនូវការលើកកម្ពស់ការកសាងសមត្ថភាពជំនាញដល់មន្ត្រីគ្រប់កម្រិតថ្នាក់ លើផ្នែកបច្ចេកទេស និងផ្នែកច្បាប់ពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្តជាធរមាន។ ទន្ទឹមនឹងការពង្រឹងសមត្ថភាពជំនាញ វិន័យក្រមសីលធម៌ក្នុងការបំពេញការងារដល់មន្ត្រីអនុវត្តគោលនយោបាយដីធ្លី ក៏ត្រូវបង្កើនការយល់ដឹងដល់សង្គមស៊ីវិល វិស័យឯកជន អ្នកសិក្សាស្រាវជ្រាវ ក្រុមកសិករ ក្រុមផលិតករនៃកសិដ្ឋានខ្នាតតូច សហគមន៍អ្នកនេសាទ អ្នកប្រើប្រាស់ផលនិងអនុផលព្រៃឈើ ក្រុមជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធទាំងអស់ ឱ្យចូលរួមក្នុងអភិបាលកិច្ចក៏ដូចជាការតាមដានត្រួតពិនិត្យ។ ដូច្នេះ ទន្ទឹមនឹងការកសាងសមត្ថភាពមន្ត្រីគ្រប់កម្រិតថ្នាក់ ក៏ត្រូវគិតគូរដល់ការលើកទឹកចិត្តជាពិសេសផងដែរ។

### ៦.១- ការកសាងសមត្ថភាពនិងការសម្របសម្រួលស្ថាប័ន

ក្រៅពីការបូកសរុបនិងរៀបចំផែនការសកម្មភាពការងារប្រចាំខែ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ បានយកចិត្តទុកដាក់ជាប្រចាំលើការកសាងសមត្ថភាពជំនាញនិងបច្ចេកទេសពាក់ព័ន្ធនឹងរដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការងារលំនៅឋាន។ ក្នុងការលើកកម្ពស់សមត្ថភាពជំនាញនិងបច្ចេកទេសសម្រាប់អនុវត្តការងារ ក្រសួងក៏បានជំរុញការចងក្រងគោលនយោបាយនិងបទប្បញ្ញត្តិ ព្រមទាំងរៀបចំបន្សីបទដ្ឋានគតិយុត្តទាំងឡាយឱ្យមានសង្គតិភាព ដើម្បីឱ្យការអនុវត្តបានរលូនជាមួយនឹងបទប្បញ្ញត្តិនៃក្រសួងស្ថាប័ននានា។

កន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបើកវគ្គបំពាក់បំប៉ននិងវគ្គបណ្តុះបណ្តាលជាប្រចាំដល់មន្ត្រីដែលកំពុងបំពេញការងារ នៅថ្នាក់កណ្តាល នៅតាមមន្ទីរនិងការិយាល័យ លើផ្នែកច្បាប់និងបទដ្ឋានគតិយុត្ត លើផ្នែកការងារសុរិយោដី ការងាររៀបចំដែនដី ការងារដោះស្រាយវិវាទដីធ្លី ការងារបែងចែកដីធ្លី និងគោលនយោបាយផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យដីធ្លី។ ទោះជាយ៉ាងណា ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាននិងជំនាញបច្ចេកទេស នៅពុំទាន់ឆ្លើយតបទៅនឹងការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ចនិងសង្គមនៅឡើយ។

ក្នុងគោលដៅពង្រីកនិងពង្រឹងសមត្ថភាពជំនាញ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ GIZ បានសហការជាមួយសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ដាក់ឱ្យដំណើរការ**មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី** ដើម្បីបណ្តុះបណ្តាលកម្រិតជំនាញថ្នាក់ឧត្តមផ្នែករដ្ឋបាលដីធ្លីនិងរៀបចំដែនដី ព្រមទាំងបានរៀបចំ

សិក្ខាសាលាប្រចាំឆ្នាំលើការងារដីធ្លី ដែលឧបត្ថម្ភដោយសកលវិទ្យាល័យក្រុងមុយនិកនៃសាធារណរដ្ឋអាល្លឺម៉ង់។ ជាមួយនេះ ក្រសួងក៏បានបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈខាងសុរិយោដីនិងរៀបចំដែនដីកម្រិតមធ្យម និងមានការរៀបចំកម្មវិធីបំប៉នជាប្រចាំដល់មន្ត្រីដែលកំពុងបំពេញការងារនៅថ្នាក់កណ្តាល នៅតាមមន្ទីរនិងនៅតាមការិយាល័យ។ បន្ថែមលើនេះ មន្ត្រីជំនាញមួយចំនួនក៏បានទទួលអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬចូលរួមក្នុងសិក្ខាសាលាអន្តរជាតិពាក់ព័ន្ធនឹងការងារដីធ្លី។

ក្នុងការសម្របសម្រួលស្ថាប័ន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ពិគ្រោះយោបល់ សម្របសម្រួលនិងស្វែងរកការស្រុះស្រួលគ្នាក្នុងការកសាងលិខិតបទដ្ឋានគតិយុត្តឬការអនុវត្តវិធាននានាពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី។ ទោះជាយ៉ាងណា ក្នុងការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី ទាំងដីរដ្ឋទាំងដីរបស់បុគ្គលឯកជននៅជួបនឹងបញ្ហាប្រឈមមួយចំនួន ដែលអាចបណ្តាលមកពីការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ហើយការអនុវត្តក៏នៅពុំទាន់បានគ្រប់ជ្រុងជ្រោយ។

## ៦.២- ការពង្រឹងការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត

ក្រោយពីការសម្រេចលើក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ច្បាប់និងបទដ្ឋានគតិយុត្តក្រោមច្បាប់ជាច្រើនត្រូវបានដាក់ឱ្យដំណើរការ។ ប៉ុន្តែការអនុវត្ត នៅមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ ដែលអាចមកពីការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាននានាមិនទាន់ស៊ីជម្រៅដល់មូលដ្ឋាន ភាពក្រីក្រនិងការស្វែងយល់អំពីច្បាប់ផ្សេងៗពីសំណាក់ប្រជាពលរដ្ឋនៅទាប ហើយសមត្ថភាពជំនាញនៃមន្ត្រីនៅតាមមូលដ្ឋានក៏នៅមានកម្រិត។ ក្នុងបរិបទនេះ ចាំបាច់ត្រូវមានកិច្ចសហការរៀបចំកម្មវិធីអប់រំនិងផ្សព្វផ្សាយជាចង្វាក់ដល់មូលដ្ឋាន ដើម្បីពង្រឹងការយល់ដឹង និងអនុវត្តវិធានការរដ្ឋបាលសំដៅធានាសមភាពរបស់ពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅចំពោះមុខច្បាប់។ កិច្ចការទាំងនេះជាវិធានការរួមចំណែកដល់ការពង្រឹងនីតិរដ្ឋតាមរយៈការងារដីធ្លី។

ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អនិងធានាតុល្យភាពរវាងការអភិវឌ្ឍនិងអភិរក្ស ក្រៅពីលិខិតបទដ្ឋានជាធរមាន ក្រសួងស្ថាប័នជំនាញពាក់ព័ន្ធក៏ត្រូវបន្តការកសាងច្បាប់បទដ្ឋានគតិយុត្តបំពេញបន្ថែមតម្រូវការនៃការអភិវឌ្ឍចំពោះមុខ និង/ឬធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិជាធរមានតាមវិស័យ តាមផ្នែកឱ្យបានរលូនជាមួយគ្នា និងសម្របសម្រួលការអនុវត្តឱ្យមានប្រសិទ្ធភាព។

ច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ ច្បាប់ស្តីពីការធ្វើអនុបយោគដី ច្បាប់រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រមសំណង់ ច្បាប់ស្តីពីការវាស់វែងនិងការផលិតផែនទី ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ច្បាប់ស្តីពីពន្ធលើអចលនទ្រព្យ... និងលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនទៀត ជារបៀបវារៈនៃការពិចារណានៅតាមក្រសួងនិងស្ថាប័នរបស់រដ្ឋ។

ដើម្បីបំពេញទៅនឹងតម្រូវការនៃការវិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ច្បាប់ និងបទដ្ឋានគតិយុត្ត ក្រោមច្បាប់មួយចំនួនទៀតត្រូវរៀបចំដាក់ឱ្យអនុវត្ត ជាអាទិ៍៖

- អនុក្រឹត្យស្តីពីការរៀបចំដែនដីថ្នាក់ខេត្ត ថ្នាក់តំបន់
- អនុក្រឹត្យស្តីពីប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានីទី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ
- ការកំណត់ស្តង់ដានៃការចុះបញ្ជីបន្តលើអចលនវត្ថុ
- ការអនុវត្តនីតិវិធី សិទ្ធិប្រាតិភោគប្រត្យក្ស
- ផែនការប្រើប្រាស់ដី ការរៀបចំដែនដី និងនគរូបនីយកម្ម
- នីតិវិធីនៃការប្តូរប្រភេទប្រើប្រាស់ដី។ល។

ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ ការគ្រប់គ្រងដីធ្លីត្រូវបានពង្រឹងនិងផ្ទេរភារកិច្ចទទួលខុសត្រូវដល់ថ្នាក់ក្រោមជាតិ ជាអាទិ៍ ភារកិច្ចថែរក្សានិងធ្វើចរន្តការប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋត្រូវបានប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តនិងអាជ្ញាធរដែនដីក្នុងមូលដ្ឋានផ្ទាល់ ដើម្បីការពារនិងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋ។

ក្នុងក្របខណ្ឌនៃការតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ លិខិតបទដ្ឋានរបស់ថ្នាក់ជាតិពាក់ព័ន្ធនឹងការងារដីធ្លី ក្រសួងស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋត្រូវ៖

- ធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងផ្តល់ឯកសារពាក់ព័ន្ធនឹងការប្រើប្រាស់ដីជូនអាជ្ញាធរមូលដ្ឋាន ដើម្បីចូលរួមតាមដានការអនុវត្ត
- ជំរុញការធ្វើផែនការរៀបចំដែនដីដោយមានការចូលរួមពីគ្រប់ស្ថាប័នជំនាញ និងសង្គមស៊ីវិល ព្រមទាំងប្រជាជនក្នុងមូលដ្ឋាន ដើម្បីកំណត់តំបន់ប្រើប្រាស់ដីស្របទៅតាមអំណោយផលធម្មជាតិនៃដីនិងតម្រូវការនៃការអភិវឌ្ឍ ជាពិសេស តំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចនិងតំបន់អាទិភាព
- ជំរុញការអនុវត្តភាពជាដៃគូរវាងសម្បទានិកនៃសម្បទានដីសេដ្ឋកិច្ចជាមួយនឹងសហគមន៍មូលដ្ឋានឬកសិករខ្នាតមធ្យមនិងខ្នាតតូចក្នុងតំបន់ ឬជាមួយនឹងសម្បទានិកនៃសម្បទានដីសង្គមកិច្ចដែលនៅជិតខាង ឱ្យក្លាយជាដៃគូពិតប្រាកដនឹងបំពេញឱ្យគ្នាទៅវិញទៅមកដើម្បីទទួលបានផលចំណេញទាំងអស់គ្នា។

## ៧- សេចក្តីសន្និដ្ឋាន

គោលនយោបាយដីធ្លីឬសៀវភៅសដីធ្លី គឺជាលទ្ធផលនៃការអភិវឌ្ឍសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លីនាខែកក្កដា ឆ្នាំ២០០៩ និងការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កាជាច្រើនលើកច្រើនសាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ រហូតមកដល់ពេលនេះ ឯកសារគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារដីធ្លី ដែលមានចែងក្នុងឯកសារក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល ឆ្នាំ២០០២ ត្រូវបានតាក់តែងនិងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។

សៀវភៅសដីធ្លីអាចចាត់ទុកជាត្រីវិស័យក្នុងការកាត់បន្ថយភាពក្រីក្រនិងការធានាសន្តិសុខស្បៀង ជាពិសេស ការចេញបណ្ណកម្មសិទ្ធិលើដីធ្លី ការរៀបចំប្រព័ន្ធស្រោចស្រព ការផ្ដល់ចំណេះដឹងអំពីការដាំដុះ គួបផ្សំនឹងកម្មវិធីបង្កើតមុខរបរនិងមុខជំនួញប្រចាំគ្រួសារ។ ការងារទាំងនេះគឺជាទិសដៅនៃកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល ដែលនឹងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើងតាមរយៈការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែកដីធ្លី និងធ្វើឱ្យប្រទេសជាតិអភិវឌ្ឍប្រកបដោយសមធម៌ មានចីរភាពនិងរក្សាបានលំនឹងបរិស្ថានសម្រាប់សង្គមជាតិនាពេលបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយទៀត។ ប្រការនេះទាមទារនូវការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តការងារតាមផ្នែក និងកំណត់នូវបញ្ហាថ្មីៗដែលអាចនឹងលេចឡើងក្នុងការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត ដើម្បីធ្វើបច្ចុប្បន្នកម្មសៀវភៅសដីធ្លីតាមការវិវឌ្ឍនៃដំណាក់កាល ដោយៈ

- ត្រួតពិនិត្យនូវការងារដែលបានអនុវត្ត សម្រាប់ធ្វើការកែលម្អគោលនយោបាយតាមកាលកំណត់ **អាចរៀងរាល់៥ឆ្នាំម្ដងនិង/ឬលើកសំណើនូវគោលនយោបាយថ្មីទៀត**
- ត្រួតពិនិត្យឡើងវិញនូវគោលនយោបាយដីធ្លីទាំងមូល **រៀងរាល់១០ឆ្នាំម្ដង** និង
- កែតម្រូវផែនការសកម្មភាពឬយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី តាមការចាំបាច់។

ដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តច្បាប់ លិខិតបទដ្ឋានឬបទប្បញ្ញត្តិទាំងឡាយតាមស្មារតីនៃសៀវភៅសដីធ្លី ចាំបាច់ត្រូវបង្កើនការយល់ដឹងនូវខ្លឹមសារជាសារវន្តនៃគោលនយោបាយដីធ្លីដល់គ្រប់អ្នកពាក់ព័ន្ធ និងសម្របសម្រួលយុទ្ធសាស្ត្រនិងនីតិវិធីក្នុងការអនុវត្តឱ្យរលូនជាមួយគ្នា ដោយការប្ដេជ្ញាចិត្តខ្ពស់ក្នុងការបំពេញមុខងារនិងភារកិច្ចតាមជំនាញ ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់រូបភាពដល់ប្រជាជនគ្រប់ស្រទាប់នូវខ្លឹមសារសៀវភៅសដីធ្លី។

**ឯកសារពិគ្រោះ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ច្បាប់ភូមិបាល ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១
- ច្បាប់ស្តីពីព្រៃឈើ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២
- ច្បាប់ស្តីពីជលផល ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦
- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ច្បាប់ស្តីពីអសុប្រាមិករណ៍ ឆ្នាំ២០១០
- ឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២។

## សទ្ទានុក្រម

ក្រឡោត ក្បាច់ចម្លាក់ដែលលៀនចេញ

ក្សេត្របរិស្ថាន លក្ខខណ្ឌសមស្របសម្រាប់កិច្ចការស្រែចម្ការនិងការដាំដុះ(អំណោយផលពីធម្មជាតិនៃដី បរិស្ថាន និងលក្ខខណ្ឌផ្សេងទៀត)។

គ្រោះទឹកជំនន់ ទឹកជំនន់ឡើងខ្ពស់ហួសកម្រិតធម្មតា។ ឧ. នៅរដូវទឹកឡើង ជាធម្មតា ទឹកទន្លេមេគង្គមានកម្ពស់មិនលើសពី១១ម៉ែត្រនៅភ្នំពេញ ដោយនីវ៉ូរាជធានីភ្នំពេញមានប្រមាណ១០ម២០ត្រង់ស្ពានីយឫស្សីកែវនិង១១ម៥០មុំគល់ស្ពានជ្រោយចង្វា។

គ្រោះរាំងស្ងួត កម្រិតទឹកក្រោមដីធ្លាក់ចុះទាបខុសធម្មតា បណ្តាលមកពីការរាំងស្ងួតបន្តជាប់គ្នាជាច្រើនឆ្នាំ ធ្វើឱ្យរុក្ខជាតិមួយចំនួនមិនអាចបឺតទឹកមកចិញ្ចឹមខ្លួនបាន។

តំបន់បបនីយជីវមណ្ឌល តំបន់ដែលមានប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់និងមិនរងការខូចខាតខ្លាំង ហើយព័ទ្ធជុំវិញដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាព

តំបន់រ៉ាមសារ ជាតំបន់ដីសើមមានសារៈសំខាន់ផ្នែកអេកូឡូស៊ីឬជីវៈចម្រុះ

តំបន់ដីសើម ជាវាលភក់ វាលល្បប់ មានរុក្ខជាតិពុករលួយ មានទឹកលិចអំចិន្ត្រៃយ៍ឬតាមរដូវ

ទុរភិក្ស (ទុរ្ភិក្ស) ដំណើរក្រេបាយឬអត់បាយ។

ធរណីសាស្ត្រ ការសិក្សាពីដីនិងក្សេត្រកម្ម។

បុព្វសិទ្ធិ សិទ្ធិពិសេសដែលឱ្យដាច់ទៅលើមុខងារឬទៅលើក្រុមមួយលើសពីអ្នកដទៃ។

បុរិមា សិទ្ធិដែលបើកឱ្យជនឬក្រុមណាមួយបានអ្វីមួយមុនជនឬក្រុមដទៃទៀត។

ប្រាតិភោគ ការដាក់ធានាដល់ម្ចាស់បំណុល។

ពិពិធភាវូបនីយកម្ម ការធ្វើឱ្យបានច្រើនមុខ ច្រើនយ៉ាង ផ្សេងៗគ្នា។

ភណ្ឌិក អ្នកទទួលទ្រព្យដែលបានដាក់ធានាបំណុលឬកាតព្វកិច្ចអ្វីមួយ ដោយមានសិទ្ធិប្រើប្រាស់ទ្រព្យនោះតែត្រូវរក្សាលំនាំដើមនៅពេលសងទៅម្ចាស់ដើមវិញ។

ភតិកៈ ភាគីម្ខាងនៃកិច្ចសន្យា ដែលត្រូវបង់ថ្លៃឈ្នួលដើម្បីទទួលបានសិទ្ធិប្រើប្រាស់និងអាស្រ័យផលពីវត្ថុណាមួយរបស់ភតិបតី។

ភតិសន្យា កិច្ចសន្យាមួយដែលភាគីម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់និងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃឈ្នួល។

ភូគព្ភសាស្ត្រ វិទ្យាសាស្ត្រដែលសិក្សាពីផែនដី(វត្ថុរឹង មានដីនិងសិលាផ្សំនៃផែនដី) តាមរយៈប្រវត្តិនៃការផ្លាស់ប្តូរអាកាសធាតុ សមាសធាតុ និងដំណើរវិវត្ត ដូចជាចលនារចិតវិវឌ្ឍន៍(tectonics)។ បច្ចុប្បន្ន ភូគព្ភសាស្ត្រមានសារៈសំខាន់ក្នុងផ្នែកពាណិជ្ជកម្ម ប្រើសម្រាប់ការរុករករ៉ែក្រោមដី និងការប៉ាន់ស្មានភាពចៃដន្យនៃធម្មជាតិ។

មតកជន ជនដែលបានស្លាប់ទៅហើយ។

មាត្រដ្ឋាន រង្វាស់ រង្វាល់ ខ្នាត កម្រិត បែប ប្រភេទ ដែលជាមូលដ្ឋាននៃការវិនិច្ឆ័យ។

លទ្ធកម្ម ការទទួលបានឬការធ្វើឱ្យទៅជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួន ឬដោយទិញ ឬដោយដូរ។

វាយនភាពដី ដីមានភាពធូរ ងាយស្រូបសារធាតុចិញ្ចឹមពីបរិយាកាស (ឧ. Nitrogen)

សព៌ាង្គ រូបរាងឬអង្គទាំងមូល

សិទ្ធិប្រត្យក្សឬសិទ្ធិភណ្ឌិក សិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន

អាជ្ញាយុកាល អំឡុងពេលមួយដែលកំណត់ដោយច្បាប់។